សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ទំនាក់ទំនងរវាងការវិនិយោគផ្ទាល់ពីបរទេស និងការកាត់បន្ថយវិសមភាពនៃប្រាក់ចំណូល៖ ករណីសិក្សាប្រទេសកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២


ស្រាវជ្រាវដោយនិស្សិតឈ្មោះ
លោក **យ៉ាំ ឧត្តម** និងលោក **យុន ឧត្តម**

សាស្ត្រាចារ្យណែនាំ
បណ្ឌិត **ស្រ៊ុន សុភ័ក្ត្រ**


ថ្នាក់បរិញ្ញាបត្រ **សេដ្ឋកិច្ចអភិវឌ្ឍន៍**
ជំនាន់ទី៦ (សិក្សាបង់ថ្លៃ)

ឆ្នាំចូលសិក្សា ២០១៨
ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **យ៉ាំ ឧត្តម** និងខ្ញុំបាទឈ្មោះ **យុន ឧត្តម** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍ ដែលកំពុងតែសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមធ្វើការសម្តែងនូវកតញ្ញូតាធម៌ និងអំណរអរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ៖

អ្នកម្តាយ **សួន គន្ធា** លោកឪពុក **ណុប ណូ** និងអ្នកម្តាយ **ខៀន នាង** លោកឪពុក **ខែម ប្រុស** ដែលបានផ្តល់កំណើត ចិញ្ចឹមថ្នាក់ថ្នមបីបាច់ថែរក្សា ផ្តល់នូវសេចក្តីស្រឡាញ់ប្រកបទៅដោយព្រហ្មវិហារធម៌ អប់រំទូន្មានប្រៀនប្រដៅ និងទំនុកបម្រុងសព្វគ្រប់បែបយ៉ាង ទាំងសម្ភារៈ ទាំងស្មារតី និងថវិកាឲ្យកូនបានមកសិក្សារៀនសូត្ររហូតមានចំណេះវិជ្ជារហូតមកដល់សព្វថ្ងៃនេះ ទោះបីមានឧបសគ្គជាច្រើន ជាពិសេសរឿងថវិកាយ៉ាងណាក្តី ក៏លោកទាំងពីរខិតខំប្រឹងប្រែងធ្វើយ៉ាងណាឲ្យកូនបានរៀននៅសាកលវិទ្យាល័យរហូតដល់ចប់បរិញ្ញាបត្រ។

ជាងនេះទៅទៀត យើងខ្ញុំបាទសូមថ្លែងអំណរគុណទៅដល់ **លោកពូ អ្នកមីង អ៊ំប្រុស អ៊ំស្រី** នៅឯភ្នំពេញដែលបានផ្តល់ជាកន្លែងស្នាក់នៅ អាហារហូបចុក ជាពិសេសដំបូន្មានល្អៗជាច្រើនដល់រូបយើងខ្ញុំ ឲ្យស្គាល់មាគ៌ាមួយត្រឹមត្រូវធ្វើឲ្យយើងខ្ញុំបានដើរមកដល់ចំណុចនេះ ជាពិសេស **លោកពូ អ្នកមីង អ៊ំប្រុស អ៊ំស្រី** ប្រៀបបានដូចជាឪពុកម្តាយទីពីររបស់យើងខ្ញុំដូច្នេះដែរ។

ជាពិសេស សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតទៅដល់សាស្ត្រាចារ្យបណ្ឌិត **ស្រ៊ុន សុភ័ក្ត្រ** ជាសាស្ត្រាចារ្យណែនាំ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ និងមមាញឹកក្នុងការបង្ហាត់បង្រៀន ដើម្បីផ្តល់ការណែនាំដល់យើងខ្ញុំក្នុងការសរសេរ និងរៀបចំសារណាបញ្ចប់ការសិក្សានេះឡើង។ ជាពិសេសគាត់បានផ្តល់នូវឱកាស និងការបង្ហាត់បង្ហាញ បូករួមទាំងចំណេះដឹងផ្សេងៗជាច្រើនទៀត ដែលជាគន្លឹះមួយដែលញ៉ាំងឲ្យកិច្ចការមួយនេះចេញជារូបរាងឡើងបាន និងមានលក្ខណៈតម្លៃគ្រប់គ្រាន់ ដើម្បីជាឯកសារស្រាវជ្រាវមួយនេះឡើងបាន។ បន្ថែមពីនេះទៅទៀត យើងខ្ញុំសូមថ្លែងអំណរគុណដល់ **ឯកឧត្តមសកលវិទ្យាធិការ សកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យ និងលោកគ្រូអ្នកគ្រូ** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំអប់រំអស់ពីសមត្ថភាពក្នុងការផ្ទេរ ចំណេះដឹង បទពិសោធន៍ ឯកសារសម្រាប់ការសិក្សាស្រាវជ្រាវ ដល់យើងខ្ញុំបាទក្នុងការសិក្សារៀនសូត្រ និងជាទីកន្លែងសម្រាប់ធ្វើការស្រាវជ្រាវ។

ជាចុងបញ្ចប់ យើងខ្ញុំបាទ សូមបួងសួងឲ្យវត្ថុស័ក្តសិទ្ធិទាំងអស់ក្នុងលោក តាមថែរក្សា ការពារ និងប្រសិទ្ធពរជ័យ សិរីសួស្តីដល់អ្នកទាំងអស់គ្នា ឲ្យចៀសផុតពីជំងឺដ៏កាចសាហាវ និងជួបប្រទះតែសេចក្តីសុខសេចក្តីចម្រើន សុខភាពល្អ កាយសម្បទារឹងមាំ អាយុយឺនយូ ជោគជ័យគ្រប់ភារកិច្ច និងជួបតែពុទ្ធពរ ទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# **អារម្ភកថា**

ជាបឋមខ្ញុំបាទឈ្មោះ **យ៉ាំ ឧត្តម** និងខ្ញុំបាទឈ្មោះ **យុន ឧត្តម** សូមគោរព និងជម្រាបសួរទៅដល់សាស្ត្រាចារ្យទាំងអស់ជាទីគោរព និងសូមស្វាគមន៍ដល់មិត្តសិស្សានុសិស្ស និស្សិត អ្នកស្រាវជ្រាវទាំងអស់ជាទីស្រឡាញ់រាប់អាន។ ឆ្លងតាមការសិក្សារយៈពេល៤ឆ្នាំកន្លងមកនេះ នៃការសិក្សាជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍ បានផ្តល់ឲ្យយើងខ្ញុំនូវចំណេះដឹងផ្សេងៗកាន់តែទូលំទូលាយពាក់ព័ន្ធនឹង សេដ្ឋកិច្ចអភិវឌ្ឍន៍ អភិវឌ្ឍន៍ជនបទ ការវិនិយោគពាណិជ្ជកម្មអន្តរជាតិ និងមុខវិជ្ជាមួយចំនួនផ្សេងៗទៀត។ ស្ថិតនៅវ័យជានិស្សិតយើងតែងតែមានក្តីស្រមៃ គោលបំណង និងមហិច្ឆតាចង់ចែករំលែកនូវចំណេះដឹងបទពិសោធន៍ដែលយើងមាននៅក្នុងជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍នេះទៅដល់និស្សិតប្អូនៗជំនាន់ក្រោយ ជាពិសេសយកជំនាញ និងសមត្ថភាពដែលយើងមានពេលនេះទៅជួយអភិវឌ្ឍដល់ប្រទេសកម្ពុជាយើងថែមទៀតផង។ មកដល់ពេលនេះយើងក៏មានឱកាសក្នុងការធ្វើសារណាដើម្បីបញ្ចប់ការសិក្សានៃជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍នេះ វាពិតជារឿងដែលអស្ចារ្យ និងមោទកភាពសម្រាប់យើងទាំងពីរនាក់ ព្រោះក្តីស្រមៃដែលយើងប៉ងគឺបានក្លាយជាការពិត ក្រោមការខិតខំប្រឹងប្រែងសិក្សារបស់យើងខ្ញុំកន្លងមកនេះ។ យ៉ាងណាមិញការស្រាវជ្រាវមួយនេះទៀតសោត ក៏បានជួបនៅផលវិបាកមួយចំនួនក្នុងអំឡុងពេលស្រាវជ្រាវ ព្រោះយើងខ្ញុំទាំងពីរត្រូវបែងចែកពេលវេលាធ្វើការផង និងសិក្សាស្រាវជ្រាវផង ពេលខ្លះយើងឈានដល់ការធ្វើកិច្ចការស្រាវជ្រាវដល់យប់ជ្រៅថែមទៀតផង ប៉ុន្តែបញ្ហា និងឧបសគ្គទាំងអស់នេះមិនអាចយកឈ្នះនូវឆន្ទៈរបស់យើងខ្ញុំទាំងពីរនាក់បានទេ។

សារណាបញ្ចប់ការសិក្សានេះក្រោមប្រធានបទ៖ **ទំនាក់ទំនងរវាងការវិនិយោគផ្ទាល់ពីបរទេស និងការកាត់បន្ថយវិសមភាពនៃប្រាក់ចំណូល៖ ករណីសិក្សាប្រទេសកម្ពុជា**។ ឯកសារចងក្រងនេះផ្តោតសំខាន់ទៅលើ ការសិក្សាស៊ីជម្រៅពីឥទ្ធិពលនៃការវិនិយោគពីបរទេសមកលើប្រាក់ចំណូលនៅក្នុងប្រទេសកម្ពុជា ដែលការវិនិយោគពីបរទេសនេះបានរួមចំណែកយ៉ាងសំខាន់ក្នុងការកាត់បន្ថយនូវវិសមភាពនៃប្រាក់ចំណូលរបស់ប្រជាជនកម្ពុជា ជាពិសេសគឺកាត់បន្ថយនូវទំហំគម្លាតចំណូលរវាងអ្នកមាន និងអ្នកក្រ អ្នករស់នៅទីក្រុង និងទីជនបទ។ ម្យ៉ាងវិញទៀត វាជាឱកាសមួយក្នុងការសិក្សា និងវិភាគអំពីចំនួនប្រភេទក្រុមហ៊ុន និងអ្នកវិនិយោគគោលដៅ ដែលយើងត្រូវយកចិត្តទុកដាក់ ដើម្បីធ្វើយ៉ាងណាឲ្យការបែកចែកមួយនេះមានប្រសិទ្ធភាពឈានដល់ការសម្រេចគោលដៅ និងទទួលបានលទ្ធផលល្អពីការវិនិយោគផ្ទាល់ពីបរទេសមកលើប្រទេសកម្ពុជា។

ជាចុងក្រោយយើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា សារណាមួយនេះនឹងជួយដល់អ្នកអាន និងអ្នកស្រាវជ្រាវដែលចង់ទទួលបាននូវចំណេះដឹង និងយល់ច្បាស់អំពីការវិនិយោគផ្ទាល់ពីបរទេសមកលើប្រាក់ចំណូលប្រជាជននៅក្នុងប្រទេសកម្ពុជាជាក់ជាមិនខាន។ យើងខ្ញុំរង់ចាំដោយក្តីសោមនស្សរីករាយ ដើម្បីទទួលនូវមតិរិះគន់កែលម្អពីសំណាក់សាស្ត្រាចារ្យ លោកគ្រូអ្នកគ្រូ និងមិត្តអ្នកអានទាំងអស់ ដើម្បីឲ្យស្នាដៃមួយនេះកាន់តែប្រសើរឡើងមួយកម្រិតទៀត។

# មាតិកា

**ទំព័រ**

**បញ្ជីអក្សរកាត់** ........ iv
**បញ្ជីតារាង** ........ v
**បញ្ជីក្រាហ្វិក** ........ vi

## ជំពូកទី១

## សេចក្តីផ្តើម

១.១ សេចក្តីផ្តើម ........ ១
១.២ ចំណោទបញ្ហា និងសំណួរនៃការស្រាវជ្រាវ ........ ២
១.៣ វត្ថុបំណងនៃការសិក្សាស្រាវជ្រាវ ........ ៣
១.៤ វិសាលភាពនៃការសិក្សាស្រាវជ្រាវ ........ ៤
១.៥ សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ ........ ៤
១.៦ រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ ........ ៥

## ជំពូកទី២

## វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

២.១ សេចក្តីផ្តើម ........ ៦
២.២ ការពិនិត្យទៅលើឯកសារយោងដែលពាក់ព័ន្ធ ........ ៦
២.៣ ការវិភាគទិន្នន័យ ........ ៦
២.៤ ការរំពឹងទុក និងលទ្ធផលទទួលបាន ........ ៧

## ជំពូកទី៣

## ការវិនិយោគផ្ទាល់ពីបរទេស (FDI) នៅក្នុងប្រទេសកម្ពុជា

៣.១ សេចក្តីផ្តើម ........ ៨
៣.២ និយមន័យការវិនិយោគផ្ទាល់ពីបរទេស (FDI) ........ ៨
៣.៣ ប្រវត្តិនៃការវិនិយោគផ្ទាល់ពីបរទេសនៅក្នុងប្រទេសកម្ពុជា ........ ១០
៣.៣.១ ការវិនិយោគនៅសម័យសង្គមរាស្ត្រនិយម (១៩៥៣ ដល់ ១៩៧០) ........ ១០

៣.៣.២ ការវិនិយោគនៅសម័យសាធារណៈរដ្ឋខ្មែរ (១៩៧០ ដល់ ១៩៧៥)................................១២
៣.៣.៣ ការវិនិយោគនៅសម័យកម្ពុជាប្រជាធិបតេយ្យ (១៩៧៥ ដល់ ១៩៧៩)............................ ១៤
៣.៣.៤ ការវិនិយោគនៅសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា (១៩៧៩ ដល់ ១៩៨៩) ............... ១៤
៣.៣.៥ ការវិនិយោគនៅសម័យរដ្ឋកម្ពុជា និងអ៊ុនតាក់ (១៩៨៩ ដល់ ១៩៩៣) ............................ ១៥
៣.៣.៦ ការវិនិយោគនៅសម័យព្រះរាជាណាចក្រកម្ពុជា (១៩៩៣ ដល់ បច្ចុប្បន្ន)......................... ១៦
៣.៤ មូលដ្ឋានគ្រឹះ ដែលទាក់ទងនឹងការវិនិយោគផ្ទាល់ពីបរទេស (FDI) ........................................១៧
៣.៤.១ ប្រភេទនៃការវិនិយោគផ្ទាល់ពីបរទេស (Types of FDI) ................................................ ១៨
៣.៤.២ ទម្រង់នៃការវិនិយោគផ្ទាល់ពីបរទេស ......................................................................២០
៣.៤.៣ ការកំណត់ដោយរដ្ឋាភិបាលកម្ពុជា ទៅលើការវិនិយោគផ្ទាល់ពីបរទេស .......................... ២២
៣.៤.៤ ប្រភេទនៃការវិនិយោគផ្ទាល់ពីបរទេស (FDI) នៅក្នុងប្រទេសកម្ពុជា ...............................២៨
៣.៥ គុណសម្បត្តិ និងគុណវិបត្តិនៃការវិនិយោគផ្ទាល់ពីបរទេស (FDI) ...........................................៣៤
៣.៥.១ គុណសម្បត្តិ......................................................................................................៣៤
៣.៥.២ គុណវិបត្តិ .........................................................................................................៣៥
៣.៦ បញ្ហាប្រឈម.............................................................................................................៣៥
៣.៦.១ កង្វះខាតហេដ្ឋារចនាសម្ព័ន្ធ.....................................................................................៣៥
៣.៦.២ កង្វះសមត្ថភាពធនធានមនុស្ស ................................................................................៣៦
៣.៦.៣ ប្រព័ន្ធហិរញ្ញវត្ថុ ..................................................................................................៣៦
៣.៦.៤ ជម្លោះដីសម្បទាន................................................................................................ ៣៧
៣.៦.៥ បញ្ហារបន្ទាប់បន្សំ ................................................................................................ ៣៧
៣.៧ ដំណោះស្រាយ............................................................................................................៣៨
៣.៧.១ កំណែទម្រង់រដ្ឋបាល និងស្ថាប័ន...............................................................................៣៨
៣.៧.២ កាត់បន្ថយអំពើពុករលួយ.......................................................................................៣៩
៣.៧.៣ ការកសាង និងអភិវឌ្ឍន៍ធនធានមនុស្ស.......................................................................៣៩
៣.៧.៤ ការពង្រឹង និងពង្រីកវិសាលភាពវិស័យហិរញ្ញវត្ថុ...........................................................៣៩
៣.៧.៥ ការបន្តស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត......................................................... ៤០
៣.៧.៦ ការលើកស្ទួយវិស័យកសិកម្ម ................................................................................. ៤០

## ជំពូកទី៤

## ការសិក្សាអំពីវិសមភាពនៃប្រាក់ចំណូល


៤.១ សេចក្តីផ្តើម....................................................................................................................................៤២

៤.២ និយមន័យវិសមភាពនៃប្រាក់ចំណូល.............................................................................................៤២

៤.៣ មេគុណ GINI និងវិធានការសរុបនៃវិសមភាព.................................................................................៤៣

៤.៣.១ សម្មតិកម្ម KUZNETS (១៩៥៥) .......................................................................................... ៤៤

៤.៤ បញ្ហា និងដំណោះស្រាយជុំវិញវិសមភាពនៃប្រាក់ចំណូល ................................................................... ៤៨

៤.៤.១ បញ្ហាប្រឈម ........................................................................................................................ ៤៨

៤.៤.២ ដំណោះស្រាយ .......................................................................................................................៥២


## ជំពូកទី៥

## ទំនាក់ទំនងរវាង (FDI) និងការកាត់បន្ថយវិសមភាពនៃប្រាក់ចំណូលៈ ករណីសិក្សាប្រទេសកម្ពុជា


៥.១ សេចក្តីផ្តើម.................................................................................................................................... ៥៤

៥.២ FDI បានជម្រុញដល់ការកាត់បន្ថយវិសមភាពនៃប្រាក់ចំណូលក្នុងប្រទេសកម្ពុជា ...................... ៥៤

៥.២.១ វិស័យកាត់ដេរសម្លៀកបំពាក់ ............................................................................................... ៥៦

៥.២.២ FDI ជម្រុញដល់កំណើន GDP និងការកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសកម្ពុជា............ ៥៩


## ជំពូកទី៦

## ការពិភាក្សា សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍


៦.១ ការពិភាក្សា.................................................................................................................................... ៦៥

៦.២ សេចក្តីសន្និដ្ឋាន ...............................................................................................................................៦៦

៦.៣ ការផ្តល់អនុសាសន៍ ...........................................................................................................................៦៧

**ឯកសារយោង**

**បញ្ជីឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

- FDI ៖  Foreign Direct Investment (ការវិនិយោគផ្ទាល់ពីបរទេស)
- NBC៖ National Bank of Cambodia (ធនាគារជាតិនៃកម្ពុជា)
- ADB៖ Asian Development Bank (ធនាគារអភិវឌ្ឍន៍អាស៊ី)
- OECD៖ Organization for Economic Cooperation and Development (អង្គការសម្រាប់សហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍)
- IMF៖ International Monetary Fund (មូលនិធិរូបិយវត្ថុអន្តរជាតិ)
- GDP៖ Gross Domestic Product (ផលិតផលក្នុងស្រុកសរុប ឬហៅកាត់ថា ផ.ស.ស)
- CDC៖ Community Development Center (មជ្ឈមណ្ឌលអភិវឌ្ឍន៍សហគមន៍)
- QIP៖ Qualified Institutional Placemen (គម្រោងវិនិយោគ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់)
- គ.ល.គ៖ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់
- WHO៖ World Health Organization (អង្គការសុខភាពពិភពលោក)
- GNI៖ Gross National Income (ចំណូលជាតិសរុប)
- WTO៖ World Trade Organization (អង្គការពាណិជ្ជកម្មពិភពលោក)។

# បញ្ជីតារាង

**ទំព័រ**

តារាងទី១៖ ចំនួន និងចំណាត់ថ្នាក់នៃរោងចក្ររវាងឆ្នាំ១៩៥៥ ដល់ ១៩៦៨ ........................................ ១១
តារាងទី២៖ វិស័យភាគហ៊ុននៃផលិតផលក្នុងស្រុកសរុបនៅឆ្នាំ១៩៦៦ គិតជាភាគរយ.......................... ១២
តារាងទី៣៖ ផលិតកម្មកសិកម្មរាប់សែនតោនក្នុងឆ្នាំ១៩៦៨ ដល់ ១៩៧៤ ........................................ ១៣
តារាងទី៤៖ កំណើន GDP ពិតប្រាកដ និងចំណែកនៃ GDP រវាងឆ្នាំ១៩៨៨ ដល់ ១៩៩២.................... ១៥
តារាងទី៥៖ អត្រាអតិផរណាឆ្នាំ១៩៨៩ ដល់ ១៩៩២ ................................................................... ១៦
តារាងទី៦៖ ការវិនិយោគតាមប្រទេស (ភាគហ៊ុន) និង (លំហូរ)...................................................... ២៩
តារាងទី៧៖ ការវិនិយោគតាមវិស័យ (ភាគហ៊ុន) និង (លំហូរ) គិតជាលានដុល្លារ................................. ៣០
តារាងទី៨៖ ការប៉ាន់ស្មានការចែកចាយប្រាក់ចំណូលតាមបណ្តាប្រទេសនីមួយៗ ត្រូវបានជ្រើសរើស ....... ៤៥
តារាងទី៩៖ ប្រាក់ចំណូល និងវិសមភាពនៅក្នុងបណ្តាប្រទេសនីមួយៗ ត្រូវបានជ្រើសរើស...................... ៤៦
តារាងទី១០៖ របាយការណ៍ចំនួននិយោជិតធ្វើការក្នុងវិស័យនីមួយៗនៅចុងឆ្នាំ២០១៤.......................... ៥៥
តារាងទី១១៖ ចំនួនរោងចក្រ និងនិយោជិតក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ឆ្នាំ២០១៤ ......................... ៥៧
តារាងទី១២៖ ការនាំចេញ និងការនាំចូលសម្លៀកបំពាក់ឆ្នាំ២០១០ ដល់ ២០១៤ ................................ ៥៨
តារាងទី១៣៖ ទិន្នន័យពិពណ៌នាអំពីអថេរនីមួយៗនៅចន្លោះឆ្នាំ១៩៨០ ដល់ ២០១៤........................... ៦២
តារាងទី១៤៖ ប្រាក់ឈ្នួលពលកម្មផ្នែកវាយនភណ្ឌកាត់ដេរសម្លៀកបំពាក់... និងសំណង់ ....................... ៦៣

# បញ្ជីក្រាហ្វិក

**ទំព័រ**


ក្រាហ្វិកទី១៖  ការប៉ាន់ស្មានតាមរយៈមេគុណ GINI ........................................ ៤៣

ក្រាហ្វិកទី២៖ ខ្សែកោង Kuznets (Inverted-U) ........................................ ៤៤

ក្រាហ្វិកទី៣៖ កំណើនសេដ្ឋកិច្ចរយៈពេលវែង និងវិសមភាពនៃប្រាក់ចំណូល ........................................ ៤៧

ក្រាហ្វិកទី៤៖ បញ្ហាសុខភាព និងសង្គមកាន់តែអាក្រក់ទៅៗនៅក្នុងប្រទេស ដែលមិនស្មើគ្នា ........................................ ៥០

ក្រាហ្វិកទី៥៖ សមាមាត្រនៃភាគហ៊ុន FDI ទៅជា GDP (ក្នុងលោកាវិត) ........................................ ៥៩

ក្រាហ្វិកទី៦៖ GDP ពិតប្រាកដនៅក្នុងមនុស្សម្នាក់ៗ ........................................ ៦០

ក្រាហ្វិកទី៧៖ កំណើន GDP ពិតប្រាកដ (អត្រាប្រចាំឆ្នាំគិតជាភាគរយ) ........................................ ៦១

# ជំពូកទី១
# សេចក្ដីផ្ដើម

## ១.១ សេចក្ដីផ្ដើម

ក្រឡេកមកមើលនៅក្នុងពិភពលោកយើងបច្ចុប្បន្ននេះ ការវិនិយោគផ្ទាល់ពីបរទេស (FDI) បាននឹងកំពុងក្លាយជាលំហូរសេដ្ឋកិច្ចដ៏សំខាន់បំផុតមួយនៅក្នុងសេដ្ឋកិច្ចពិភពលោក។[1] វាគឺជាប្រភពដើមទុនដ៏សំខាន់សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ ហើយនៅតែជាប្រភពនៃការវិនិយោគដ៏សំខាន់នៅក្នុងប្រទេសអភិវឌ្ឍន៍ដោយមិនអាចខ្វះបានឡើយ។ ការវិនិយោគផ្ទាល់ពីបរទេស (FDI) បានរីកចម្រើនមួយផ្នែកធំនោះគឺ ដោយសារតែប្រទេសនានានៅលើពិភពលោក បានផ្លាស់ប្ដូរគោលនយោបាយរបស់ពួកគេបាញ់ឆ្ពោះទៅរកការវិនិយោគបែបសកលពីបណ្ដាប្រទេសទាំងអស់នៅលើពិភពលោក ដែលមានសកម្មភាពយ៉ាងខ្លាំងបន្ទាប់ពីទសវត្សរ៍ឆ្នាំ1980 ។ នៅក្នុងនោះដែរ រដ្ឋាភិបាលក្នុងប្រទេសកំពុងអភិវឌ្ឍន៍បានធ្វើការផ្លាស់ប្ដូរគោលនយោបាយឯកតោភាគី ដែលបានបើកទីផ្សារនៅទូទាំងពិភពលោក និងការកើនឡើងបន្ថែមនៃការប្រកួតប្រជែងក្នុងចំណោមប្រទេសទាំងអស់នៅលើពិភពលោកសម្រាប់ការវិនិយោគផ្ទាល់ពីបរទេស។

ម្យ៉ាងវិញទៀតបើក្រឡេកមកមើលនៅក្នុងប្រទេសកម្ពុជាយើងវិញម្ដង ការវិនិយោគផ្ទាល់ពីបរទេស (FDI) ពិតជាដើរតួនាទីយ៉ាងសំខាន់ណាស់នៅក្នុងការធ្វើឲ្យប្រសើរឡើងនៃការអភិវឌ្ឍនៅក្នុងប្រទេសដូចជាជួយបង្កើននូវទំហំសេដ្ឋកិច្ចនៅក្នុងប្រទេស ការកើនឡើងនៃប្រាក់ចំណូលរបស់ប្រជាជន និងជួយបង្កើនការងារទៅដល់ប្រជាពលរដ្ឋផងដែរ ពីព្រោះប្រទេសនេះបានឆ្លងកាត់នូវសោកនាដកម្មជាច្រើនជំនាន់មកហើយ ជាពិសេសរបប ប៉ុល ពត (ខ្មែរក្រហម) ដែលបានបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធស្ទើរតែគ្រប់ប្រភេទ រួមទាំងធនធានមនុស្ស និងជីវិតស្លូតត្រង់ប្រមាណជាងពីរលាននាក់។

សរុបមកដោយសារកង្វះទុនក្នុងស្រុកសម្រាប់ពង្រឹងកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍ ការវិនិយោគផ្ទាល់ពីបរទេស (FDI) គឺជាមូលធនបរទេសចម្បង ដែលពិតជាមានសារៈប្រយោជន៍ និងមានសារៈសំខាន់ណាស់ចំពោះគោលដៅនៃការជួយដល់ប្រជាជននៅក្នុងស្រុកឲ្យមានការងារធ្វើ ដើម្បីមានឱកាសទទួលបាននូវប្រាក់ចំណូលខ្ពស់ដល់ប្រជាជនក្នុងស្រុក ជាពិសេសគឺជួយកាត់បន្ថយនូវវិសមភាពនៃប្រាក់ចំណូលថែមទៀត

[1] *Introduction the Global Economy, FDI, and the Regime for Investment*. By Helen V. Milner *downloaded on 30 April 2022 at 5:00PM*. https://scholar.princeton.edu/sites/default/files/hvmilner/files/hvm_wp_2014.pdf

ផង។ ក្នុងនោះដែរដើម្បីទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស កម្ពុជាបានធ្វើកំណែទម្រង់សេដ្ឋកិច្ចដ៏ធំមួយដោយផ្លាស់ប្តូរពីសេដ្ឋកិច្ចផែនការ ទៅជាសេដ្ឋកិច្ចទីផ្សារសេរីរហូតមកដល់ពេលបច្ចុប្បន្ននេះ។[2]

## ១.២ ចំណោទបញ្ហា និងសំណួរនៃការស្រាវជ្រាវ

ក្រោយការងើបឡើងនៃសន្ទស្សន៍សេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា ដែលបានប្រែក្លាយខ្លួនជាប្រទេសដែលមានកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស ពីប្រទេសដែលមានចំណូលទាបទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាបនៅក្នុងឆ្នាំ2015 ហើយអាចនឹងចាកផុតពីប្រទេសអភិវឌ្ឍន៍តិចតួចក្នុងរយៈពេលត្រឹមតែមួយទសវត្សរ៍។[3] ទោះបីប្រទេសកម្ពុជាបានប្រែក្លាយខ្លួនទៅជាប្រទេស ដែលមានកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័សបែបនេះក៏ដោយ ក៏ប៉ុន្តែបញ្ហាមួយចំនួន ដែលជាកត្តារាំងស្ទះដល់ការអភិវឌ្ឍប្រទេសនៅតែកើតមានឡើងនៅគ្រប់វិស័យ ដែលសម្រេចចិត្តឲ្យប្រទេសកម្ពុជាត្រូវតែបង្កើនការយកចិត្តទុកដាក់ក្នុងការប្រឈមទៅនឹងបញ្ហានៅលើវិស័យសំខាន់ៗមួយចំនួនដូចជា វិស័យអប់រំ វិស័យឧស្សាហកម្ម វិស័យកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងវិស័យធារាសាស្ត្រផងដែរ។ ដើម្បីជាចលករមួយក្នុងការជម្រុញនូវកំណើនសេដ្ឋកិច្ច និងដោះស្រាយនូវបញ្ហាប្រឈមទាំងអស់នេះ កម្ពុជាត្រូវពឹងផ្អែកការវិនិយោគពីបរទេស (FDI) ជាចាំបាច់បំផុតនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចបានយ៉ាងជោគជ័យ ជាពិសេសជួយជម្រុញដល់ការកាត់បន្ថយនូវវិសមភាពនៃប្រាក់ចំណូលរបស់ប្រជាជននៅក្នុងប្រទេសកម្ពុជា។

ហេតុដូច្នេះ ឆ្លងតាមការសង្កេត និងវាយតម្លៃទៅលើអត្ថប្រយោជន៍នៃការវិនិយោគពីបរទេស (FDI) មកលើប្រទេសកម្ពុជា ដែលបង្កើតបានជាចំណោទបញ្ហាក្នុងការសិក្សាស្រាវជ្រាវប្រធានបទសារណាមួយនេះឡើង។ ទាក់ទងអំពីចំណោទបញ្ហានៅក្នុងប្រធានបទនេះដែរ ក៏បានលេចចេញនូវសំណួរមួយចំនួន ដែលជាមាគ៌ាមួយសម្រាប់ជាគំនិតឲ្យយើងធ្វើការសិក្សាបន្តផងដែរ ដែលសំណួរទាំងនោះរួមមាន៖

- តើការវិនិយោគផ្ទាល់ពីបរទេសមានឥទ្ធិពលយ៉ាងណាមកលើកំណើនសេដ្ឋកិច្ចប្រទេសកម្ពុជា?
- តើការឈានជើងចូលមកវិនិយោគពីបណ្តាក្រុមហ៊ុនបរទេសប្រព្រឹត្តទៅដោយរបៀបណា?

---

[2] *ដកស្រង់អត្ថបទពី៖* Seng Sothan (2017) *បុព្វហេតុរវាងការវិនិយោគផ្ទាល់ពីបរទេស និងកំណើនសេដ្ឋកិច្ចសម្រាប់ប្រទេសកម្ពុជា Cogent Economics & Finance អត្ថបទ PDF ជាភាសាអង់គ្លេសដែលមានចំណងជើងថា Causality between foreign direct investment and economic growth for Cambodia ។ បានទាញយកនៅថ្ងៃទី30 ខែមេសា ឆ្នាំ2022 ម៉ោង6:00 ល្ងាច។* https://www.tandfonline.com/doi/pdf/10.1080/23322039.2016.1277860

[3] *ដកស្រង់អត្ថបទពី៖ អង្គការទិន្នន័យអំពីការអភិវឌ្ឍ ដែលប្រធាបទនិយាយអំពី គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅក្នុងប្រទេសកម្ពុជា។ បានទាញយកនៅថ្ងៃទី05 ខែឧសភា ឆ្នាំ2022 ម៉ោង7:00 ល្ងាច។* https://opendevelopmentcambodia.net/km/topics/sustainable-development-goals/#ref-115279-12

- តើហេតុអ្វីបានជាការវិនិយោគផ្ទាល់ពីបរទេសជួយបង្កើតនូវចំណូល និងការងារដល់ប្រជាជននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសនៅក្នុងប្រទេសកម្ពុជា?
- តើហេតុអ្វីបានជាគេលើកឡើងថា ការវិនិយោគពីបរទេស (FDI) មានឥទ្ធិពលមកលើវិសមភាពនៃប្រាក់ចំណូលរបស់ប្រជាជននៅក្នុងប្រទេសកម្ពុជា?

## ១.៣ វត្ថុបំណងនៃការសិក្សាស្រាវជ្រាវ

តាមរយៈការបកស្រាយប្រធានបទសារណា ខាងលើនេះនឹងបង្ហាញឲ្យយើងមើលឃើញកាន់តែច្បាស់អំពីគោលបំណងសំខាន់ៗមួយចំនួន ដែលបានបង្កប់នៅក្នុងខ្លឹមសារអត្ថបទ។ គោលបំណងនៃការសិក្សាប្រធានមួយនេះ គឺដើម្បីបកស្រាយពន្យល់អំពីអត្ថប្រយោជន៍នៃការឈានជើងចូលវិនិយោគពីក្រុមហ៊ុនបរទេសមកកាន់ប្រទេសកម្ពុជា និងសិក្សាអំពីឥទ្ធិពលនៃការវិនិយោគផ្ទាល់ពីបរទេសទៅលើវិសមភាពនៃប្រាក់ចំណូលរបស់ប្រជាជន ជាពិសេសគឺជួយដល់ការវិភាគផ្សេងៗទៀត ដើម្បីធ្វើយ៉ាងណាឲ្យមានសមភាពក្នុងការអភិវឌ្ឍន៍នៅទីជនបទ និងទីក្រុង។ គោលបំណងចម្បងនៃការសិក្សា គឺដើម្បីប្រមូលទិន្នន័យអំពីលំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេសនៅក្នុងប្រទេសកម្ពុជា នៅបណ្ដាដំណាច់ឆ្នាំនីមួយៗ ដើម្បីសម្រួលដល់ការចងក្រងស្ថិតិជញ្ជីងទូទាត់ និងស្ថានភាពវិនិយោគអន្តរជាតិ ក៏ដូចជាដើម្បីផ្ដល់នូវទិន្នន័យសមស្របមួយដល់ការរៀបចំចងក្រងជាឯកសារមួយនេះឡើង។

ម្យ៉ាងវិញទៀតតាមរយៈការសិក្សាអំពីប្រធានបទនេះ ក៏ជួយបង្ហាញដល់មិត្តអ្នកអានឲ្យយល់ដឹងកាន់តែច្បាស់ពីដំណើរការ និងលក្ខខណ្ឌមួយចំនួននៃការវិនិយោគជាពិសេស គឺយុទ្ធសាស្ត្រក្នុងការទាក់ទាញអ្នកវិនិយោគពីខាងក្រៅប្រទេស ដើម្បីឲ្យមកវិនិយោគនៅក្នុងប្រទេសកម្ពុជា។ ដោយមានការបណ្ដុះបណ្ដាលទាំងចំណេះដឹង និងជំនាញផ្សេងៗដល់ប្រជាជន ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ ដែលក្រុមហ៊ុនវិនិយោគផ្ទាល់ពីបរទេសបានបោះទីតាំងនៅក្នុងប្រទេសកម្ពុជា។ លើសពីនេះទៅទៀត គឺដើម្បីផ្សារភ្ជាប់នូវចរន្តលំហូរសេដ្ឋកិច្ចឲ្យមានលក្ខណៈល្អប្រសើ ដែលជាផ្នែកមួយជួយដល់ការអភិវឌ្ឍ និងបង្កើនប្រាក់ចំណូលបន្ថែមដល់ប្រជាពលរដ្ឋគ្រប់តំបន់នៅទូទាំងប្រទេស ពោលក្នុងន័យជួយកាត់បន្ថយនូវគម្លាតចំណូលរបស់ប្រជាជន។

កត្តាសំខាន់ចុងក្រោយមួយទៀត គឺវិភាគបកស្រាយអំពីឥទ្ធិពលនៃការវិនិយោគផ្ទាល់ពីបរទេសមកលើសេដ្ឋកិច្ចប្រទេសកម្ពុជា ដែលឥទ្ធិពលទាំងអស់នោះមានទាំងផលវិជ្ជមាន និងអវិជ្ជមានផងដែរ។ ការវិនិយោគផ្ទាល់ពីបរទេស (FDI) មិនសុទ្ធតែទទួលបាននូវផលចំណេញទាំងអស់នោះទេ ដែលពេលខ្លះវាក៏អាចធ្វើឲ្យយើងទទួលរងនូវការខាតបង់ផងដែរប្រសិនបើយើងមិនបានសិក្សាឲ្យបានច្បាស់លាស់ អំពីទីតាំងភូមិសាស្ត្រ សេដ្ឋកិច្ចប្រជាជន និងវប្បធម៌។

## ១.៤ វិសាលភាពនៃការសិក្សាស្រាវជ្រាវ

ប្រទេសកម្ពុជាបានចាប់ផ្ដើមមានការរីកចម្រើនខាងផ្នែកសេដ្ឋកិច្ច និងបានបើកចំហពេញលេញនូវការវិនិយោគផ្ទាល់ពីបរទេសឡើងវិញចាប់ពីឆ្នាំ1993 ឬក្រោយការបោះឆ្នោតជាលើកដំបូងនៅក្នុងប្រទេសកម្ពុជា ដូច្នេះការសិក្សាស្រាវជ្រាវអំពីទំនាក់ទំនងរវាងការវិនិយោគផ្ទាល់ពីបរទេស និងការកាត់បន្ថយវិសមភាពនៃប្រាក់ចំណូលៈ ករណីសិក្សាប្រទេសកម្ពុជា ដោយក្នុងដំណើរការស្រាវជ្រាវនេះផងដែរ យើងនឹងបកស្រាយពន្យល់ជាប្រភេទអត្ថបទសម្រាយ បូករួមជាមួយទិន្នន័យជាតារាង Excel និងក្រាហ្វិក ដែលគិតចាប់ផ្ដើមយកពីឆ្នាំ1993 នេះតែម្ដង។ ចំណែកឯការសិក្សាស្រាវជ្រាវឆ្នាំចុងក្រោយ យើងនឹងគិតយកត្រឹមឆ្នាំ2020 ដោយយោងទៅលើហេតុផលនៃភាពជាក់លាក់ច្បាស់លាស់នៅចន្លោះឆ្នាំទាំងពីរនេះ(1993 ដល់ 2020) ជាពិសេសគឺក្រោយការកើតឡើងនូវជំងឺរាតត្បាត Covid-19 ដែលធ្វើឲ្យសកលលោក ក៏ដូចជាប្រទេសកម្ពុជាមិនអាចកំណត់នូវទិន្នន័យច្បាស់លាស់ពេញលេញបាន។

## ១.៥ សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ជាទូទៅនៅក្នុងការសិក្សាស្រាវជ្រាវប្រធានបទនីមួយៗ អ្នកសរសេរតែងតែបង្ហាញអំពីសារៈសំខាន់ផ្សេងៗ ដើម្បីជាគន្លឹះមួយជួយដល់មិត្តអ្នកអានឲ្យឆាប់យល់ដឹង និងសិក្សាកាន់តែស៊ីជម្រៅបន្ថែមទៀតទៅលើប្រធានបទទាំងអស់នោះ។ មិនខុសគ្នាពីប្រធានបទដ៏ទៃទៀតដែរ ទំនាក់ទំនងរវាងការវិនិយោគផ្ទាល់ពីបរទេស និងការកាត់បន្ថយវិសមភាពនៃប្រាក់ចំណូលៈ ករណីសិក្សាប្រទេសកម្ពុជា ក៏បានផ្ដល់នូវសារៈសំខាន់ជាច្រើនទៅកាន់មិត្តអ្នកអាន ក៏ដូចជាអ្នកស្រាវជ្រាវទាំងអស់ ដែលកំពុងតែសិក្សាពីប្រធានបទនេះ។ ការសិក្សានេះផងដែរគឺជាជ្រុងមួយក្នុងការកំណត់នូវភាពប្រសើរឡើងនៃការវិនិយោគផ្ទាល់ពីបរទេស ព្រមទាំងបង្ហាញនូវប្រភេទនៃការវិនិយោគផ្សេងៗ ដើម្បីជាទុនមួយក្នុងការវិភាគឲ្យបានស៊ីជម្រៅទៅលើស្ថានភាពប្រទេសកម្ពុជាយើងបច្ចុប្បន្ន ដោយធ្វើការសម្រេចចិត្តជ្រើសរើសការវិនិយោគបែបណា ដែលសមស្របទៅនឹងទីតាំងភូមិសាស្ត្រ ប្រជាករ និងរចនាសម្ព័ន្ធប្រជាសាស្ត្រនៅក្នុងប្រទេសកម្ពុជា។

ម្យ៉ាងវិញទៀត ការសិក្សាមួយនេះបានផ្ដល់នូវចំណេះដឹងបន្ថែមដល់មិត្តអ្នកអាន ក៏ដូចជាអ្នកសិក្សាស្រាវជ្រាវ អំពីឥទ្ធិពលនៃការវិនិយោគផ្ទាល់ពីបរទេសមកលើវិសមភាពនៃប្រាក់ចំណូល ដោយការវិនិយោគផ្ទាល់ពីបរទេស (FDI) បានប្រែក្លាយចំណូលរបស់ប្រជាជនឲ្យខិតជិតមករកគ្នា ពោលគឺជួយបង្កើតការងារដល់ប្រជាជននៅតាមតំបន់ជនបទ និងទីក្រុង ដែលធ្វើយ៉ាងណាឲ្យពួកគេទទួលបាននូវប្រាក់ចំណូលដូចគ្នា ជាពិសេសជួយកាត់បន្ថយវិសមភាពនៃប្រាក់ចំណូលនៅក្នុងប្រទេសកម្ពុជាផងដែរ។

បន្ថែមពីលើនេះទៅទៀត ការសិក្សាស្រាវជ្រាវមួយនេះ ក៏ជាផ្នែកមួយក្នុងការជួយបង្ហាញជាគំនិតទៅដល់ស្ថាប័នដែលពាក់ព័ន្ធក្នុងការរៀបចំយុទ្ធសាស្ត្រ និងនយោបាយសេដ្ឋកិច្ចផ្សេងៗ ដើម្បីអាចឲ្យប្រទេសកម្ពុជាក្លាយជាប្រទេស ដែលមានសក្តានុពលក្នុងការទាក់ទាញការវិនិយោគផ្ទាល់ពីបរទេសឲ្យកាន់តែច្រើន។

## ១.៦ រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ

ក្នុងដំណើរការនៃការសិក្សាស្រាវជ្រាវប្រធានបទសារណាមួយនេះត្រូវបានបែងចែកជា ៦ ជំពូក។ ជំពូកទី១ "សេចក្តីផ្តើម" ដោយនិយាយអំពីសញ្ញាណទូទៅជុំវិញប្រធានបទ ដែលមានដូចជា ចំណោទបញ្ហា គោលបំណងនៃការសិក្សាស្រាវជ្រាវ បូករួមជាមួយវិសាលភាព និងសារៈសំខាន់នៃការសិក្សាស្រាវជ្រាវ។ ចំណែកឯជំពូកទី២ "វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ" នៅក្នុងចំណុចនេះផងដែរ យើងបានលើកយកនូវទ្រឹស្តី ឬក្របខណ្ឌគំនិតដែលត្រូវប្រើ ជាពិសេស គឺការប្រើប្រាស់នូវទិន្នន័យដែលមានស្រាប់ពីគេហទំព័រធំៗ ដូចជាសហគ្រាសរដ្ឋ និងឯកជន ដែលអាចជឿទុកចិត្តបាន ដើម្បីយកមកវិភាគបង្កើតបានលទ្ធផលនៃការសិក្សាស្រាវជ្រាវ។ រីឯជំពូកទី៣ "ការវិនិយោគផ្ទាល់ពីបរទេស (FDI) នៅក្នុងប្រទេសកម្ពុជា" ដែលបានបង្ហាញពីប្រវត្តិនៃការវិនិយោគនៅកម្ពុជា ក៏ដូចជាមូលដ្ឋានគ្រឹះទាក់ទងជាមួយការវិនិយោគផ្ទាល់ពីបរទេស (FDI) ។ លើសពីនេះទៅទៀត នៅក្នុងជំពូកនេះផងដែរនឹងពន្យល់យើងអំពីផលចំណេញដែលទទួលបានពីការវិនិយោគផ្ទាល់ពីប្រទេស (FDI) នៅក្នុងសេដ្ឋកិច្ចប្រទេសកម្ពុជា។ ជំពូកទី៤ "ការសិក្សាអំពីវិសមភាពនៃប្រាក់ចំណូល" បានបង្ហាញឲ្យយើងមើលឃើញថា គម្លាតចំណូល គឺជាបញ្ហាមួយសម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅក្នុងប្រទេស បន្ថែមពីលើនេះទៅទៀត យើងនឹងយកបញ្ហាទាំងអស់នេះយកមកវិភាគ ដើម្បីរកដំណោះស្រាយ និងការកាត់បន្ថយវិសមភាពនៃប្រាក់ចំណូលរបស់ប្រជាជន។ លើសពីនេះទៅទៀត យើងនឹងយក មេគុណ Gini យកមកបកស្រាយ ក៏ដូចជាបានបង្ហាញតាមរយៈទ្រឹស្តីរបស់ Kuznets (1955) ។ ចំណែកឯជំពូកទី៥ "ទំនាក់ទំនងរវាងការវិនិយោគផ្ទាល់ពីបរទេស (FDI) និងការកាត់បន្ថយវិសមភាពនៃប្រាក់ចំណូល៖ ករណីសិក្សាប្រទេសកម្ពុជា" ដែលជាចំណុចសំខាន់ជាងគេនៅក្នុងប្រធានបទសារណានេះ ដោយបានបកស្រាយពន្យល់អំពីវិសមភាពនៃប្រាក់ចំណូលត្រូវបានកាត់បន្ថយនៅពេលដែលមានវត្តមាននៃការវិនិយោគផ្ទាល់ពីបរទេស (FDI)។ ជំពូកទី៦ "ការពិភាក្សា ការផ្តល់អនុសាសន៍ និងសេចក្តីសន្និដ្ឋាន" នៅក្នុងចំណុចនេះដែរ គឺជាចំណុចចុងក្រោយ ដែលយើងនឹងធ្វើការពិភាក្សាវែកញែកអំពីទិដ្ឋភាពជាក់ស្តែងនៃប្រធានបទទាំងមូល បន្ទាប់មកធ្វើសេចក្តីសន្និដ្ឋាន។

# ជំពូកទី២
# វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

## ២.១ សេចក្តីផ្តើម

តាមរយៈដំណើរការនៃការសិក្សាស្រាវជ្រាវនេះផងដែរ យើងបានប្រើប្រាស់នូវវិធីសាស្ត្រប្រមូលទិន្នន័យ ដែលបានបោះពុម្ពផ្សាយជាសាធារណៈ ទាំងភាសាខ្មែរ និងភាសាបរទេស។ ការសិក្សាស្រាវជ្រាវនៅក្នុងបណ្ណាល័យពីកិច្ចការស្រាវជ្រាវ និងកម្រងសារណារបស់និស្សិតជំនាន់មុនៗ។ លើសពីនេះទៅទៀត បានដកស្រង់ឯកសារតាមរយៈគេហទំព័រមួយចំនួន ដែលទាក់ទងទៅនឹងទិន្នន័យនៃការវិនិយោគ ក៏ដូចជាកម្រិតចំណូលរបស់ប្រជាជននៅក្នុងបណ្តាប្រទេសផ្សេងៗនៅក្នុងពិភពលោក ជាពិសេសនៅក្នុងប្រទេសកម្ពុជា។

## ២.២ ការពិនិត្យទៅលើឯកសារយោងដែលពាក់ព័ន្ធ

ដើម្បីជាមាគ៌ាមួយក្នុងការចងក្រងឯកសារស្រាវជ្រាវមួយនេះឡើង យើងខ្ញុំត្រូវការទិន្នន័យនានាដែលទាក់ទងទៅនឹងចំណោទបញ្ហាខាងលើ ដើម្បីយកមកដាក់រួមបញ្ចូលគ្នា ដោយបង្កើតបានជាប្រភពឯកសារក្នុងការវិភាគ។ យើងខ្ញុំបានជ្រើសរើសនូវប្រភេទទិន្នន័យកម្រិត២ (Secondary Data) ដែលបកប្រែពីខ្លឹមសារអត្ថបទដើមទាំងស្រុង ពោលចម្លងអត្ថបទដើមឡើងវិញ និងមានការដាក់បញ្ចូលបន្ថែមនៃការយល់ឃើញខ្លះៗនៅក្នុងអត្ថបទផ្ទាល់។ ទិន្នន័យដូចបានរៀបរាប់ខាងលើនេះ អាចរកបាននូវតាមស្ថាប័នពាក់ព័ន្ធដូចជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា (NBC) ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ធនាគារពិភពលោក (World Bank) អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ និងអង្គការសម្រាប់សហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (OECD) រួមមានការចេញផ្សាយ ជារបាយការណ៍ ជាសៀវភៅ ជាឯកសារចងក្រង និងការបង្ហាញលើគេហទំព័រជាដើម។

## ២.៣ ការវិភាគទិន្នន័យ

ឆ្លងតាមរយៈការសិក្សាលើប្រភេទនៃទ្រឹស្តី និងវិធីសាស្ត្រ ដែលសិក្សាលើទំនាក់ទំនងរវាងអថេរពីរ ឬច្រើន ក៏ដូចជាការស្វែងយល់ទៅលើឯកសារស្រាវជ្រាវដែលធ្លាប់បានធ្វើកន្លងមក យើងបានប្រើប្រាស់នូវការវិភាគតាមរយៈ Excel ដោយបានស្រង់នូវតួលេខនៅក្នុងទិន្នន័យពីឆ្នាំនីមួយៗ ដើម្បីយកមកបង្កើតជាតារាងតុល្យការ បន្ទាប់មកធ្វើការប្រៀបធៀប ដោយយោងទៅលើការវិភាគតាមគំរូសមហេតុផល ដែលមានកត្តាសំខាន់បី ដូចជា Input (មុខចូល ជាទិន្នន័យ ឬព័ត៌មានជាលេខ) Processing (ដំណើរការវិភាគ ជាវិធីបរិមាណ ឬវិធីគុណភាព) និងចុងក្រោយគឺ Output (ទិន្នផលនៃការប្រែប្រួលបរិមាណ ឬការប្រែប្រួលគុណភាព)។ ដោយមើលពីភាពជាក់ស្តែង ក៏ដូចជាមានអំណះអំណាងក្នុងការស្រាវជ្រាវជាច្រើន ដែលបង្ហាញឲ្យឃើញថា ការវិនិយោគផ្ទាល់ពីបរទេស (FDI) គឺជា Input សេដ្ឋកិច្ចមួយ ដែលបានរួមចំណែកក្នុងលទ្ធផល Output សេដ្ឋកិច្ច និងប្រាក់

ចំណូល។ ដូចនេះការធ្វើតេស្តរកទំនាក់ទំនងរវាងអថេរទាំងពីរ ដោយបានធ្វើការកំណត់យកការវិនិយោគផ្ទាល់ពីបរទេស ជាថេរឯករាជ្យ ហើយរាល់បម្រែបម្រួលការវិនិយោគផ្ទាល់ពីបរទេស នឹងមានឥទ្ធិពលលើប្រាក់ចំណូលរបស់ប្រជាជននៅក្នុងប្រទេសកម្ពុជានេះតែម្តង។ ជាចុងក្រោយនេះផងដែរ យើងនឹងអាចមើលឃើញអំពីទំនាក់ទំនងរវាងការវិនិយោគផ្ទាល់ពីបរទេស និងការកាត់បន្ថយវិសមភាពនៃប្រាក់ចំណូល ហើយលទ្ធផលនៃការធ្វើទំនាក់ទំនងនេះអាចឲ្យយើងយល់ដឹង និងត្រៀមលក្ខណៈបែបណាចំពោះឥទ្ធិពលពីការវិនិយោគផ្ទាល់ពីបរទេស (FDI) មកលើសេដ្ឋកិច្ច និងចំណូលរបស់ប្រជាជននៅក្នុងប្រទេសកម្ពុជា។

## ២.៤ ការរំពឹងទុក និងលទ្ធផលទទួលបាន

បន្ទាប់ពីបានជ្រើសរើសនូវវិធីសាស្រ្តស្រាវជ្រាវខាងលើនេះ ដើម្បីបញ្ចប់ការសរសេរសារណា យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា អ្នកស្រាវជ្រាវទាំងអស់នឹងអាចទទួលលបាននូវចំណេះដឹងបន្ថែម អំពីការវិនិយោគផ្ទាល់ពីបរទេស (FDI) ដែលមានឥទ្ធិពលមកលើប្រាក់ចំណូលរបស់ប្រជាជននៅក្នុងប្រទេសកម្ពុជា។ ជាមួយគ្នានេះដែរ យើងខ្ញុំបានដកស្រង់នូវចំណុចសំខាន់ៗទាក់ទងនឹងការវិនិយោគ តាមរយៈការសិក្សាទៅលើគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលកំពុងអនុវត្តន៍ដល់សព្វថ្ងៃ ជាពិសេសស្ថានភាពទូទៅជុំវិញបរិស្ថាននៃការវិនិយោគដើម្បីសម្រួលដល់ចីរភាពកំណើនវិនិយោគផ្ទាល់ពីបរទេសទៅថ្ងៃអនាគត។ ជាងនេះទៅទៀត យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា សៀវភៅនេះនឹងផ្តល់ផលប្រយោជន៍សម្រាប់ជាឯកសារតម្កល់ដល់អ្នកអាន ឬអ្នកស្រាវជ្រាវក្នុងការទទួលបាននូវព័ត៌មាន និងទិន្នន័យទាក់ទងនឹងការវិនិយោគផ្ទាល់ពីបរទេស។

# ជំពូកទី៣

# ការវិនិយោគផ្ទាល់ពីបរទេស (FDI) នៅក្នុងប្រទេសកម្ពុជា

## ៣.១ សេចក្តីផ្តើម

ការវិនិយោគផ្ទាល់ពីបរទេស (FDI) បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការធ្វើឲ្យប្រសើរឡើងនៃការរីកចម្រើននៅក្នុងអាជីវកម្មសកល ជាពិសេសនៅក្នុងប្រទេសកម្ពុជាយើង។[4] អាចផ្តល់ឲ្យក្រុមហ៊ុននូវទីផ្សារថ្មីៗ និងបណ្តាញទីផ្សារថ្មីមួយទៀត ហើយជាកន្លែងផលិត ដែលមានតម្លៃថោកជាងក្នុងប្រទេសដើមកំណើត។ ការដែលទទួលបាននូវបច្ចេកវិទ្យាថ្មីៗ ផលិតផល ជំនាញ និងហិរញ្ញប្បទានផ្សេងៗទៀត។ សម្រាប់ប្រទេសម្ចាស់ផ្ទះ ដែលត្រូវបានក្រុមហ៊ុនបរទេសចូលមកធ្វើការវិនិយោគ អាចផ្តល់នូវប្រភពនៃបច្ចេកវិទ្យាថ្មីៗ ដើមទុនដំណើរការផលិតផល បច្ចេកវិជ្ជារបស់ស្ថាប័ន និងជំនាញគ្រប់គ្រង ដូច្នេះអាចផ្តល់ឥទ្ធិពលខ្លាំងដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

មុននឹងឈានទៅសិក្សាស្រាវជ្រាវអំពីការវិនិយោគដោយផ្ទាល់ពីបរទេសជាបន្ត យើងគប្បីត្រូវយល់អត្ថន័យនៃពាក្យគន្លឹះពីរ គឺប្រទេសដើមកំណើត និង ប្រទេសម្ចាស់ផ្ទះ ដែលវាមានសារៈសំខាន់ណាស់សម្រាប់ការសិក្សា។ ប្រទេសដើមកំណើត សំដៅទៅលើប្រទេសដែលជាប្រភពនៃដើមមូលធនដែលក្រុមហ៊ុនមេ ឬវិនិយោគិនយកទៅធ្វើការវិនិយោគនៅប្រទេសមួយផ្សេងទៀត។ ចំណែកឯប្រទេសម្ចាស់ផ្ទះវិញ គឺជាប្រទេសដែលត្រូវបានមូលធនហូរចូល ហើយមូលធននេះផងដែរត្រូវបានប្រើប្រាស់សម្រាប់ការផលិតផលិតផល ដែលជាទំនិញ ឬសេវាកម្មមិនថាសម្រាប់ផ្គត់ផ្គង់នៅក្នុងប្រទេសនោះ ឬនាំចេញផ្គត់ផ្គង់ទៅក្រៅប្រទេសនោះទេ។[5]

## ៣.២ និយមន័យការវិនិយោគផ្ទាល់ពីបរទេស (FDI)

ការវិនិយោគផ្ទាល់ពីបរទេស (FDI) គឺជាលំហូរកើតមានឡើងនៅពេលដែលសហគ្រាសមួយបានធ្វើការវិនិយោគផ្ទាល់ ដើម្បីផលិតផលិតផល ឬក៏ចែកចាយផលិតផលនៅក្នុងប្រទេសមួយ ឬច្រើនដទៃទៀតក្រៅពីប្រទេសដើមកំណើតរបស់ខ្លួន។[6] លើសពីនេះទៅទៀត យើងអាចនិយាយបានម្យ៉ាងទៀតថា ការវិនិយោគផ្ទាល់ពីបរទេស (FDI) គឺជាការវិនិយោគនៅក្នុងបណ្តាប្រទេសណាមួយ ដោយជនជាតិនៃប្រទេសដទៃដែលបាន

---

[4] *Understanding Foreign Direct Investment (FDI)* Jeffrey P. Graham *and* R. Barry Spaulding. *Downloaded on 15 May 2022 at 6:00PM.* http://www.orintonlawfirm.com/data/artikel/01-Understand%20FDI.pdf

[5] *Difference Between Home and Host Country (2016, November 28). Compare the Difference Between Similar Terms. Downloaded on 15 May 2022 at 6:00PM.* https://www.differencebetween.com/difference-between-home-and-vs-host-country/

[6] *International Business, Foreign Direct Investment, Introduction (Page: 238)*

ធ្វើការវិនិយោគមកក្នុងប្រទេសនោះ។ លំហូរនៃការវិនិយោគផ្ទាល់ពីបរទេស សំដៅទៅលើបរិមាណនៃការវិនិយោគទទួលបាននៅក្នុងរយៈពេលកំណត់មួយក្នុងរូបរាង ជាលំហូរចេញ និងលំហូរចូល ហើយស្តុកនៃការវិនិយោគផ្ទាល់ពីបរទេសវិញ គឺជាតម្លៃសរុបនៃបរិមាណមូលធនដែលមានម្ចាស់កម្មសិទ្ធិជាជនជាតិបរទេស។

ម្យ៉ាងវិញទៀត ប្រសិនបើយោងទៅតាមទ្រឹស្តីរបស់ John J. Wild និង Wild (2016)[7] បានអធិប្បាយថា ការវិនិយោគផ្ទាល់ពីបរទេស គឺជាការប្រើប្រាស់មូលធនពីប្រទេសដើម ដើម្បីបង្កើតសហគ្រាសថ្មី ឬសហការជាមួយសហគ្រាសក្នុងស្រុក នៅក្នុងប្រទេសម្ចាស់ផ្ទះ ដែលអនុញ្ញាតឲ្យវិនិយោគិននោះទទួលបាននូវភាពជាម្ចាស់សិទ្ធិដែលមានអំណាចក្នុងការគ្រប់គ្រងត្រួតពិនិត្យសហគ្រាសនោះក្នុងកម្រិតណាមួយ ក្នុងគោលបំណងផលិត និងឬលក់ផលិតផលដែលជាទំនិញ ឬសេវាកម្មនៅក្នុងប្រទេសម្ចាស់ផ្ទះនោះ។ មូលធនក្នុងន័យខាងលើនេះអាចជាសាច់ប្រាក់ គ្រឿងម៉ាស៊ីន និងវត្ថុធាតុដើមជាដើម។

លើសពីនេះទៅទៀត យោងតាមវិធីសាស្ត្រចងក្រងស្ថិតិជញ្ជីងទូទាត់ និងស្ថានភាពវិនិយោគអន្តរជាតិរបស់មូលនិធិរូបបិយវត្ថុអន្តរជាតិ បោះពុម្ពលើកទី៦ (BPM6)[8] បានកំណត់និយន័យការវិនិយោគផ្ទាល់ពីបរទេសថា ជាប្រភេទនៃការវិនិយោគឆ្លងកាត់ព្រំដែនរវាងនិវាសជននៅក្នុងសេដ្ឋកិច្ចមួយ ដែលមានការត្រួតត្រាពេញលេញ ឬមានឥទ្ធិពលខ្លាំងទៅលើការគ្រប់គ្រងសហគ្រាសមួយ ដែលមានទីតាំងនៅក្នុងសេដ្ឋកិច្ចមួយផ្សេងទៀត។ ដូចគ្នាជាមួយនឹងភាគហ៊ុន ដែលផ្តល់ឲ្យនូវការត្រួតត្រា ឬមានឥទ្ធិពល ការវិនិយោគផ្ទាល់ក៏បានរាប់បញ្ចូលផងដែរនូវការវិនិយោគក្នុងសហគ្រាស ដែលមានទំនាក់ទំនងគ្នា ទាំងការវិនិយោគដោយប្រយោលទៅក្នុងសហគ្រាសសម្ព័ន្ធញាតិ សហគ្រាសដែលមានក្រុមហ៊ុនមេតែមួយ ប្រតិបត្តិការបំណុល និងការវិនិយោគត្រឡប់។ និយន័យខាងលើទាំងអស់នេះសុទ្ធតែមានអំណះអំណាងសមហេតុផល និងត្រឹមត្រូវដូចគ្នា ប៉ុន្តែនិយមន័យដែលយោងទៅតាមទ្រឹស្តីរបស់ John J. Wild និង Wild (2016) គឺមានភាពច្បាស់លាស់ និងមានអត្ថន័យសមហេតុផលជាង ដែលអាចអោយអ្នកស្រាវជ្រាវយកមកប្រើប្រាស់ជាផ្លូវការបាន។

---

[7] *សម្រាយបន្តពីសារណារបស់និស្សិតឈ្មោះ* នាង នីតា(2021) *ដែលបានដកស្រង់ ប្រភពដើមពីៈ* Wild, John J., & Wild, Kenneth L. *(2016). International Business: The Challenges of Globalization (8th ed.).* Harlow: Pearson *(p. 208).*

[8] *ដកស្រង់ពីៈ របាយការណ៍អំពីលទ្ធផលអង្កេតវិនិយោគផ្ទាល់ពីបរទេសឆ្នាំ2014 ។ វិធីសាស្ត្រចងក្រងស្ថិតិជញ្ជីងទូទាត់ និងស្ថានភាពវិនិយោគអន្តរជាតិរបស់មូលនិធិរូបបិយវត្ថុអន្តរជាតិ បោះពុម្ពលើកទី៦ (BPM6) ។ បានទាញយកនៅថ្ងៃទី19 ខែឧសភាព ឆ្នាំ2022 ម៉ោង10 ព្រឹក។*

https://www.nbc.org.kh/download_files/other_reports/khmer/Report-on-FDI-Survey-Result-2014_NBC_KH.pdf

## ៣.៣ ប្រវត្តិនៃការវិនិយោគផ្ទាល់ពីបរទេសនៅក្នុងប្រទេសកម្ពុជា

ប្រទេសកម្ពុជាបានក្លាយជាប្រទេសដែលទទួលបានឯករាជ្យនៅឆ្នាំ1953[9] ជាមួយនឹងមហិច្ឆតានៃភាពរីកចម្រើន និងការអភិវឌ្ឍតាមរយៈការពង្រីកវិស័យឧស្សាហកម្ម ដែលមានការវិនិយោគផ្ទាល់ពីបរទេស (FDI) ។ ឆ្លងមកដល់រយៈពេល 60 ឆ្នាំក្រោយមកបន្ទាប់ពីសង្គ្រាមរាប់ទសវត្សរ៍ និងការបំផ្លិចបំផ្លាញ មហិច្ឆតាទាំងនេះកំពុងចាប់ផ្តើមត្រូវបានសម្រេចជាមួយនឹងអត្រាកំណើនពីរគឺ ការពង្រីកអាជីវកម្ម និងសកម្មភាពសេដ្ឋកិច្ចបែបសកល។ ឯកសារនេះនឹងបង្ហាញពីការវិវត្តន៍ជាប្រវត្តិសាស្ត្រនៃសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ការវិនិយោគផ្ទាល់ពីបរទេស (FDI និងដំណើការសេដ្ឋកិច្ចកម្ពុជារហូតមកដល់ពេលបច្ចុប្បន្ននេះ។ ក្នុងរយៈពេល 60 ឆ្នាំចុងក្រោយនេះប្រទេសកម្ពុជាបានជួបប្រទះនូវមនោគមវិជ្ជានយោបាយខុសៗគ្នាជាច្រើន ដែលមានឥទ្ធិពលនៃការប្រែប្រួលលើគោលនយោបាយឧស្សាហកម្មរបស់ខ្លួននៅសម័យកាលនោះ។

### ៣.៣.១ ការវិនិយោគនៅសម័យសង្គមរាស្ត្រនិយម ( ១៩៥៣ ដល់ ១៩៧០ )

ប្រទេសកម្ពុជាបានទទួលឯករាជ្យពេញលេញពីប្រទេសបារាំងនៅក្នុងឆ្នាំ1953 មានរោងចក្រមួយចំនួនបានបង្កើតឡើង ដើម្បីផ្គត់ផ្គង់ទីផ្សារក្នុងស្រុកដូចជាវាយនភណ្ឌ ក្រដាស និងរោងសិប្បកម្ម ប៉ុន្តែភាគច្រើនអាស្រ័យលើការនាំចូលវត្ថុធាតុដើមហើយជាកម្មសិទ្ធិរបស់ជនបរទេស ឬជាកម្មសិទ្ធិរបស់ឥស្សរជន ក្រុមជនជាតិចិន។ នៅក្នុងសម័យសង្គមរាស្ត្រនិយមនេះផងដែរ កម្ពុជាភាគច្រើនទទួលយកនូវការធ្វើទំនាក់ទំនងសេដ្ឋកិច្ចជាមួយបរទេស និងទទួលយកការវិនិយោគទុនពីបរទេសថែមទៀតផង។ សេដ្ឋកិច្ចនៅក្នុងសម័យនោះអាចត្រូវបានពិពណ៌នាយ៉ាងល្អបំផុតថា ជាសេដ្ឋកិច្ចចម្រុះដែលរួមបញ្ចូលគ្នានូវដើមទុនបុគ្គល និងសហគ្រាសដែលមានដើមទុនមួយចំនួនជារបស់រដ្ឋ។ (តារាងទី១) បង្ហាញពីការកើនឡើងគួរឱ្យកត់សម្គាល់នៃចំនួនរោងចក្ររវាងឆ្នាំ 1955 និង 1968 ពីគ្មានរោងចក្រសោះរហូតដល់ 28 រោងចក្ររបស់រដ្ឋ និងរោងចក្របណ្តាក់ទុនរួមគ្នាចំនួន 29 (កម្មសិទ្ធិឯកជន និងសាធារណៈ) ចំណែកឯកជនខ្នាតតូច និងមធ្យម រោងចក្រទាំងនេះបានកើនឡើងយ៉ាងខ្លាំងពី 650 ក្នុងឆ្នាំ 1965 ដល់ 3,700 ក្នុងឆ្នាំ1968។ សូមក្រឡេកមកមើលតារាងនៅក្នុងទំព័របន្ទាប់ ដែលនិយាយអំពីចំនួន និងចំណាត់ថ្នាក់នៃរោងចក្ររវាងឆ្នាំ1955 ដល់ 1968។

[9] *Suggested Citation:* Chhair, Sokty; Ung, Luyna *(2013): Economic history of industrialization in Cambodia, WIDER Working Paper, No. 2013/134, The United Nations University World Institute for Development Economics Research (UNU-WIDER), Helsinki. Downloaded on 19 May 2022 at 3:00PM.* https://www.econstor.eu/bitstream/10419/93708/1/773878327.pdf

តារាងទី១៖ ចំនួន និងចំណាត់ថ្នាក់នៃរោងចក្ររវាងឆ្នាំ១៩៥៥ ដល់ ១៩៦៨

| | 1955 | 1968 |
|---|---|---|
| ❖ រោងចក្ររបស់រដ្ឋ | 0 | 28 |
| ❖ រោងចក្របណ្តាក់ទុនរួមគ្នា(កម្មសិទ្ធិឯកជន និងសាធារណៈ) | 0 | 29 |
| ❖ រោងចក្រឯកជនខ្នាតតូច និងមធ្យម | 650 | 3,700 |

ប្រភព៖ based on Cambodge (១៩៧០) cited in Ear (១៩៩៥ - ៤៩)

នៅក្នុងផែនការសេដ្ឋកិច្ចរយៈពេលប្រាំឆ្នាំ (ខែមករា ឆ្នាំ1960 ដល់ខែធ្នូ ឆ្នាំ1964) មានត្រឹមតែមួយភាគរយក្នុងមួយកញ្ចប់ថវិកាបានចូលរួមចំណែកដោយប្រទេសកម្ពុជា ហើយ 57 ភាគរយនៃការរួមចំណែក គឺបានមកពីថវិការបស់សហរដ្ឋអាមេរិក 23 ភាគរយបានមកពីប្រទេសចិន និង 17 ភាគរយមកពីប្រទេសបារាំង។ ខណៈពេលដែលហេដ្ឋារចនាសម្ព័ន្ធមានភាពប្រសើរឡើង រួមជាមួយនឹងចំនួនសហគ្រាសក៏មានតិចតួចដែរក្នុងការផ្លាស់ប្តូររចនាសម្ព័ន្ធជាក់ស្តែងនៅក្នុងតួលេខសរុប។ ដូចដែលបានបង្ហាញក្នុង (តារាងទី២) ដែលការផលិតមានចំនួន 8.6 ភាគរយនៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ1962 កើនឡើងដល់ 10.5 ភាគរយក្នុងឆ្នាំ1966 និង 12 ភាគរយ (រួមទាំងការជីកយករ៉ែ) ក្នុងឆ្នាំ1968 ។ វិស័យកសិកម្មនៅតែមានប្រហែល 41 ភាគរយនៃ GDP ពេញមួយឆ្នាំ។ សរុបមករចនាសម្ព័ន្ធសេដ្ឋកិច្ចបានផ្លាស់ប្តូរតិចតួចណាស់រវាងឆ្នាំ1966 និង1968 ការនាំចេញរបស់កម្ពុជាពឹងផ្អែកយ៉ាងលើសលប់លើផលិតផលចម្បងធំៗមានដូចជា អង្ករ និងកៅស៊ូជាការនាំចេញដ៏ធំបំផុត ដែលស្មើនឹងជាងពាក់កណ្តាលនៃការនាំចេញសរុប។ ការដករបាំងពន្ធគយនៅចុងឆ្នាំ1969 បានរងនូវផលប៉ះពាល់យ៉ាងខ្លាំងដល់សហគ្រាសខ្នាតតូច ដែលមានចំនួន 90 ភាគរយនៃក្រុមហ៊ុននៅពេលនោះដោយសារតែគោលនយោបាយការពារឧស្សាហកម្មជាច្រើន។

តារាងទី២៖ វិស័យភាគហ៊ុននៃផលិតផលក្នុងស្រុកសរុបនៅឆ្នាំ១៩៦៦ គិតជាភាគរយ (%)

| | 1962 | 1966 |
|---|---|---|
| ▪ កសិកម្ម | 30.7 | 30.3 |
| ▪ ចិញ្ចឹមសត្វ | 4.3 | 4.9 |
| ▪ នេសាទ | 2.4 | 2.3 |
| ▪ ព្រៃឈើ | 3.9 | 3.5 |
| ▪ រ៉ែអំបិល | 0.1 | - |
| ▪ ផលិតកម្ម | 8.6 | 10.5 |
| ▪ ផ្គត់ផ្គង់ទឹក និងថាមពល | 0.9 | 1.1 |
| ▪ សំណង់ | 6.8 | 5.3 |
| ▪ ដឹកជញ្ជូន | 2.0 | 2.1 |
| ▪ ពាណិជ្ជកម្ម | 23.8 | 22.2 |
| ▪ រដ្ឋបាលសាធារណៈ វិស័យការពារជាតិ និងស្ថាប័នហិរញ្ញវត្ថុ | 13.1 | 14.4 |
| ▪ វិស័យសេវាកម្មផ្សេងៗទៀត។ | 3.4 | 3.4 |

ប្រភព៖ ក្រសួងផែនការ (១៩៦៦) ដកស្រង់ក្នុង Slocomb (២០១០)

### ៣.៣.២ ការវិនិយោគនៅសម័យសាធារណៈរដ្ឋខ្មែរ (១៩៧០ ដល់ ១៩៧៥)

ចាប់ពីឆ្នាំ1970 ប្រទេសកម្ពុជាបានធ្លាក់ចូលទៅក្នុងសង្គ្រាមស៊ីវិល ដែលធ្វើឲ្យកម្ពុជាទទួលរងផលប៉ះពាល់ទៅដល់សេដ្ឋកិច្ចមួយចំនួន។ ទោះបីជាយ៉ាងណាក៏ដោយ សូម្បីតែមុនការផ្លាស់ប្តូររបបដឹកនាំនៅឆ្នាំ១៩៧០ មេដឹកនាំនៃរដ្ឋប្រហារនាយឧត្តមសេនីយ៍ លន់ នល់ និង ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ ដែលនឹងក្លាយជាមេដឹកនាំថ្មីក្នុងអាណត្តិថ្មីនៅក្នុងសម័យនោះផងដែរ គោលនយោបាយថ្មីដែលប្រកាន់យកភាពយុត្តិធម៌ពាក់ព័ន្ធនឹងការទម្លាក់តម្លៃរូបិយប័ណ្ណដោយដកចេញការគ្រប់គ្រងរបស់រដ្ឋលើពាណិជ្ជកម្មបរទេស វិស័យធនាគារ និង

កាត់បន្ថយការចូលរួមលូកដៃរបស់រដ្ឋនៅក្នុងសហគ្រាស។ ម៉្យាងវិញទៀត ការផ្លាស់ប្តូរដ៏សំខាន់បំផុតចំពោះគោលនយោបាយឧស្សាហកម្ម គឺការផ្តាច់ទំនាក់ទំនងរវាងវិស័យសាធារណៈ និងការសង្កត់ធ្ងន់ទៅលើសហគ្រាសឯកជនជាយន្តការសម្រាប់ពាណិជ្ជកម្ម និងការអភិវឌ្ឍឧស្សាហកម្ម។ ផលិតកម្មស្រូវ និងពោតត្រូវបានគេធ្វើសេរីភាវូបនីយកម្មជាមួយការលុបបំបាត់នូវភាពផ្តាច់មុខរបស់រដ្ឋលើការនាំចេញគ្រាប់ធញ្ញជាតិ និងដំណាំកសិកម្ម ពោលរដ្ឋនៅសល់តែអំណាចផ្តាច់មុខក្នុងការផលិត និងចែកចាយអគ្គិសនីលើសពី 500 គីឡូវ៉ាត់ វិស័យដែលទាក់ទងនឹងយោធា ផ្លូវរថភ្លើង សេវាប្រៃសណីយ៍ និងសេវាទូរគមនាគមន៍។ បើទោះបីជាយ៉ាងណាក៏ដោយ ក៏គោលនយោបាយទាំងនេះមានរយៈពេលខ្លី ហើយការអនុវត្តរបស់ពួកគេត្រូវបានរំខានដោយសង្គ្រាមស៊ីវិល។ សេដ្ឋកិច្ចសម័យនោះពឹងផ្អែកតែលើជំនួយបរទេស ដែលភាគច្រើនពីសហរដ្ឋអាមេរិកដើម្បីបន្តការរស់រានមានជីវិតនៃសេដ្ឋកិច្ច។ (តារាងទី៣) បង្ហាញពីផលប៉ះពាល់ដែលសង្គ្រាមស៊ីវិលមានមកលើផលិតកម្មកសិកម្មដំណាំស្រូវ កៅស៊ូ និងពោតដែលនាំឲ្យទិន្នផលធ្លាក់ចុះយ៉ាងខ្លាំង ដោយសន្ទស្សន៍ផលិតកម្មដែលមាន 100 ក្នុងឆ្នាំ 1968 បានធ្លាក់ចុះដល់ 73 ក្នុងឆ្នាំ1972 ។

តារាងទី៣៖ ផលិតកម្មកសិកម្មរាប់សែនតោនក្នុងឆ្នាំ១៩៦៨ ដល់ ១៩៧៤ (គិតជាតោន)

| | 1968/69 | 1969/70 | 1970/71 | 1971/72 | 1972/73 | 1973/74 |
|---|---|---|---|---|---|---|
| ❖ អង្ករ | 2,503 | 3,814 | 2,732 | 2,138 | 953 | 762 |
| ❖ កៅស៊ូ | 51 | 52 | 13 | 1 | 15 | 12 |
| ❖ ពោត | 117 | 137 | 121 | 80 | 73 | - |
| ❖ ស្ករត្នោត | - | 34 | 23 | - | - | - |

ប្រភព៖ based on Ear (១៩៩៥)

### ៣.៣.៣ ការវិនិយោគនៅសម័យកម្ពុជាប្រជាធិបតេយ្យ (១៩៧៥ ដល់ ១៩៧៩)

ក្រោយខ្មែរក្រហមបានឡើងកាន់អំណាច សេដ្ឋកិច្ចកម្ពុជាបានដាំក្បាលចុះក្រោម ពោលសេដ្ឋកិច្ចបានទទួលរងនូវផលប៉ះពាល់យ៉ាងខ្លាំង ដោយបានបាត់បង់នូវការវិនិយោគ ហេដ្ឋារចនាសម្ព័ន្ធ និងមូលធនហិរញ្ញវត្ថុផ្សេងៗ។ មហិច្ចតារបស់មេដឹកនាំនៅសម័យនោះ គឺដើម្បីធ្វើការផ្លាស់ប្តូរប្រទេសទៅជារបបគ្រប់គ្រងបែបកុម្មុយនិស្តនៅកម្ពុជាក្នុងរយៈពេលដ៏ខ្លីបំផុត គោលនយោបាយសេដ្ឋកិច្ចរបស់ពួកគេ គឺដើម្បីកម្ទេចពួកមូលធននិយម ធ្វើជាទាសករនៃកម្លាំងពលកម្ម និងផ្តោតសំខាន់ទៅលើការអភិវឌ្ឍវិស័យកសិកម្មយ៉ាងឆាប់រហ័ស។ ដើម្បីសម្រេចបាននូវរបបនេះទាំងស្រុង និងភ្លាមៗកសិកម្មសមូហភាព ការធ្វើជាតូបនីយកម្មគ្រប់វិស័យទាំងអស់នៃសេដ្ឋកិច្ច និងបានអនុម័តគោលនយោបាយការពឹងផ្អែកលើខ្លួនឯង។ ទ្រព្យសម្បត្តិទាំងអស់ត្រូវបានគ្រប់គ្រងដោយរដ្ឋ ហើយការចូលរួមពីអន្តរជាតិទាំងអស់គឺត្រូវបានដកចេញ ហើយគោលនយោបាយថ្មីនេះបានបង្វែរគោលនយោបាយសេដ្ឋកិច្ច ដែលបានអនុម័តពីមុនទាំងស្រុង ទៅជារបបដែលតំណាងឲ្យការផ្លាស់ប្តូរនៃមនោគមវិជ្ជាសេដ្ឋកិច្ច ។ រាជធានីភ្នំពេញ និងខេត្តក្រុងផ្សេងៗទៀតត្រូវបានបោះបង់ចោលហើយអ្នកទីក្រុងត្រូវបានបង្ខំឲ្យធ្វើការជាកសិករសមូហភាពនៅជនបទ ចំណែកឯកម្មសិទ្ធិឯកជនត្រូវបានហាមឃាត់ទាំងស្រុង និងរូបិយប័ណ្ណត្រូវបានលុបចោលនៅក្នុងសម័យនោះ។

### ៣.៣.៤ ការវិនិយោគនៅសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា (១៩៧៩ ដល់ ១៩៨៩)

ក្រោយថ្ងៃរំដោះកម្ពុជាពីរបបប្រល័យពូជសាសន៍ខ្មែរក្រហម របបថ្មីមួយទៀតបានលេចរូបរាងឡើងដែលមានឈ្មោះថា សាធារណរដ្ឋប្រជាមានិតកម្ពុជា ក្នុងសម័យនោះដែរកម្ពុជានៅសល់ធនធានតិចតួចណាស់ក្នុងការស្តារសេដ្ឋកិច្ចកម្ពុជាឲ្យងើបឡើងវិញ។ សេដ្ឋកិច្ចមួយភាគធំជាប្រភេទកសិកម្មចិញ្ចឹមជីវិតខ្នាតតូច ហើយមានឧស្សាហកម្មតិចតួចបំផុត ឬសឹងតែគ្មានតែម្តង។ ចាប់ពីឆ្នាំ1979 ដល់ 1989 គោលនយោបាយសេដ្ឋកិច្ចផ្តោតសំខាន់លើសន្តិសុខស្បៀង និងការលុបបំបាត់ភាពអត់ឃ្លាននៅទូទាំងប្រទេសដោយសហគ្រាសរបស់រដ្ឋត្រូវបានបង្កើតឡើងវិញ ដែលរួមមានថ្នាំជក់ កប្បាស និងក្រុមហ៊ុនអគ្គិសនី មេកានិច គ្រឿងបន្លាស់ ភេសជ្ជៈរោងចក្រផលិតគ្រឿងកញ្ចក់ និងរោងចក្រសំបកកង់។ ការបង្កើតទាំងអស់នេះក្នុងគោលបំណងដើម្បីផ្តល់ទំនិញប្រើប្រាស់ជាមូលដ្ឋាន និងឧបករណ៍ប្រើប្រាស់ជាសាធារណៈ ដែលសហគ្រាសរបស់រដ្ឋជារឿយៗលក់ផលិតផលក្នុងតម្លៃឧបត្ថម្ភធន ជាពិសេសរដ្ឋបានឧបត្ថម្ភធនតម្លៃទំនិញមួយចំនួនដូចជាប្រេងកាត បារី សាប៊ូ អង្ករ ស្ករ និងទឹកដោះគោខាប់។ នៅក្នុងសម័យនោះដែរ កម្ពុជាបានជម្រុញក្នុងការបែងចែក និងរៀបចំសេដ្ឋកិច្ចឡើងវិញដូចជា ប្រមូលកៀងគរអ្នកវិនិយោគពីបរទេស ជួយជម្រុញដល់កំណើនសេដ្ឋកិច្ចឧស្សាហកម្ម។ ប៉ុន្តែទាំងអស់នេះពុំទទួលបានជោគជ័យឡើយ ពីព្រោះកម្ពុជាយើងមានកង្វះខ្វះខាតជាច្រើន ទាំងធនធានមនុស្ស ហេដ្ឋារចនាសម្ព័ន្ធ ទីផ្សារ ជាពិសសគឺភាពអសន្តិសុខនៅក្នុងប្រទេស។

### ៣.៣.៥ ការវិនិយោគនៅសម័យរដ្ឋកម្ពុជា និងអ៊ុនតាក់ (១៩៨៩ ដល់ ១៩៩៣)

ដំណើរការនៃកំណែទម្រង់ឆ្ពោះទៅរកការក្លាយជាសេដ្ឋកិច្ចទីផ្សារ ត្រូវបានលេចរូបរាងឡើងនៅក្នុងសម័យនោះ ដែលការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសនៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ដែលជាផ្នែកនៃកិច្ចព្រមព្រៀងសន្តិភាពរដ្ឋាភិបាលកម្ពុជាបានលះបង់តួនាទីស្តារនីតិសម្បទា និងការកសាងឡើងវិញរបស់អង្គការសហប្រជាជាតិ ដែលមានអាទិភាពសម្រាប់ដំណាក់កាលស្តារនីតិសម្បទា គឺការអភិវឌ្ឍសង្គម និងការផ្តល់ដូចជា សន្តិសុខស្បៀង សុខភាព លំនៅដ្ឋាន ការបណ្តុះបណ្តាល ការអប់រំ ប្រព័ន្ធប្រើប្រាស់សាធារណៈ និងមូលដ្ឋានហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន។ ក្នុងដំណាក់កាលកសាងឡើងវិញ ភាពជាសហគ្រិន និងវិស័យឯកជនការអភិវឌ្ឍ ក៏ត្រូវបានលើកកម្ពស់ផងដែរ ដើម្បីរៀបចំសម្រាប់ការឈានជើងចូលទៅក្នុងសេដ្ឋកិច្ចទីផ្សារសេរី។ រីឯនៅក្នុងពាក់កណ្តាលឆ្នាំ1980 ប្រទេសកម្ពុជាបានយកចិត្តទុកដាក់ទៅលើការលើកកម្ពស់ទៅដល់កម្មសិទ្ធិឯកជន ដែលនាំទៅដល់ការធ្វើឯកជនភាវូបនីយកម្មបន្តិចម្តងៗនៃក្រុមហ៊ុនរបស់រដ្ឋ និងការដកចេញនូវសមូហភាពនៃវិស័យកសិកម្ម។ (តារាងទី៤) បង្ហាញពីភាពជោគជ័យមួយចំនួននៃអំឡុងពេលសម័យនោះ ដែលផលិតផលក្នុងស្រុកសរុបដែលមានកំណើនយ៉ាងខ្លាំងនៅក្នុងឆ្នាំ1988 គឺ 9.8 ភាគរយការធ្លាក់ចុះនៅឆ្នាំ 1989 និង 1990 និងការងើបឡើងវិញបន្តបន្ទាប់មករហូតដល់មានការកើនឡើងខ្លាំងឡើងវិញ។ ដោយមានការជម្រុញបន្ថែមក្នុងការកសាងប្រតិបត្តិការរបស់អង្គការសហប្រជាជាតិ វិស័យកសិកម្មបានចូលរួមចំណែកជាងពាក់កណ្តាលនៃ GDP ក្នុងអំឡុងពេលនោះផងដែរខណៈពេលដែលវិស័យសេវាកម្មមានប្រហែល 33 ភាគរយនៃទិន្នផល និងឧស្សាហកម្ម 15 ភាគរយ។ ជាលទ្ធផល អត្រាអតិផរណាបានកើនឡើងពី 70 ភាគរយនៅឆ្នាំ 1989 ដល់ 200 ភាគរយក្នុងឆ្នាំ1992 (សូមមើលតារាងទី៥) ។

តារាងទី៤៖ កំណើន GDP ពិតប្រាកដ និងចំណែកនៃ GDP រវាងឆ្នាំ១៩៨៨ ដល់ ១៩៩២
(គិតជាភាគរយ)

| | 1988 | 1989 | 1990 | 1991 | 1992 |
|---|---|---|---|---|---|
| អត្រាកំណើន ផ.ស.ស ពិតប្រាកដ | | | | | |
| ផ.ស.ស | 9.8 | 3.5 | 1.2 | 7.6 | 6.9 |
| • កសិកម្ម | 5.9 | 7.1 | 1.2 | 6.7 | 4.8 |

| | | | | | |
|---|---|---|---|---|---|
| • ឧស្សាហកម្ម | 15 | 1.8 | -2.1 | 8.9 | 8.4 |
| • សេវាកម្ម | 13.6 | -1.1 | 2.7 | 8.4 | 9.5 |
| ផ.ស.ស តាមវិស័យ | | | | | |
| • កសិកម្ម | 50.5 | 52.2 | 52.3 | 51.8 | 50.8 |
| • ឧស្សាហកម្ម | 15.7 | 15.4 | 14.9 | 15.1 | 15.3 |
| • សេវាកម្ម | 33.8 | 32.4 | 32.8 | 33.1 | 33.9 |

ប្រភព៖ based on Irvin (១៩៩៣)

តារាងទី៥៖ អត្រាអតិផរណាឆ្នាំ ១៩៨៩ ដល់ ១៩៩២ គិតជាភាគរយ (%)

| ឆ្នាំ | 1989 | 1990 | 1991 | 1992 |
|---|---|---|---|---|
| អត្រាគិតជាភាគរយ (%) | 70 | 157 | 121 | 200 |

ប្រភព៖ based on Ear (១៩៩៥)

### ៣.៣.៦ ការវិនិយោគនៅសម័យព្រះរាជាណាចក្រកម្ពុជា (១៩៩៣ ដល់ បច្ចុប្បន្ន)

បន្ទាប់ពីការបោះឆ្នោតសកលលើកដំបូងក្នុងឆ្នាំ១៩៩៣ រដ្ឋាភិបាលបានរៀបចំ និងអនុវត្តកម្មវិធីគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចយ៉ាងទូលំទូលាយ និងកម្មវិធីកំណែទម្រង់រចនាសម្ព័ន្ធជាមួយនឹងការខិតខំប្រឹងប្រែង ដើម្បីធ្វើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងតំបន់ និងទូទាំងពិភពលោក។ នៅចុងទស្សវត្សរ៍ឆ្នាំ 1980 ប្រទេសកម្ពុជាបានចាប់ផ្តើមដំណើរការនៃទីផ្សារសេរីភាវូបនីយកម្ម។ ភាពផ្តាច់មុខរបស់រដ្ឋចំពោះពាណិជ្ជកម្ម

បរទេសត្រូវបានលុបចោលនៅឆ្នាំ1987 ហើយច្បាប់វិនិយោគផ្ទាល់ពីបរទេសត្រូវបានដាក់ចូលជាធរមាននៅឆ្នាំ 1989 ដែលអនុញ្ញាតឲ្យក្រុមហ៊ុនឯកជន អាចធ្វើការវិនិយោគមកក្នុងប្រទេសកម្ពុជា។ ដើម្បីជំរុញការអភិវឌ្ឍនៅក្នុងវិស័យឧស្សាហកម្ម រដ្ឋាភិបាលបានផ្ដល់ការលើកទឹកចិត្ត និងជម្រុញកិច្ចសហប្រតិបត្តិការជាមួយបណ្ដាប្រទេសនៅលើពិភពលោក ដើម្បីទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស (FDI) និងក្នុងពេលជាមួយគ្នានេះដែរ កម្ពុជាបានខិតខំស្វែងរកទីផ្សារនាំចេញសម្រាប់ផលិតផលដែលផលិតដោយក្រុមហ៊ុន ដែលវិនិយោគផ្ទាល់ពីបរទេស (FDI) ។ ការលើកលែងពន្ធត្រូវបានផ្ដល់ជូនលើទំនិញកម្រិតមធ្យមដែលនាំចូល និងលើការនាំចេញទំនិញសម្រេច។ កម្ពុជាបានក្លាយជាសមាជិកនៃអង្គការពាណិជ្ជកម្មសេរីតំបន់អាស៊ានក្នុងឆ្នាំ1999 និងអង្គការពាណិជ្ជកម្មពិភពលោក(WTO) ក្នុងឆ្នាំ2004 ។ អង្គការទាំងនេះបានដាក់លក្ខខណ្ឌបន្ថែមលើកម្ពុជា ដើម្បីធ្វើពាណិជ្ជកម្មសេរីភាវូបនីយកម្ម លើទំនិញ សេវាកម្ម និងកម្មសិទ្ធិមូលធនវិនិយោគផ្ទាល់ពីបរទេស (FDI) ដែលបានដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើនផលិតកម្ម ជាពិសេសដើម្បីទាញយកឱកាសពីការធ្វើពាណិជ្ជកម្មនៅក្នុងបណ្ដាប្រទេស ដែលមានសេដ្ឋកិច្ចជឿនលឿន។ លំហូរចូលការវិនិយោគផ្ទាល់ពីបរទេសបានកើនឡើងត្រឹមតែ 124 លានដុល្លារក្នុងឆ្នាំ1993 ដល់ 520 លានដុល្លារក្នុងឆ្នាំ2009 ឬច្រើនជាងនេះ និង 1,500 លានដុល្លារក្នុងឆ្នាំ2012 (ផ្អែកលើមូលដ្ឋានទិន្នន័យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) ។

### ៣.៤ មូលដ្ឋានគ្រឹះ ដែលទាក់ទងនឹងការវិនិយោគផ្ទាល់ពីបរទេស (FDI)

ជាទូទៅ ការវិនិយោគផ្ទាល់ពីបរទេសកើតឡើងបានពីការបញ្ចៀតចូលទៅក្នុងទីផ្សាររបស់ប្រទេសមួយក្នុងរូបរាង បីយ៉ាងគឺ[10]៖ ក្រុមហ៊ុនសាខា (Greenfield Investment) គឺជាការបង្កើតប្រតិបត្តិការថ្មីទាំងស្រុងនៅក្នុងប្រទេសថ្មីមួយ។ ក្រុមហ៊ុនរួមទុន (Acquisition or Merger Investment) គឺនៅពេលក្រុមហ៊ុនសាអាជីវកម្មធ្វើការចូលរួមចំណែកលើការវិនិយោគនៅក្នុងប្រទេសមួយ ជាមួយនឹងដៃគូក្នុងស្រុកទោះបីជាសហគ្រាសឯកជនឬសហគ្រាសរបស់រដ្ឋក្ដី។ ចំណុចចុងក្រោយ Brownfield Investment គឺជាប្រភេទនៃការវិនិយោគដោយការទិញ ឬជួលទីតាំងផលិតកម្ម ដែលមានស្រាប់នៅក្នុងប្រទេសម្ចាស់ផ្ទះ ដើម្បីផលិតនូវផលិតផលថ្មីរបស់ខ្លួន។ ជាទូទៅ តាមរយៈនិន្នាការលំហូរការវិនិយោគផ្ទាល់ពីបរទេសនៅលើពិភពលោក លក្ខណៈវិនិយោគរួមទុន ហាក់បីមានការកើនឡើងលើសពីការវិនិយោគដោយបង្កើតប្រតិបត្តិការណ៍ថ្មីទាំងស្រុង។

ក្នុងលក្ខខណ្ឌនេះដែរ បើទោះបីជាវាធ្វើឲ្យមានការបាត់បង់ភាពជាម្ចាស់គ្រប់គ្រងរបស់ក្រុមហ៊ុនមេយ៉ាងណាក៏ដោយ ក៏ក្រុមហ៊ុនវិនិយោគបរទេសនៅតែធ្វើការចូលរួមទុន ដោយសារមូលហេតុមួយចំនួនដូចជា៖ ទី១ ក្រុមហ៊ុនរួមទុនមានភាពងាយស្រួល និងរហ័សក្នុងការប្រតិបត្តិការសាកល្បងជាមួយនឹងតម្រូវការមូលធន

[10] *International Business, Foreign Direct Investment, The Form of FDI (Page: 244 – 245)*

ដែលអាចឲ្យក្រុមហ៊ុនសាអាជីវកម្មរីករាលដាលយ៉ាងឆាប់រហ័សជុំវិញពិភពលោក។ ទី២ ដើម្បីកាត់បន្ថយនូវហានិភ័យនៅក្នុងតំបន់វិនិយោគ ដែលក្រុមហ៊ុនវិនិយោគពីបរទេសត្រូវការជំនួសខាងលក្ខណៈសម្បត្តិមូលដ្ឋានពីក្រុមហ៊ុនក្នុងស្រុក ដូចជាទំនាក់ទំនងអតិថិជន ប្រព័ន្ធផលិតកម្ម ប្រព័ន្ធចែកចាយកេរ្តិ៍ឈ្មោះជាដើម ដែលការកសាងមូលដ្ឋានទាំងនេះត្រូវចំណាយពេលវេលាក្នុងពេលបង្កើតក្រុមហ៊ុនថ្មីស្រឡាងមួយឡើង។ ទី៣ ការចូលរួមទុនត្រូវបានគេជឿថា វាអាចបង្កើនប្រសិទ្ធភាព ដោយការផ្ទេរនូវបច្ចេកវិទ្យា ធនធាន និងជំនាញគ្រប់គ្រងផ្សេងៗ។ ទី៤ ដោយសារច្បាប់ចងក្រង គឺនៅពេលដែលរដ្ឋាភិបាលនៅក្នុងប្រទេសទទួលការវិនិយោគ ដែលតម្រូវឲ្យក្រុមហ៊ុនបរទេសទាំងនោះ ត្រូវមានការចូលរួមជាមួយដៃគូវិនិយោគក្នុងស្រុក។

### ៣.៤.១ ប្រភេទនៃការវិនិយោគផ្ទាល់ពីបរទេស (Types of FDI)

វិនិយោគិនបរទេសអាចចូលរួមក្នុងការវិនិយោគផ្ទាល់ពីបរទេសតាមវិធីផ្សេងៗគ្នា។ ពួកគេអាចពង្រីកប្រតិបត្តិការរបស់ពួកគេនៅក្នុងប្រទេសនានា ឬពួកគេអាចទទួលបានភាគហ៊ុនសម្រាប់ការឈរជើងរបស់អាជីវកម្ម ដែលមានមូលដ្ឋាននៅក្នុងប្រទេសផ្សេងៗនៅលើពិភពលោក។ នេះគឺជាប្រភេទ ឬវិធីផ្សេងៗគ្នាមួយចំនួនដែល FDIs អាចត្រូវបានប្រើ ដើម្បីជ្រៀតចូលទៅក្នុងទីផ្សារក្រៅប្រទេស ដែលមានដូចជា៖ Horizontal FDI, Vertical FDI, Conglomerate FDI, Platform FDI [11]។




ចំពោះ Horizontal FDI[12] គឺជាប្រភេទនៃការវិនិយោគផ្ទាល់ពីបរទេសទូទៅបំផុត ដែលវិនិយោគិនភាគច្រើនយកមកប្រើប្រាស់។ វាពាក់ព័ន្ធនឹងការបណ្តាក់ទុននៅក្នុងក្រុមហ៊ុនបរទេស ដែលមានកម្មសិទ្ធិទៅលើវិស័យឧស្សាហកម្មដូចគ្នា ដែលជាប្រភេទនៃការវិនិយោគនៅក្នុងប្រទេសម្ចាស់ផ្ទះជាមួយវិស័យដូចគ្នាទៅនឹង

[11] *Understanding the Workings of Foreign Direct Investment, Types of FDI. Downloaded on 20 May 2022 at 6:00PM.* https://tradesmartonline.in/knowledge-hub/stock-market/types-of-fdi/

[12] *Understanding the Workings of Foreign Direct Investment, Types of FDI. Downloaded on 20 May 2022 at 9:00PM.* https://tradesmartonline.in/knowledge-hub/stock-market/types-of-fdi/

ប្រតិបត្តិការរបស់ក្រុមហ៊ុនមេ ដែលនៅក្នុងប្រទេសដើម។ ដូច្នេះការវិនិយោគប្រភេទនេះ គឺធ្វើឡើងតាមរយៈក្រុមហ៊ុនក្នុងស្រុក បណ្តាក់ទុនទៅក្នុងក្រុមហ៊ុនបរទេស ដែលក្រុមហ៊ុនទាំងពីរផលិតទំនិញស្រដៀងគ្នា និងជាកម្មសិទ្ធិរបស់ឧស្សាហកម្មដូចគ្នា។ ការចែកចាយមូលនិធិត្រូវបានគេមើលឃើញថាជា Horizontal នៅទូទាំងវិស័យនានា ទោះបីជាស្ថិតនៅក្នុងប្រទេសផ្សេងៗគ្នាយ៉ាងណាក៏ដោយ។ ចាប់តាំងពីអាជីវកម្មស្នូលគឺដូចគ្នាវាក៏អាចត្រូវបានគេមើលឃើញថា ជាការពង្រីកអាជីវកម្មក្នុងស្រុករបស់អ្នកវិនិយោគនៅក្រៅប្រទេសផងដែរ។ ឧទាហរណ៍៖ ក្រុមហ៊ុន Nike ជាក្រុមហ៊ុន ដែលមានមូលដ្ឋាននៅសហរដ្ឋអាមេរិកអាចទិញក្រុមហ៊ុន Puma ជាក្រុមហ៊ុន ដែលមានមូលដ្ឋាននៅប្រទេសអាល្លឺម៉ង់ ព្រោះឧស្សាហកម្មទាំងពីរមានផលិតផលជាសម្លៀកបំពាក់កីឡាដូចគ្នា។ លើសពីនេះទៅទៀត ជាក់ស្តែងក្នុងប្រទេសកម្ពុជា គឺក្រុមហ៊ុន Siam Cement Group ដែលជាក្រុមហ៊ុនផលិតស៊ីម៉ងត៍ម៉ាក SCG របស់ប្រទេសថៃ បានវិនិយោគទុនដោយផ្ទាល់មកកាន់កម្ពុជាប្រភេទជា HORIZONTAL FDI ដោយបានធ្វើការផលិតនូវផលិតផលស៊ីម៉ង់ម៉ាក Kampot Cement (K-Cement) ។

រីឯ Vertical FDI[13] គឺជាការវិនិយោគរបស់ក្រុមហ៊ុនមេនៅក្នុងប្រទេសដើមកំណើតទៅកាន់ប្រទេសម្ចាស់ផ្ទះដោយការទិញយក ឬបង្កើតជាក្រុមហ៊ុនសម្រាប់ដើរតួនាទីជាអ្នកចែកចាយផលិតផលរបស់ខ្លួននៅក្នុងប្រទេសម្ចាស់ផ្ទះ។ ឧទាហរណ៍៖ ក្រុមហ៊ុន McDonald's បានទិញរោងចក្រកែច្នៃសាច់ទ្រង់ទ្រាយធំមួយនៅបណ្តាប្រទេសក្នុងតំបន់អឺរ៉ុប ដើម្បីជម្រុញខ្សែសង្វាក់ផ្គត់ផ្គង់សាច់របស់ខ្លួននៅក្នុងប្រទេសគោលដៅ។ លើសពីនេះទៅទៀត ជាក់ស្តែងនៅក្នុងវិស័យ E-Commerce នៅប្រទេសថៃ ក្រុមហ៊ុន Alibaba របស់ប្រទេសចិនបានទិញយកក្រុមហ៊ុនLAZADA របស់ប្រទេសថៃ ដើម្បីធ្វើការចែកចាយនូវផលិតផលរបស់ខ្លួនពីប្រទេសចិន។

ចំណែកឯ Conglomerate FDI[14] គឺជាប្រតិបត្តិការមួយ ដែលការវិនិយោគត្រូវបានធ្វើឡើងនៅក្នុងក្រុមហ៊ុនពីរផ្សេងគ្នា ពោលជាប្រភេទនៃការវិនិយោគនៅក្នុងប្រទេសម្ចាស់ផ្ទះជាមួយវិស័យ ដែលមិនទាក់ទងគ្នាទាល់តែសោះទៅនឹងប្រតិបត្តិការរបស់ក្រុមហ៊ុនមេ ដែលនៅក្នុងប្រទេសដើមកំណើត។ ឧទាហរណ៍៖ ក្រុមហ៊ុនលក់រាយមួយរបស់សហរដ្ឋអាមេរិក ដែលមានឈ្មោះថា Walmart បានវិនិយោគទៅលើម៉ូតូ TATA ដែលជាក្រុមហ៊ុនផលិតរថយន្តរបស់ឥណ្ឌា។

---

[13] *សម្រាយបន្តពីសារណារបស់និស្សិតឈ្មោះ* នាង នីតា*(2021) ដែលបានដកស្រង់ ប្រភពដើមពី៖* Rugman, Alan M., & Collinson, Simon. (2012). *International Business: (6th ed.).* Harlow: *Pearson (p. 366)*

[14] *What are the types of Foreign Direct Investment?* – Enterslice, *Downloaded on 21 May 2022 at 9:00AM.* https://www.google.com/amp/s/enterslice.com/learning/types-of-foreign-direct-investment/

ប្រភេទចុងក្រោយ Platform FDI[15] គឺជាប្រភេទចុងក្រោយនៃការវិនិយោគផ្ទាល់ពីបរទេស ដែលជាការពង្រីកអាជីវកម្មទៅបរទេសរបស់ប្រទេសដើមកំណើត ទៅក្នុងប្រទេសម្ចាស់ផ្ទះ ប៉ុន្តែអ្វីៗដែលផលិតនៅទីនោះ (ប្រទេសម្ចាស់ផ្ទះ) គឺត្រូវបាននាំចេញទៅកាន់ប្រទេសទីបី។ ឧទាហរណ៍៖ ជាក់ស្តែងនៅប្រទេសកម្ពុជា ក្រុមហ៊ុន Adidas ដែលជាក្រុមហ៊ុនមានមូលដ្ឋានក្នុងប្រទេសអាល្លឺម៉ង់ បានបោះទីតាំងរោងចក្រក្នុងការផលិតសម្លៀកបំពាក់កីឡានៅប្រទេសកម្ពុជា បន្ទាប់មកធ្វើការនាំចេញផលិតផលនោះទៅកាន់ សហរដ្ឋអាមេរិក សហភាពអឺរ៉ុប និងអាស៊ី។ លើសពីនេះទៅទៀត ម៉ាក់យីហោទឹកអប់បារាំងម៉ាក Chanel បានបង្កើតរោងចក្រផលិតផលិតផលនៅសហរដ្ឋអាមេរិក ហើយបាននាំចេញផលិតផលទៅបណ្តាប្រទេសនៅអាស៊ី និងផ្នែកផ្សេងៗទៀតនៃទ្វីបអឺរ៉ុប។

### ៣.៤.២ ទម្រង់នៃការវិនិយោគផ្ទាល់ពីបរទេស

ការវិនយោគផ្ទាល់ពីបរទេស ត្រូវបានសិក្សាមើលឃើញថា គឺមានទម្រង់ខុសៗគ្នា ដែលរួមមានដូចជាការវិនិយោគស្វែងរកទីផ្សារ ការវិនិយោគដើម្បីនាំចេញ និងការវិនិយោគស្វែងរកធនធាន។[16]

#### ៣.៤.២.១ ការវិនិយោគស្វែងរកទីផ្សារ (Market Seeking Investment)

ការវិនិយោគស្វែងរកទីផ្សារ គឺជាការវិនិយោគពីបរទេសមួយបែប ដែលតាមលោក Rajneesh Narula[17] បានពន្យល់ថា ការវិនិយោគបែបនេះកើតឡើងនៅពេលក្រុមហ៊ុនធ្វើអន្តរតូបនីយកម្មទៅក្នុងប្រទេសមួយ ដើម្បីផ្គត់ផ្គង់ទំនិញ និងសេវាកម្មនៅលើទីផ្សារប្រទេសនោះក្នុងគោលបំណង ដើម្បីពង្រីកទៅក្នុងទីផ្សារ និងប្រកួតប្រជែងក្នុងវិស័យទីផ្សាររបស់ខ្លួន ដើម្បីឆក់យកឱកាស Production Economies of Scale ។ ដើម្បីទាញយកប្រយោជន៍ទាំងនេះ គឺទាមទារនូវទីផ្សារ ដែលមានទំហំប្រជាជនធំ ឬទីផ្សារដែលមានទំហំសេដ្ឋកិច្ចធំ ដើម្បីទ្រទ្រង់ទំហំវិនិយោគ ដែលបានបោះទុនក្នុងការវិនិយោគ។ ដូច្នេះហើយ ការវិនិយោគផ្ទាល់ពីបរទេសដើម្បីស្វែងរកទីផ្សារ គឺជាការស្វែងរកទីតាំងភូមិសាស្ត្រនៅកណ្តាល ដែលអាចផ្តល់ឱកាសងាយស្រួល ដើម្បីចូលទៅក្នុងទីផ្សារ។

យ៉ាងណាមិញ តាមលោក Narula ការវិនិយោគស្វែងរកទីផ្សារ គឺត្រូវបានលើកទឹកចិត្ត ប្រសិនបើក្នុងប្រទេសដើមកំណើតរបស់ក្រុមហ៊ុនជាប់មានរបាំងពាណិជ្ជកម្មណាមួយនោះ ឬក៏ប្រទេសទទួលការវិនិយោគបានបើកទូលាយផ្តល់នូវការស្វាគមន៍ និងបានផ្តល់នូវឱកាសវិនិយោគជាមួយនឹងការលើកទឹកចិត្តផ្សេងៗ ដើម្បីធានានូវភាពរីកចម្រើនលូតលាស់។ នៅពេលដែលគេនិយាយពីការស្វែងរកទីផ្សាររបស់ក្រុមហ៊ុនសាអាជីវកម្ម

[15] *Understanding the Workings of Foreign Direct Investment, Types of FDI. Downloaded on 20 May 2022 at 10:00AM.* https://tradesmartonline.in/knowledge-hub/stock-market/types-of-fdi/

[16] *Market-seeking Investment (Foreign Direct Investment in the Transition Economies. mht)*

[17] *Market-seeking Investment (Foreign Direct Investment in the Transition Economies. mht)*

ពហុជាតិ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ការជ្រើសរើសទីតាំងសម្រាប់វិនិយោគ គឺជាទូទៅត្រូវបានពន្យល់ដោយឱកាសផលិតកម្មនៅក្នុងប្រទេស ដែលទទួលការវិនិយោគ ដោយមើលឃើញពីតម្រូវការក្នុងស្រុក និងក្រៅស្រុករបស់ប្រទេសនោះ។ ដូច្នេះ ការស្វែងរកទីផ្សារនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ គឺដើម្បីទទួលបាននូវអត្ថប្រយោជន៍ពីការអនុគ្រោះពន្ធសម្រាប់ប្រទេសចំណូលទាប ដើម្បីឆក់យកឱកាសពីការអនុគ្រោះពន្ធទាំងនោះ។

**៣.៤.២.២ ការវិនិយោគដើម្បីនាំចេញ** (Export Seeking Investment)

ការវិនិយោគដើម្បីនាំចេញជាទូទៅត្រូវបានពន្យល់ ដោយលោក Reuber គឺជាប្រភេទវិនិយោគដែលស្វែងរកនូវទីកន្លែង ដែលមានកត្តាពលកម្មតម្លៃថោក និងសំបូរបែបដើម្បីងាយស្រួលក្នុងការផលិតនូវទំនិញសម្រេចមានតម្លៃទាប ដែលផ្តល់នូវភាពងាយស្រួលក្នុងការប្រកួតប្រជែងនាំចេញក្នុងទីផ្សារអន្តរជាតិ។ មួយវិញទៀត ការវិនិយោគសម្រាប់ការនាំចេញជារឿយៗ គេមិនសំដៅទៅលើទីផ្សារនៅក្នុងប្រទេស ដែលគេធ្វើការវិនិយោគនោះទេ ប៉ុន្តែគេសង្កត់ធ្ងន់ទៅលើទីផ្សារខាងក្រៅ ប្រទេសទាំងអស់នោះ គឺសំដៅលើប្រទេសនៅជុំវិញ និងប្រទេសមានទំនាក់ទំនងជាមួយប្រទេសដែលគេធ្វើការវិនិយោគនោះ។ ជាទូទៅ តម្រូវការក្នុងស្រុករបស់ប្រទេសកំពុងអភិវឌ្ឍន៍មានទំហំតូច តែវាមិនមែនជាបញ្ហាដល់ការវិនិយោគផ្ទាល់ពីបរទេសនោះទេ។ នៅពេលប្រទេសទទួលវិនិយោគមានការបើកចំហទីផ្សារ លំហូរការវិនិយោគផ្ទាល់ពីបរទេសនៅក្នុងប្រទេសនោះ វាផ្តោតទៅលើការធ្វើពាណិជ្ជកម្មជាមួយប្រទេសជាដៃគូ។ ដូច្នេះ ប្រទេសដែលទទួលការវិនិយោគ គឺតម្រូវឲ្យមានទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិល្អ។

**៣.៤.២.៣ ការវិនិយោគស្វែងរកធនធាន** (Resource Seeking Investment)

ការវិនិយោគស្វែងរកធនធាន គឺជាការវិនិយោគដែលផ្តោតសំខាន់ទៅលើភាពសម្បូរបែបនៃវត្ថុធាតុដើម កម្លាំងពលកម្មទាំងមានជំនាញ និងគ្មានជំនាញបច្ចេកទេស និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៅក្នុងប្រទេសដែល FDI ធ្វើការវិនិយោគ។ យោងតាមលោក Rajneesh Narula បានបែងចែកក្រុមហ៊ុនសាអាជីវកម្មបែបស្វែងរកធនធានជាបីប្រភេទ៖ ក្រុមទីមួយ ជាក្រុមស្វែងរកធនធានរូបវន្តមានដូចជា ប្រេង រ៉ែ វត្ថុធាតុដើម និងផលិតផលកសិកម្ម។ ក្រុមទីពីរ ជាក្រុមស្វែងរកកម្លាំងពលកម្មតម្លៃថោកជាទូទៅ គឺពលកម្មគ្មានជំនាញ។ ចំណែកឯ ក្រុមទីបី ជាក្រុមចុងក្រោយ ដែលជាប្រភេទស្វែងរកនូវបច្ចេកទេសនៃការគ្រប់គ្រង ឬជំនាញផ្សព្វផ្សាយទីផ្សារផ្សេងៗ។

ទោះបីជាយ៉ាងណាក៏ដោយ ការវិនិយោគផ្ទាល់ពីបរទេសតាមបែបខាងលើនេះអាចនឹងធ្វើឲ្យមានភាពសឹករិចរិលនូវធនធាន។ បើតាមលោក Rajneesh Narula ក្នុងតំបន់មានលទ្ធភាពផ្គត់ផ្គង់នូវធនធានកម្ររាជរដ្ឋាភិបាលតំបន់នោះមានលទ្ធភាពខ្ពស់ក្នុងការចរចា ហើយនៅពេលមានការចំណាយក្នុងការទាញយកធនធានកម្រនោះ គឺមានតែលើកិច្ចសន្យាជាមួយនឹងរដ្ឋាភិបាល និងចំណាយលើការរុករក នោះក្រុមហ៊ុនវិនិយោគ

ផ្ទាល់ពីបរទេសនឹងទទួលបាននូវផលចំណេញក្នុងកម្រិតខ្ពស់។ ហើយចំពោះប្រទេសទទួលការវិនិយោគ ក៏ទទួលបាននូវផលចំណេញពីការវិនិយោគនេះផងដែរ ពោលគឺការចំណេញផ្នែកបច្ចេកទេស ភាពមានការងារ បូករួមនឹងការទាញយកធនធានទាំងនោះយកមកប្រើប្រាស់ ព្រោះថាបើគ្មានការវិនិយោគផ្ទាល់ពីបរទេសនោះទេ ធនធានកម្រទាំងនោះនឹងត្រូវកប់ចោល ដោយមិនអាចយកមកប្រើប្រាស់បាននោះទេ។

### ៣.៤.៣ ការកំណត់ដោយរដ្ឋាភិបាលកម្ពុជា ទៅលើការវិនិយោគផ្ទាល់ពីបរទេស

#### ៣.៤.៣.១ គោលនយោបាយ និងបទប្បញ្ញត្តិស្តីពីការវិនិយោគផ្ទាល់ពីបរទេស (FDI)

សេដ្ឋកិច្ចប្រទេសកម្ពុជាទទួលបានលទ្ធផលដ៏គួរឲ្យជាទីមោទនៈ ដែលឆ្លុះបញ្ចាំងចេញពីកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស និងការកាត់បន្ថយភាពក្រីក្រគួរឲ្យកត់សម្គាល់។[18] មួយផ្នែកនៃជោគជ័យនេះ គឺជាលទ្ធផលនៃការបើកចំហទីផ្សាររបស់ប្រទេសកម្ពុជា ឆ្ពោះទៅកាន់វិនិយោគិនបរទេស។ ការវិនិយោគក្នុងស្រុកក៏មានការកើនឡើងផងដែរ បើទោះបីជាមានអត្រាទាបជាងប្រទេសដទៃទៀតនៅក្នុងតំបន់ និងប្រទេសផ្សេងៗទៀតដែលមានកម្រិតអភិវឌ្ឍន៍ដូចគ្នាក៏ដោយ ។

ប្រទេសកម្ពុជាបានដាក់គោលដៅនៅក្នុងយុទ្ធសាស្ត្រជាតិរបស់ខ្លួន ក្នុងការក្លាយជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់គិតត្រឹមឆ្នាំ2030 និងទទួលបានឋានៈជាប្រទេសមានប្រាក់ចំណូលខ្ពស់គិតត្រឹមឆ្នាំ2050 ។ ដើម្បីសម្រេចបាននូវគោលដៅ និងផែនការដទៃទៀតប្រទេសកម្ពុជាបានបន្តរក្សាបើកចំហសេដ្ឋកិច្ចរបស់ខ្លួន ដោយផ្តល់ឱកាសវិនិយោគ ដែលមានសក្តានុពលទៅដល់វិនិយោគិនបរទេស។ គោលបំណង គឺដើម្បីបង្កើនពាណិជ្ជកម្មអន្តរជាតិ ការផ្លាស់ប្តូរទំនិញ និងសេវាកម្មជាមួយទីផ្សារនៅក្នុងតំបន់ និងបណ្តាប្រទេសនៅលើពិភពលោកដទៃផ្សេងៗទៀត។ ការអនុវត្តគោលការណ៍សេដ្ឋកិច្ចទីផ្សារសេរី និងស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ក៏ផ្តល់បរិយាកាសវិនិយោគ ដែលមានភាពទាក់ទាញសម្រាប់ប្រទេសកម្ពុជាផងដែរ។ ប្រទេសកម្ពុជាទទួលបានលទ្ធផលល្អក្នុងការទាក់ទាញវិនិយោគិនពីបរទេសដោយសារ ទំហំសេដ្ឋកិច្ចរបស់ខ្លួនបើទោះបីជាការវិនិយោគផ្ទាល់ពីបរទេស (FDI) នៅតែផ្តោតសំខាន់ខ្លាំងទៅលើតែវិស័យមួយចំនួនយ៉ាងណាក៏ដោយ ជាឧទាហរណ៍៖ គឺវិស័យវាយនភណ្ឌ។ ដូចប្រទេសដទៃទៀតនៅក្នុងតំបន់ដែរ លំហូរវិនិយោគផ្ទាល់ពីបរទេសមកក្នុងប្រទេសកម្ពុជាបានកើនឡើងគួរឱ្យកត់សម្គាល់បន្ទាប់ពីបានចូលរួមជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក (WTO) នៅក្នុងឆ្នាំ2004 ។

---

[18] *អង្គការទិន្នន័យអំពីការអភិវឌ្ឍស្តីអំពី៖ គោលនយោបាយ និងបទប្បញ្ញត្តិស្តីពីការវិនិយោគ។ បានទាញយកនៅថ្ងៃទី22 ខែឧសភា ឆ្នាំ2022 ម៉ោង 8:00 ព្រឹក។*
https://opendevelopmentcambodia.net/km/topics/investment-policy-and-regulation/

### ៣.៤.៣.២ ច្បាប់ស្តីពីការវិនិយោគផ្ទាល់ពីបរទេស (FDI) នៃព្រះរាជាណាចក្រកម្ពុជា

យោងទៅតាមក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ស៊ីឌីស៊ី) ការបង្កើតច្បាប់ និងបទប្បញ្ញត្តិនានា ដែលគ្រប់គ្រងលើការវិនិយោគផ្ទាល់ពីបរទេសនៅក្នុងប្រទេសកម្ពុជា ដែលមានគោលបំណងជំរុញដល់ការវិនិយោគ។ ដូចដែលបានចែងនៅក្នុងច្បាប់ស្តីពីការវិនិយោគ ទុនវិនិយោគផ្ទាល់ពីបរទេសនៅក្នុងប្រទេសកម្ពុជាត្រូវបានបើកចំហ ហើយការវិនិយោគត្រូវបានអនុញ្ញាតនៅក្នុងវិស័យជាច្រើន លើកលែងតែកម្មសិទ្ធិដីធ្លី។ លើសពីនេះទៅទៀតវិនិយោគិន ក៏មានសិទ្ធិទទួលបាននូវការលើកទឹកចិត្តផ្សេងៗទៀតផងដែរ។[19] ច្បាប់ស្តីពីការវិនិយោគដំបូងបង្អស់នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានតាក់តែងឡើងក្នុងឆ្នាំ1994 ។ ច្បាប់ទាំងនោះមានទាំងអស់ ៩ ជំពូក និង ២៦ មាត្រា ដោយផ្តោតសំខាន់ក្នុងការផ្តល់ភាពងាយស្រួលទៅដល់វិនិយោគិន។ ច្បាប់នេះដែរបានចែងពីបទប្បញ្ញត្តិទូទៅដូចជានីតិវិធីសម្រាប់ការវិនិយោគ និងការទទួលបានសិទ្ធិព្រមទាំងការធានាសម្រាប់វិនិយោគិន។ មិនតែប៉ុណ្ណោះ វាក៏បានបង្ហាញពីវិស័យ ដែលរដ្ឋាភិបាលបានលើកទឹកចិត្តឲ្យមានការវិនិយោគផងដែរ។[20]

នៅក្នុងឆ្នាំ2003 ច្បាប់ថ្មីមួយត្រូវបានធ្វើវិសោធនកម្មទៅលើមាត្រាខ្លះៗនៃច្បាប់ស្តីពីការវិនិយោគនៅក្នុងឆ្នាំ1994 ដោយបានកែប្រែធ្វើឲ្យវាកាន់តែមានភាពច្បាស់លាស់ និងទូលំទូលាយជាងមុន។ ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីអំពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជានេះ បានបញ្ជាក់ឲ្យកាន់តែច្បាស់ជាងមុនអំពីវិសាលភាព នីតិវិធី និងលក្ខណៈសម្បត្តិ ដែលអាចវិនិយោគបាននៅលើទឹកដីប្រទេសកម្ពុជា។ ច្បាប់នេះក៏មានគោលបំណងដើម្បីជំរុញដល់ការវិនិយោគបន្ថែមទៀត និងបង្កើតឲ្យមានតុល្យភាពត្រឹមត្រូវសម្រាប់ការវិនិយោគនៅកម្ពុជា។ បន្ថែមពីលើនេះ គឺមានការលើកទឹកចិត្តបន្ថែមទៀតសម្រាប់វិនិយោគិន និងយន្តការដោះស្រាយវិវាទផ្សេងៗ ជាក់ស្តែងទទួលបានការមិនបាច់បង់ពន្ធក្នុងរយៈពេលកំណត់ណាមួយ (automatic tax holiday) ការ

[19] *ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាស្តីអំពី៖ « គម្រោង វិនិយោគ ៖ នីតិវិធីនៃការដាក់ពាក្យស្នើសុំវិនិយោគ » ឆ្នាំ 2020 ។ បានទាញយកនៅថ្ងៃទី22 ខែឧសភា ឆ្នាំ2022 ម៉ោង 8:30 ព្រឹក។*

http://www.cambodiainvestment.gov.kh/investment-scheme/investment-application-procedures.html

[20] *ក្រុមប្រឹក្សាសម្រាប់ការអភិវឌ្ឍកម្ពុជា ច្បាប់ស្តីអំពី៖ ការវិនិយោគឆ្នាំ 1994 ថ្ងៃទី05 ខែ សីហា ឆ្នាំ១៩៩៤ ។ បានទាញយកនៅថ្ងៃទី22 ខែឧសភា ឆ្នាំ2022 ម៉ោង 9:00 ព្រឹក។*

https://data.opendevelopmentcambodia.net/en/dataset/law-on-investment-in-the-kingdom-of-cambodia

លើកលែងពន្ធលើការនាំចូល 100% ការធានាប្រឆាំងនឹងការធ្វើជាតូបនីយកម្ម កែប្រែថ្មីឡើងវិញលើកិច្ចសន្យាជួលដីរហូតដល់ 99 ឆ្នាំលើដីសម្បទានសម្រាប់គោលបំណងកសិកម្ម និងមានជាច្រើនទៀត។[21]

ក្រោយមកនៅក្នុងឆ្នាំ2005 អនុក្រឹតលេខ ១១១ ស្តីពីច្បាប់វិសោធនកម្មនៃច្បាប់ស្តីពីការវិនិយោគនៃព្រះរាជាណាចក្រកម្ពុជាបានប្រកាសដាក់ឲ្យប្រើប្រាស់។ ច្បាប់នេះមានគោលបំណងបំពេញបន្ថែម និងអនុវត្តលើច្បាប់វិនិយោគ ដើម្បីលើកកម្ពស់បន្ថែមទៀតលើការវិនិយោគក្នុងប្រទេសពីសំណាក់វិនិយោគិនទាំងក្នុងស្រុក និងបរទេស។ អនុក្រឹត្យនេះបានបញ្ជាក់ឲ្យកាន់តែច្បាស់អំពីស្ថានភាពគម្រោងវិនិយោគ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIP) ដែលវិនិយោគិនទាំងអស់គឺត្រូវតែដាក់ពាក្យស្នើសុំ ដើម្បីទទួលបាននូវការលើកទឹកចិត្តវិនិយោគ។[22] យោងទៅតាមច្បាប់ស្តីពីវិសោធនកម្មស្តីពីការវិនិយោគនៅឆ្នាំ2003 (ស៊ីឌីស៊ី) បានដើរតួជាអង្គការសេវាកម្មច្រកចេញចូលតែមួយ ដែលទទួលខុសត្រូវក្នុងការវាយតម្លៃ និងធ្វើការសម្រេចចិត្តលើការវិនិយោគ និងការស្តារនីតិសម្បទា ការអភិវឌ្ឍ និងការត្រួតពិនិត្យសកម្មភាពវិនិយោគ។ វិនិយោគិនត្រូវដាក់សំណើវិនិយោគរបស់ខ្លួនទៅខាង(ស៊ីឌីស៊ី) ឬអនុគណៈកម្មាធិការវិនិយោគខេត្តក្រុង ដើម្បីទទួលបានឋានៈជាគម្រោងវិនិយោគ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIP) ដែលអាស្រ័យទៅលើកម្រិតដើមទុន និងទីតាំងនៃការវិនិយោគ។

នៅថ្ងៃទី15 ខែតុលា ឆ្នាំ2021 ច្បាប់ស្តីពីវិនិយោគត្រូវបានអនុម័តដាក់ឲ្យប្រើជំនួសច្បាប់ពីវិនិយោគឆ្នាំ1994 និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគឆ្នាំ2003 និងសម្រាប់ប្រទេសកម្ពុជា ដើម្បីបង្កើតក្របខ័ណ្ឌគតិយុត្ត ដែលបើកចំហឲ្យមានតម្លាភាពអាចប៉ាន់ប្រមាណជាមុនបាន និងមានអំណោយផល ដើម្បីលើកកម្ពស់ និងទាក់ទាញការវិនិយោគប្រកបដោយគុណភាព ប្រសិទ្ធភាព និងប្រសិទ្ធផល ដោយវិនិយោគិនក្នុងស្រុក និងអន្តរជាតិ។ ច្បាប់នេះមាន ១២ ជំពូក និង ៤២ មាត្រា ដែលផ្តោតលើការកែលម្អការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនៅកម្ពុជា តាមរយៈការបង្កើនសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា ការធ្វើទំនើបកម្ម និងការបង្កើនផលិតភាពនៃឧស្សាហកម្មក្នុងស្រុក ការបង្កើតរបបលើកទឹកចិត្តវិនិយោគ និងការផ្តល់សិទ្ធិការការពារដល់ផលប្រយោជន៍

[21] *សន្និសិទអង្គការសហប្រជាជាតិស្តីអំពី៖ ពាណិជ្ជកម្ម និងការអភិវឌ្ឍ (UNCTAD) មគ្គុទេសក៍ការវិនិយោគសំរាប់ប្រទេសកម្ពុជា៖ ឱកាស និងលក្ខខណ្ឌ (ខែកញ្ញា ឆ្នាំ2003) ។ បានទាញយកនៅថ្ងៃទី22 ខែឧសភា ឆ្នាំ2022 ម៉ោង 9:30 ព្រឹក។* https://unctad.org/en/docs/iteiia20036_en.pdf

[22] *ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា៖ អនុក្រឹត្យលេខ ១១១ ស្តីពីច្បាប់វិសោធនកម្មច្បាប់វិនិយោគ (ថ្ងៃទី26 ខែតុលា ឆ្នាំ2011 ។ បានទាញយកនៅថ្ងៃទី22 ខែឧសភា ឆ្នាំ2022 ម៉ោង 10:00 ព្រឹក។* https://data.opendevelopmentmekong.net/laws_record/sub-decree-on-the-implementation-of-the-law-on-the-amendment-of-the-law-on-investment

ស្របច្បាប់របស់អ្នកវិនិយោគ។[23] ច្បាប់នេះមានបំណងធ្វើឲ្យប្រទេសកម្ពុជាកាន់តែមានភាពទាក់ទាញតាមរយៈការផ្តល់នូវ ការលើកទឹកចិត្ត ការធានា និងការការពារបន្ថែមទៀតសម្រាប់អ្នកវិនិយោគក្នុងស្រុក និងបរទេសស្របតាមច្បាប់ និងស្តង់ដារអន្តរជាតិ។ ច្បាប់វិនិយោគថ្មីផងដែរ ក៏មានលក្ខណៈពិសេសសំខាន់ៗចំនួន ៥ ។[24] ទី១ អនុញ្ញាតឲ្យចុះឈ្មោះសម្រាប់គម្រោងវិនិយោគថ្មីពីរប្រភេទ។ ទី២ ការធានា និងការការពារទៅលើការវិនិយោគ។ ទី៣ ការលើកទឹកចិត្តសម្រាប់វិស័យវិនិយោគ និងសកម្មភាពផ្សេងៗមួយចំនួនទៀត។ ទី៤ ការលើកទឹកចិត្តនៅក្នុងការវិនិយោគសម្រាប់ គ.ល.គ។ ទី៥ ការអនុម័តសម្រាប់ការវិនិយោគឯកជន និងការដោះស្រាយវិវាទ។

### ៣.៤.៣.៣ ការជម្រុញពីរដ្ឋាភិបាលក្នុងការលើកទឹកចិត្តដល់ការវិនិយោគផ្ទាល់ពីបរទេស

យោងទៅតាមមាត្រាទី២៤ នៃជំពូកទី៦ ក្នុងច្បាប់វិនិយោគថ្មីនៃព្រះរាជាណាចក្រកម្ពុជា វិស័យវិនិយោគចំនួន ១៩ អាចនឹងត្រូវទទួលបានការលើកទឹកចិត្តដូចខាងក្រោម៖

1) ឧស្សាហកម្មដែលមានបច្ចេកវិទ្យាខ្ពស់ ប្រកបដោយនវានុវត្តន៍ ការស្រាវជ្រាវ និងអភិវឌ្ឍន៍
2) ឧស្សាហកម្ម ឬកម្មន្តសាលថ្មីៗ ផ្តល់តម្លៃបន្ថែមខ្ពស់ មាននវានុវត្តន៍ និងភាពប្រកួតប្រជែងខ្ពស់
3) ឧស្សាហកម្មបម្រើឲ្យខ្សែច្រវាក់ផលិតកម្មក្នុងតំបន់ និងសកលលោក
4) ឧស្សាហកម្មគាំទ្រពាក់ព័ន្ធនឹងវិស័យកសិកម្ម ទេសចរណ៍ កម្មន្តសាល ឧស្សាហកម្មបម្រើឲ្យខ្សែច្រវាក់ផលិតកម្មតំបន់ សកលលោក និងឧស្សាហកម្មតភ្ជាប់បណ្តាញផ្គត់ផ្គង់
5) ឧស្សាហកម្មគ្រឿងអគ្គិសនី និងអេឡិចត្រូនិក
6) ឧស្សាហកម្មគ្រឿងបន្លាស់ បង្គុំ និងតម្លើង
7) ឧស្សាហកម្មមេកានិក និងគ្រឿងម៉ាស៊ីន
8) កសិកម្ម កសិឧស្សាហកម្ម ឧស្សាហកម្មកែច្នៃផលិតផលកសិកម្ម ឧស្សាហកម្មកែច្នៃចំណីអាហារ ដែលបម្រើទីផ្សារក្នុងស្រុក ឬការនាំចេញ

[23] *ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាច្បាប់ស្តីអំពី៖ វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា បានចុះនៅថ្ងៃទី15 ខែតុលា ឆ្នាំ2021 (ទំព័រទី១)។ បានទាញយកនៅថ្ងៃទី22 ខែឧសភា ឆ្នាំ2022 ម៉ោង 11:00 ព្រឹក។*
https://data.opendevelopmentcambodia.net/en/laws_record/law-on-the-investment-of-the-kingdom-of-cambodia

[24] Siphana Sok *និង* Soromnear Sin *(កម្ពុជាអនុម័តច្បាប់ថ្មីស្តីពីការវិនិយោគ)* SokSiphana *&* associates *ចុះនៅថ្ងៃទី8 ខែធ្នូ ឆ្នាំ2021 ។ ឯកសារនេះជាភាសាអង់គ្លេស ដោយពុំមានការបកប្រែជាភាសាខ្មែរ។ បានទាញយកនៅថ្ងៃទី22 ខែឧសភា ឆ្នាំ2022 ម៉ោង 11:30 ព្រឹក។* https://www.soksiphana.com/resources/alerts/cambodia-adopts-newlawoninvestment/#:~:text=On%2015%20October%202021%2C%20Cambodia,efficiency%20of%20investments%20in%20Cambodia

9) សហគ្រាសធុនតូច និងមធ្យមក្នុងវិស័យអាទិភាព និងការអភិវឌ្ឍបណ្តុំសហគ្រាសធុនតូច និងមធ្យម បណ្តុំឧស្សាហកម្ម និងបណ្តុំវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

10) ឧស្សាហកម្មទេសចរណ៍ និងសកម្មភាពពាក់ព័ន្ធនឹងទេសចរណ៍

11) ការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស

12) ឧស្សាហកម្មឌីជីថល

13) ការវិនិយោគក្នុងវិស័យអប់រំ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការជំរុញផលិតភាព

14) ការវិនិយោគក្នុងវិស័យសុខាភិបាល

15) ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

16) ការវិនិយោគក្នុងវិស័យឡូជីស្ទីក

17) ការវិនិយោគក្នុងការគ្រប់គ្រង ការការពារបរិស្ថាន និងការអភិរក្សជីវៈចម្រុះ និងសេដ្ឋកិច្ចចក្រា

18) ការវិនិយោគក្នុងវិស័យថាមពលបៃតង បច្ចេកវិទ្យាដែលរួមចំណែកដល់ការបន្សាំ និងជួយដល់ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ

19) វិស័យ និងសកម្មភាពវិនិយោគផ្សេងៗទៀតដែលមិនមានចែងក្នុងច្បាប់នេះ ក្នុងករណីដែលរាជរដ្ឋាភិបាលយល់ឃើញថាមានសក្តានុពលដល់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច។[25]

លើសពីនេះទៅទៀត ការលើកទឹកបានផ្តល់ជម្រើសជាច្រើនផងដែរទៅដល់វិនិយោគិន ដែលធ្វើការវិនិយោគផ្ទាល់ពីបរទេសដូចជា៖

| ការលើកទឹកចិត្តជាមូលដ្ឋាន | ការលើកទឹកចិត្តបន្ថែម | ការលើកទឹកចិត្តពិសេស |
|---|---|---|
| ជម្រើសទី១៖ ការលើកលែងពន្ធលើប្រាក់ចំណូល។ | ការលើកលែងអាករលើតម្លៃបន្ថែម។ | វិស័យជាក់លាក់ណាមួយ ដែលមានសក្តានុពលខ្ពស់។ |
| ជម្រើសទី២៖ ការរំលស់ពិសេស។ | ការកាត់កងចំណាយក្នុងអត្រា 150% ពីមូលដ្ឋានគិតពន្ធ។ | សកម្មភាពវិនិយោគជាក់លាក់ ដែលមានសក្តានុពលខ្ពស់។ |

ការលើកទឹកចិត្តជាមូលដ្ឋាន គឺជាសកម្មភាពវិនិយោគដែលបានចុះបញ្ជីជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (គ.ល.គ.) មានសិទ្ធិជ្រើសរើសជាកញ្ចប់លើកទឹកចិត្តជាមូលដ្ឋានជា ២ ជម្រើស។

[25] *Under the LoI (Chapter 6), 19 investment sectors (listed in Article 24 of the LoI). Downloaded on 23 May 2022 at 6:00PM.* https://cdc.gov.kh/incentives-and-schemes/

ជម្រើសទី១៖ ការលើកលែងពន្ធលើប្រាក់ចំណូល គឺជាការលើកលែងពន្ធលើប្រាក់ចំណូលសម្រាប់រយៈពេលពី 3 ទៅ 9 ឆ្នាំ ទៅតាមវិស័យ និងសកម្មភាពវិនិយោគ គិតចាប់ពីពេលទទួលបានប្រាក់ចំណូលលើកដំបូង។ វិស័យ និងសកម្មភាពវិនិយោគ ព្រមទាំងរយៈពេលលើកលែងពន្ធលើប្រាក់ចំណូលនឹងត្រូវកំណត់ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង និងឬអនុក្រឹត្យ។ បន្ទាប់ពីផុតរយៈពេលលើកលែងពន្ធលើប្រាក់ចំណូល គ.ល.គ. មានសិទ្ធិទទួលបានការលើកទឹកចិត្តឲ្យបង់ពន្ធលើប្រាក់ចំណូលតាមអត្រាកំណើនតាមពេល ធៀបទៅនឹងប្រាក់ពន្ធត្រូវបង់សរុបដូចតទៅ 25% សម្រាប់ 2 ឆ្នាំដំបូង 50% សម្រាប់ 2 ឆ្នាំបន្ទាប់ និង 75% សម្រាប់ 2 ឆ្នាំចុងក្រោយ។ លើសពីនេះទៀតជម្រើសនេះរួមបញ្ចូល ការលើកលែងប្រាក់រំដោះពន្ធលើប្រាក់ចំណូលក្នុងអំឡុងពេលលើកលែងពន្ធលើប្រាក់ចំណូល ការលើកលែងពន្ធអប្បបរមា ដោយត្រូវមានរបាយការណ៍សវនកម្មឯករាជ្យ ការលើកលែងអាករនាំចេញ លើកលែងតែមានចែងដោយឡែកនៅក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត។ ជម្រើសទី២៖ ការរំលស់ពិសេស គឺជាសិទ្ធិកាត់កងចំណាយមូលធនតាមរយៈការរំលស់ពិសេស ដែលមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន សិទ្ធិកាត់កងរហូតដល់ 200% លើចំណាយជាក់លាក់ផ្សេងទៀតសម្រាប់រយៈពេលរហូតដល់ 9 ឆ្នាំ។ វិស័យ និងសកម្មភាពវិនិយោគ និងចំណាយជាក់លាក់ ព្រមទាំងរយៈពេលកាត់កងចំណាយត្រូវកំណត់ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រង និងឬអនុក្រឹត្យ ជាពិសេសការលើកលែងប្រាក់រំដោះពន្ធលើប្រាក់ចំណូលក្នុងរយៈពេលជាក់លាក់ណាមួយទៅតាមវិស័យ និងសកម្មភាពវិនិយោគដែលត្រូវកំណត់ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង និងឬអនុក្រឹត្យ ការលើកលែងពន្ធអប្បបរមាដោយត្រូវមានរបាយការណ៍សវនកម្មឯករាជ្យ ការលើកលែងអាករនាំចេញ លើកលែងតែមានចែងដោយឡែកនៅក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត។

ការលើកទឹកចិត្តបន្ថែម គឺជាការលើកលែងអាករលើតម្លៃបន្ថែមចំពោះការទិញធាតុចូលផលិតកម្មដែលផលិតក្នុងស្រុកសម្រាប់បម្រើដល់ការអនុវត្ត គ.ល.គ. ការលើកលែងពន្ធលើប្រាក់ចំណូលចំពោះការពង្រីក គ.ល.គ. ដែលត្រូវកំណត់ដោយអនុក្រឹត្យ ដែលកាត់កងចំណាយក្នុងអត្រា 150% ពីមូលដ្ឋានគិតពន្ធចំពោះសកម្មភាពណាមួយដូចខាងក្រោម៖

- ការស្រាវជ្រាវអភិវឌ្ឍន៍ និងនវានុវត្តន៍
- ការអភិវឌ្ឍធនធានមនុស្ស តាមរយៈការផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងជំនាញដល់កម្មករនិយោជិតខ្មែរ
- ការសាងសង់កន្លែងស្នាក់នៅ កន្លែងបរិភោគអាហារ ឬអាហារដ្ឋានតម្លៃសមរម្យ ទារកដ្ឋាន និងសុខុបត្ថម្ភវត្ថុដទៃទៀតសម្រាប់ កម្មករ ឬនិយោជិត
- ការធ្វើទំនើបកម្មលើគ្រឿងម៉ាស៊ីនដើម្បីបម្រើខ្សែច្រវាក់ផលិតកម្ម និង

- ការផ្តល់ការលើកកម្ពស់សុខុមាលភាពដល់កម្មករនិយោជិតខ្មែរ ដូចជាការផ្តល់មធ្យោបាយដឹកជញ្ជូនប្រកបដោយផាសុខភាពដល់កម្មករនិយោជិត ក្នុងការធ្វើដំណើរទៅមកពីកន្លែងស្នាក់នៅទៅរោងចក្រ កន្លែងស្នាក់នៅ កន្លែងបរិភោគអាហារ ឬអាហារដ្ឋានដែលមានតម្លៃសមរម្យ ទារកដ្ឋាន និងសុខុបត្ថម្ភវត្ថុដទៃទៀត

ការលើកទឹកចិត្តពិសេស គឺជាវិស័យ និងសកម្មភាពវិនិយោគជាក់លាក់ណាមួយ ដែលមានសក្តានុពលខ្ពស់ក្នុងការរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ អាចទទួលការលើកទឹកចិត្តពិសេសដោយឡែកផ្សេងទៀត ដែលត្រូវកំណត់នៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង។

### ៣.៤.៤ ប្រភេទនៃការវិនិយោគផ្ទាល់ពីបរទេស (FDI) នៅក្នុងប្រទេសកម្ពុជា

#### ៣.៤.៤.១ បណ្តាប្រទេសផ្សេងៗ ដែលវិនិយោគនៅក្នុងប្រទេសកម្ពុជា

គិតមកដល់ត្រឹមឆ្នាំ2019[26] បណ្តាប្រទេសដែលធ្វើការវិនិយោគនៅក្នុងប្រទេសកម្ពុជា បើយោងតាមទិន្នន័យរបស់ធនាគារពិភពលោកបានអនុម័តមានចំនួនច្រើនជាងគេលំដាប់ទីមួយ គឺប្រទេសចិន ដែលមានចំនួនរហូតដល់ទៅ 9,731.40 លានដុល្លារអាមេរិក (ភាគហ៊ុននៃការវិនិយោគ) និង 1,112.40 លានដុល្លារអាមេរិក (លំហូរចូលនៃការវិនិយោគ)។ ទីពីរ គឺប្រទេសកូរ៉េ ដែលមានចំនួនរហូតដល់ទៅ 3,790.60 លានដុល្លារអាមេរិក (ភាគហ៊ុននៃការវិនិយោគ) និង 248.00 លានដុល្លារអាមេរិក (លំហូរចូលនៃការវិនិយោគ)។ ទីបី គឺហុងកុង ដែលមានចំនួន 2,967.80 លានដុល្លារអាមេរិក (ភាគហ៊ុននៃការវិនិយោគ) និង 399.30 លានដុល្លារអាមេរិក (លំហូរចូលនៃការវិនិយោគ)។ ទីបួន គឺប្រទេសវៀតណាម ជាប្រទេសនៅក្នុងតំបន់អាស៊ានមួយ ក៏ដូចជាប្រទេសជិតខាងរបស់ប្រទេសកម្ពុជាផងដែរ ដែលធ្វើការវិនិយោគផ្ទាល់មកប្រទេសកម្ពុជា ដែលមានចំនួន 2,368.00 លានដុល្លារអាមេរិក (ភាគហ៊ុននៃការវិនិយោគ) និង 184.90 លានដុល្លារ (លំហូរចូលនៃការវិនិយោគ)។ លើសពីនេះទៅទៀត ក៏មានប្រទេសមួយចំនួនទៀតធ្វើការវិនិយោគនៅប្រទេសកម្ពុជា ដែលមានបង្ហាញក្នុងតារាងទី៦ ។

[26] *ដកស្រង់ពី៖ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ (Ministry of Foreign Affairsand International Cooperation)។ ស្តីពី ការវិនិយោគផ្ទាល់ពីបរទេសរបស់បណ្តាប្រទេសផ្សេងៗ។ បានទាញយកនៅថ្ងៃទី28 ខែឧសភា ឆ្នាំ 2022 ម៉ោង 9:00 ព្រឹក។* https://data.opendevelopmentcambodia.net/km/dataset/dashboard-series-about-cambodia/resource/ac3ffd22-e65c-4e5b-b474-dfc840016318/view/de5b84e2-2c01-4604-8a24-d11e64e47ecd

## តារាងទី៦៖ ការវិនិយោគតាមប្រទេស (ភាគហ៊ុន) និង (លំហូរ) គិតជាលានដុល្លារ

| Country | 2016 | | 2017 | | 2018 | | 2019 | | Share % | |
|---|---|---|---|---|---|---|---|---|---|---|
| | Stock | Flow | Stock | Flow | Stock | Flow | Stock | Flow | Stock | Flow |
| China | 7,260.20 | 603.80 | 7,894.50 | 634.80 | 8,618.30 | 798.20 | 9,731.40 | 1,112.40 | 28.60% | 30.02% |
| R.O.K | 3,041.80 | 138.40 | 3,216.70 | 177.20 | 3,546.00 | 249.90 | 3,790.60 | 248.00 | 11.14% | 6.69% |
| Hong Kong | 1,792.10 | 248.20 | 2,175.30 | 347.30 | 2,568.50 | 349.00 | 2,967.80 | 399.30 | 8.72% | 10.77% |
| Viet Nam | 1,904.70 | 192.20 | 1,912.80 | 127.20 | 2,186.10 | 165.90 | 2,368.00 | 184.90 | 6.96% | 4.99% |
| Singapore | 1,264.10 | 175.00 | 1,432.60 | 178.10 | 1,759.30 | 227.70 | 2,031.50 | 263.40 | 5.97% | 7.11% |
| Japan | 1,303.90 | 255.40 | 1,527.80 | 226.60 | 1,842.90 | 199.20 | 2,022.90 | 179.30 | 5.94% | 4.84% |
| Chinese Taipei | 1,415.00 | 104.70 | 1,594.30 | 168.70 | 1,750.70 | 121.60 | 1,965.10 | 214.20 | 5.77% | 5.78% |
| Malaysia | 1,223.10 | 98.90 | 1,377.20 | 145.00 | 1,524.00 | 157.80 | 1,678.40 | 160.60 | 4.93% | 4.33% |
| Thailand | 1,114.10 | 151.10 | 1,323.40 | 146.40 | 1,500.30 | 183.20 | 1,578.40 | 88.70 | 4.64% | 2.39% |
| U.K | 501.20 | 125.30 | 617.10 | 115.90 | 726.10 | 109.00 | 896.20 | 171.00 | 2.63% | 4.62% |
| Others | 3,555.36 | 382.90 | 3,975.88 | 520.90 | 4,346.70 | 651.00 | 4,999.11 | 684.20 | 14.69% | 18.46% |
| **Total** | **24,375.56** | **2,475.90** | **27,047.58** | **2,788.10** | **30,368.90** | **3,212.50** | **34,029.41** | **3,706.00** | **100%** | **100%** |

ប្រភព៖ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

ឆ្លងមកដល់រយៈពេលមួយឆ្នាំ ក្រោយពីមានការទទួលស្គាល់ប្រទេសកម្ពុជាក្លាយជាប្រទេស ដែលមានចំណូលមធ្យមកម្រិតទាបនៅឆ្នាំ2015 ដូចគ្នានេះផងដែរនៅក្នុងឆ្នាំ2016 ដល់ 2019 កម្ពុជាបានពង្រីកនូវទីផ្សារកាន់តែទូលំទូលាយ ដើម្បីធ្វើយ៉ាងណាទាក់ទាញវិនិយោគិនបរទេសឲ្យចូលមកវិនិយោគផ្ទាល់នៅក្នុងប្រទេសកម្ពុជា។ ប្រទេសដែលធ្វើការវិនិយោគផ្ទាល់នៅក្នុងប្រទេសកម្ពុជា មានដូចជាប្រទេសចិនមានភាគហ៊ុននៃការវិនិយោគស្មើនឹង 28.60% និងលំហូរនៃការវិនិយោគស្មើនឹង 30.02%។ ប្រទេសកូរ៉េខាងត្បូងមានភាគហ៊ុននៃការវិនិយោគស្មើនឹង 11.14% និងលំហូរនៃការវិនិយោគស្មើនឹង 6.69%។ ហុងកុងមានភាគហ៊ុននៃការវិនិយោគស្មើនឹង 8.72% និងលំហូរនៃការវិនិយោគស្មើនឹង 10.77%។ ប្រទេសវៀតណាមមានភាគហ៊ុននៃការវិនិយោគស្មើនឹង 6.96% និងលំហូរនៃការវិនិយោគស្មើនឹង 4.99%។ ប្រទេសសិង្ហបុរីមានភាគហ៊ុននៃការវិនិយោគស្មើនឹង

5.97% និងលំហូរនៃការវិនិយោគស្មើនឹង 7.11%។ ប្រទេសជប៉ុនមានភាគហ៊ុននៃការវិនិយោគស្មើនឹង 5.94% និងលំហូរនៃការវិនិយោគស្មើនឹង 4.84%។ ប្រទេសចិនតៃវ៉ាន់មានភាគហ៊ុននៃការវិនិយោគស្មើនឹង 5.77% និងលំហូរនៃការវិនិយោគស្មើនឹង 5.78%។ ប្រទេសម៉ាឡេស៊ីមានភាគហ៊ុននៃការវិនិយោគស្មើនឹង 4.93% និងលំហូរនៃការវិនិយោគស្មើនឹង 4.33%។ ប្រទេសថៃមានភាគហ៊ុននៃការវិនិយោគស្មើនឹង 4.64% និងលំហូរនៃការវិនិយោគស្មើនឹង 2.39%។ ចំណែកឯប្រទេសអង់គ្លេសវិញមានភាគហ៊ុននៃការវិនិយោគស្មើនឹង 2.63% និងលំហូរនៃការវិនិយោគស្មើនឹង 4.62%។ ដោយឡែក នៅមានបណ្តាប្រទេសផ្សេងៗមួយចំនួនទៀត ដែលមានភាគហ៊ុននៃការវិនិយោគស្មើនឹង 14.69% និងហូរនៃការវិនិយោគស្មើនឹង 18.46%។ លើសពីនេះទៅទៀត នៅក្នុងការវិនិយោគពីបណ្តាប្រទេស ដែលបានរៀបរាប់ខាងលើយើងឃើញថា នៅក្នុងឆ្នាំ2019 ភាគហ៊ុននៃការវិនិយោគសរុបជាទឹកប្រាក់ស្មើនឹង 34,029.41 លានដុល្លារអាមេរិក និងលំហូរនៃការវិនិយោគសរុបជាទឹកប្រាក់ស្មើនឹង 3,706.00 លានដុល្លារអាមេរិក ពោលគឺមានការកើនឡើងជាលំដាប់ បើធៀបនឹងឆ្នាំ2016 2017 និង2018។

### ៣.៤.៤.២ ការវិនិយោគតាមវិស័យនៅក្នុងប្រទេសកម្ពុជា

តារាងទី៧៖ ការវិនិយោគតាមវិស័យ (ភាគហ៊ុន) និង (លំហូរ) គិតជាលានដុល្លារ

| Industry | 2016 | | 2017 | | 2018 | | 2019 | | Share % | |
|---|---|---|---|---|---|---|---|---|---|---|
| | Stock | Flow | Stock | Flow | Stock | Flow | Stock | Flow | Stock | Flow |
| **Agriculture** | 3,224.69 | 236.64 | 3,458.51 | 233.82 | 3,689.30 | 230.80 | 3,901.84 | 212.54 | 11.47% | 5.73% |
| **Mining & quarrying** | 234.25 | 22.47 | 253.31 | 19.06 | 272.88 | 19.56 | 289.73 | 16.85 | 0.85% | 0.45% |
| **Manufacturing** | 5,837.17 | 490.24 | 6,193.50 | 356.33 | 6,614.93 | 421.43 | 7,247.57 | 632.65 | 21.30% | 17.07% |
| *Beverage* | 285.86 | 48.31 | 341.84 | 55.98 | 399.25 | 57.41 | 447.33 | 48.08 | 1.31% | 1.30% |
| *Footwear* | 730.43 | 100.47 | 792.45 | 62.02 | 849.64 | 57.19 | 916.33 | 66.69 | 2.69% | 1.80% |
| *Garment* | 4,181.39 | 251.69 | 4,412.08 | 230.69 | 4,697.11 | 285.03 | 5,015.27 | 318.16 | 14.74% | 8.58% |
| *Bag* | 38.28 | 13.20 | 38.28 | – | 38.28 | – | 204.94 | 166.66 | 0.60% | 4.50% |
| *Packaging* | 238.83 | 6.08 | 238.83 | – | 250.33 | 11.49 | 278.83 | 28.51 | 0.82% | 0.77% |
| *Petroleum* | 94.46 | 0.76 | 94.46 | – | 97.12 | 2.66 | 98.45 | 1.33 | 0.29% | 0.04% |
| *Tobacco* | 83.71 | 12.27 | 91.35 | 7.64 | 98.99 | 7.64 | 102.21 | 3.21 | 0.30% | 0.09% |
| *Wood Pro* | 184.20 | 57.47 | 184.20 | – | 184.20 | – | 184.20 | – | 0.54% | 0.00% |
| **Financial Activities** | 3,547.07 | 645.54 | 4,382.36 | 951.35 | 5,548.26 | 1,057.21 | 6,726.48 | 1,223.85 | 19.77% | 33.02% |
| **Accommodations** | 2,532.84 | 253.96 | 2,851.18 | 318.33 | 3,295.68 | 444.50 | 3,809.16 | 513.49 | 11.19% | 13.86% |
| *Hotel* | 741.89 | 127.64 | 877.98 | 136.08 | 1,018.88 | 140.90 | 1,199.85 | 180.97 | 3.53% | 4.88% |
| *Resort* | 466.22 | 43.34 | 544.47 | 78.25 | 614.07 | 69.60 | 750.59 | 136.52 | 2.21% | 3.68% |
| *Casino* | 1,324.73 | 82.99 | 1,428.73 | 104.00 | 1,662.73 | 234.00 | 1,858.73 | 196.00 | 5.46% | 5.29% |
| **Telecom** | 620.32 | 16.09 | 640.92 | 20.60 | 661.52 | 20.60 | 682.12 | 20.60 | 2.00% | 0.56% |
| **Construction** | 455.31 | 77.30 | 562.70 | 107.39 | 804.43 | 241.73 | 1,054.26 | 249.83 | 3.10% | 6.74% |
| **Hydropower** | 2,298.14 | 14.68 | 2,312.83 | 14.68 | 2,327.51 | 14.68 | 2,342.19 | 14.68 | 6.88% | 0.40% |
| **Real Estate** | 3,112.88 | 313.00 | 3,480.68 | 368.00 | 3,844.80 | 364.00 | 4,283.52 | 438.72 | 12.59% | 11.84% |
| **Other** | 2,513.90 | 406.12 | 2,912.60 | 398.70 | 3,310.61 | 398.01 | 3,693.44 | 382.83 | 10.85% | 10.33% |
| **Total** | **24,376.57** | **2,476.04** | **27,048.59** | **2,788.26** | **30,369.92** | **3,212.52** | **34,030.31** | **3,706.04** | **100%** | **100%** |

ដកស្រង់ពី៖ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

ការវិនិយោគផ្ទាល់ពីបរទេសនៅកម្ពុជា គេអាចធ្វើការចាត់ថ្នាក់ទៅតាមវិស័យអទិភាពចំបងៗ ដូចជា វិស័យកសិកម្ម វិស័យប្រតិបត្តិការ និងអាជីវកម្មធនធានរ៉ែ វិស័យកម្មន្តសាល វិស័យហិរញ្ញវត្ថុ វិស័យស្នាក់នៅ វិស័យទូរគមនាគមន៍ វិស័យសំណង់ វិស័យវារីអគ្គិសនី វិស័យអចលនទ្រព្យ និងវិស័យផ្សេងៗទៀត ដែលកំពុងតែ ប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា។ តាមរយៈតារាងទី៧ ខាងលើយើងនេះយើងនឹងបង្ហាញអំពីការវិនិយោគនៅ លើវិស័យផ្សេងៗ ដែលគិតចាប់ពីឆ្នាំ2016 ដល់ 2019។[27]

### ក. កសិកម្ម

វិស័យកសិកម្ម គឺជាវិស័យសំខាន់បំផុតលេខរៀងទី៤ បើយោងតាមទិន្នន័យរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដែលមានសមាមាត្រចំនួន 11.47% នៃវិនិយោគផ្ទាល់ពីបរទេសសរុប ឬស្មើនឹង 3,901.84 លានដុល្លារអាមេរិក នៅក្នុងឆ្នាំ2019 ។ ភាគច្រើននៃការវិនិយោគនេះ គឺការវិនិយោគដីដែលមានទំហំ ធំៗ និងជាទូទៅផ្ទៃដីទាំងនោះត្រូវបានប្រើប្រាស់សម្រាប់ការដាំដំណាំកៅស៊ូ និងដំឡូងមី។ ផ្ទៃដីទាំងនេះភាគច្រើន ត្រូវបានជួលទៅឲ្យសហគ្រាសវិនិយោគផ្ទាល់ពីបរទេសក្នុងរូបភាពជាការជួលរយៈពេលវែង និងក្នុងរូបភាពជា ដីសម្បទានសេដ្ឋកិច្ច។

### ខ. ប្រតិបត្តិការ និងអាជីវកម្មធនធានរ៉ែ

ការវិនិយោគផ្ទាល់ពីបរទេសក្នុងវិស័យប្រតិបត្តិការ និងអាជីវកម្មធនធានរ៉ែមានសមាមាត្រចំនួន 0.85% នៃវិនិយោគផ្ទាល់ពីបរទេសសរុប ឬស្មើនឹង 289.73 លានដុល្លារអាមេរិក នៅក្នុងឆ្នាំ2019 ។ វិស័យនេះ រាប់បញ្ចូលទាំងការវិនិយោគក្នុងការរុករក និងអភិវឌ្ឍន៍ប្រេង ព្រមទាំងប្រតិបត្តិការអាជីវកម្មធនធានរ៉ែផ្សេងៗទៀត។ វិស័យអាជីវកម្មធនធានរ៉ែនៅក្នុងប្រទេសកម្ពុជា គឺនៅតែមិនទាន់មានការអភិវឌ្ឍខ្លាំងក្លានៅឡើយ ហើយក្រុមហ៊ុន អាជីវកម្មធនធានរ៉ែដែលសកម្មបំផុត ធ្វើប្រតិបត្តិការជីកយកថ្មក្នុងទ្រង់ទ្រាយតូចតាចផលិតសម្ភារៈសម្រាប់ការ សាងសង់ ដូចជាថ្មបាយក្រៀម ថ្មម៉ាប ថ្មក្រានីត ថ្មកំបោរ ក្រួស និងដីខ្សាច់ ហើយក៏មានអ្នកជីករុករកធនធានរ៉ែ ដោយដៃខុសច្បាប់មួយចំនួនធំកំពុងធ្វើប្រតិបត្តិការរុករកមាស និងត្បូងមានតម្លៃក្នុងទ្រង់ទ្រាយតូច ដែលជាញឹក ញយធ្វើឡើងក្រៅម៉ោង និងតាមរដូវកាល។

---

[27] *ដកស្រង់ពី៖ ប្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ (Ministry of Foreign Affairsand International Cooperation)។ បានទាញយកនៅថ្ងៃទី28 ខែឧសភា ឆ្នាំ2022 ម៉ោង 11:00 ព្រឹក។*
https://data.opendevelopmentcambodia.net/km/dataset/dashboard-series-about-cambodia/resource/ac3ffd22-e65c-4e5b-b474-dfc840016318/view/de5b84e2-2c01-4604-8a24-d11e64e47ecd

**គ. កម្មន្តសាល**

វិស័យកម្មន្តសាល គឺជាវិស័យសំខាន់បំផុតនៅក្នុងប្រទេសកម្ពុជា ដោយសារតែវិស័យនេះមានសមាមាត្រចំនួន 21.30% នៃវិនិយោគផ្ទាល់ពីបរទេសសរុប ឬស្មើនឹង 7,247.57 លានដុល្លារអាមេរិក នៅក្នុងឆ្នាំ2019 ។ វិស័យនេះបានផ្តល់ឱកាសការងារយ៉ាងច្រើនសម្រាប់ប្រជាជនវ័យក្មេងរបស់ប្រទេសកម្ពុជា ដោយគ្របដណ្តប់គ្រប់ផលិតកម្មជាច្រើនផ្សេងៗគ្នា ដូចជាវិស័យកាត់ដេរសម្លៀកបំពាក់ និងស្បែកជើង ការវេចខ្ចប់ ថ្នាំជក់ ការកែច្នៃឈើ ការចម្រាញ់ប្រេង។

**ឃ. សកម្មភាពហិរញ្ញវត្ថុ**

ការវិនិយោគក្នុងវិស័យហិរញ្ញវត្ថុ គ្របដណ្តប់លើការវិនិយោគផ្នែកធនាគារពាណិជ្ជ ធនាគារឯកទេស គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមហ៊ុនធានារ៉ាប់រង និងក្រុមហ៊ុនមូលបត្រ។ បើយោងទៅតាមទិន្នន័យរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដែលមានសមាមាត្រចំនួន 19.77% នៃវិនិយោគផ្ទាល់ពីបរទេសសរុប ឬស្មើនឹង 6,726.48 លានដុល្លារអាមេរិក នៅក្នុងឆ្នាំ2019 ។ ក្នុងនោះដែរវិស័យធនាគារមានចំនួន 95% នៃចំនួនសរុបក្នុងផ្នែកហិរញ្ញវត្ថុ ចំណែកឯក្រុមហ៊ុនធានារ៉ាប់រង និងក្រុមហ៊ុនមូលបត្រមានចំនួនត្រឹមតែ 5% ប៉ុណ្ណោះ។

**ង. ការស្នាក់នៅ**

វិស័យស្នាក់នៅសំដៅលើការផ្តល់ការស្នាក់នៅរយៈពេលខ្លីចំពោះភ្ញៀវទេសចរ និងអ្នកធ្វើដំណើរផ្សេងៗទៀត រួមទាំងការផ្តល់ម្ហូបអាហារ ភេសជ្ជៈ សម្រាប់ការប្រើប្រាស់ភ្លាមៗ និងការកម្សាន្តផ្សេងៗទៀត។ បើយោងតាមទិន្នន័យរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដែលមានសមាមាត្រចំនួន 11.19% នៃវិនិយោគផ្ទាល់ពីបរទេសសរុប ឬស្មើនឹង 3,809.16 លានដុល្លារអាមេរិក នៅក្នុងឆ្នាំ2019 ។ ដូចគ្នានេះផងដែរ វិស័យនេះគ្របដណ្តប់គ្រប់ផលិតផលសេវាកម្មជាច្រើនផ្សេងៗគ្នាដូចជា វិស័យសណ្ឋាគារ និងផ្ទះសំណាក់ ហើយជាពិសេស រមណីដ្ឋាន និងកាស៊ីណូ។

**ច. ទូរគមនាគមន៍**

វិស័យនេះគ្របដណ្តប់ទៅលើការផលិត និងការចែកចាយផលិតផលព័ត៌មាន និងវប្បធម៌ ការផ្តល់មធ្យោបាយបញ្ជូន ឬចែកចាយផលិតផលទាំងនេះ រួមទាំងទិន្នន័យអំពីគមនាគមន៍ សកម្មភាពព័ត៌មានវិទ្យា និងសកម្មភាពដំណើរការទិន្នន័យ និងសេវាកម្មព័ត៌មានវិទ្យាផ្សេងៗទៀត។ ការវិនិយោគទៅលើវិស័យទូរគមនាគមន៍មានសមាមាត្រចំនួន 2.00% នៃវិនិយោគផ្ទាល់ពីបរទេសសរុប ឬស្មើនឹង 682.12 លានដុល្លារអាមេរិក នៅក្នុងឆ្នាំ2019 ។ វិស័យនេះផងដែរបានក្លាយជាវិស័យមានសារៈសំខាន់មួយនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម

ហើយកំពុងក្លាយជាវិស័យមួយក្នុងការជម្រុញឲ្យមានកំណើនក្នុងវិស័យផ្សេងៗទៀតនៅក្នុងប្រទេសកម្ពុជា ដូចជា វិស័យអប់រំ កសិកម្ម និងសុខាភិបាល។

### ឆ. សំណង់

វិស័យនេះ រាប់បញ្ចូលសកម្មភាពសំណង់ទូទៅ និងការសាងសង់ឯកទេសផ្សេងៗទៀត សម្រាប់ការងារវិស្វកម្មស៊ីវិល និងសំណង់សិល្បការ (Buildings and civil engineering works)។ សកម្មភាពនេះរាប់បញ្ចូលការងារសាងសង់ថ្មី ការជួសជុល ការសង់បន្ថែម និងការកែលម្អ ការសាងសង់គ្រោងអាគារ និងរចនាសម្ព័ន្ធដែលដំឡើងរួចនៅនឹងទីកន្លែង និងការសាងសង់បណ្ដោះអាសន្ន។ បើយោងតាមទិន្នន័យរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដែលមានសមាមាត្រចំនួន 3.10% នៃវិនិយោគផ្ទាល់ពីបរទេសសរុប ឬស្មើនឹង 1,054.26 លានដុល្លារអាមេរិក នៅក្នុងឆ្នាំ2019 ។

### ជ. វារីអគ្គិសនី

វិស័យវារីអគ្គិសនី គឺជាវិស័យមួយដែលមានចំណាត់ថ្នាក់លេខរៀងទី៧ ដោយសារតែវិស័យនេះមានសមាមាត្រចំនួន 6.88% នៃវិនិយោគផ្ទាល់ពីបរទេសសរុប ឬស្មើនឹង 2,342.19 លានដុល្លារអាមេរិក នៅក្នុងឆ្នាំ2019 ។ ក្រៅពីនេះ អគ្គិសនីមួយចំនួនត្រូវបាននាំចូលពីប្រទេសវៀតណាម ប្រទេសថៃ និងប្រទេសឡាវ ដើម្បីបំពេញតម្រូវការប្រើប្រាស់បង្គ្រប់។ ទំនប់វារីអគ្គិសនី គឺជាប្រភេទគម្រោងផែនការថាមពលរបស់រាជរដ្ឋាភិបាលដ៏សំខាន់មួយ ដែលជាទូទៅត្រូវបានចាត់ទុកថា ជាប្រភពថាមពលកើតឡើងវិញ។

### ឈ. អចលនទ្រព្យ

ការវិនិយោគផ្ទាល់ពីបរទេសក្នុងវិស័យអចលនទ្រព្យរួមមាន ដីមិនទាន់អភិវឌ្ឍន៍ អចលនទ្រព្យបែបលំនៅដ្ឋាន អចនលនទ្រព្យបែបពាណិជ្ជកម្ម អចនលនទ្រព្យបែបឧស្សាហកម្ម និងអចនលនទ្រព្យបែបការកម្សាន្ត។ បើយោងតាមទិន្នន័យរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដែលមានសមាមាត្រចំនួន 12.59% នៃវិនិយោគផ្ទាល់ពីបរទេសសរុប ឬស្មើនឹង 4,283.52 លានដុល្លារអាមេរិក នៅក្នុងឆ្នាំ2019 ។ នៅក្នុងវិស័យនេះផងដែរ ជនបរទេសមិនអាចកាន់កាប់អចនលនទ្រព្យក្នុងប្រទេសកម្ពុជាឡើយ លើកលែងតែខុនដូស្នាក់នៅចាប់ពីជាន់ទី១ ឡើងទៅ។ លើសពីនេះទៅទៀត ក្រុមហ៊ុនសាជីវកម្មកម្ពុជា ដែលអាចកាន់កាប់អចលនទ្រព្យបាន លុះត្រាតែក្រុមហ៊ុននោះត្រូវបានកាន់កាប់ភាគច្រើនដាច់ខាតដោយពលរដ្ឋកម្ពុជា។

### ញ. ឧស្សាហកម្មផ្សេងទៀត

វិស័យនេះ ជាផ្នែកសេសសល់ ដែលមានសមាមាត្រចំនួន 10.85% នៃវិនិយោគផ្ទាល់ពីបរទេសសរុប ឬស្មើនឹង 3,693.44 លានដុល្លារអាមេរិក នៅក្នុងឆ្នាំ2019 ។ វិស័យនេះផងដែរ ត្រូវបានរាប់បញ្ចូលឧស្សាហកម្មដែលសកម្មភាពរបស់វាពុំត្រូវបានធ្វើចំណាត់ថ្នាក់ ដោយសារតែពុំមានព័ត៌មានគ្រប់គ្រាន់ ដើម្បី

ទទួលទិន្នន័យពីកម្មសិទ្ធ ឬសកម្មភាពរបស់ឧស្សាហកម្ម ឬក្រោមហេតុផលការសម្ងាត់ជាដើម ហើយផ្នែកខ្លះនៃឧស្សាហកម្មទាំងនោះអាចចាត់ថ្នាក់ក្នុងវិស័យសេវាកម្ម ក្រៅពីវិស័យដែលបានកំណត់ខាងលើ។

## ៣.៥ គុណសម្បត្តិ និងគុណវិបត្តិនៃការវិនិយោគផ្ទាល់ពីបរទេស (FDI)

### ៣.៥.១ គុណសម្បត្តិ

ជាទូទៅការវិនិយោគផ្ទាល់ពីបរទេស (FDI) បានធ្វើឲ្យមានកំណើនការងារ និងសេដ្ឋកិច្ចមានសន្ទុះយ៉ាងខ្លាំងក្នុងប្រទេសកម្ពុជា ព្រោះថាការវិនិយោគផ្ទាល់ពីបរទេស បានបង្កឲ្យមានប្រភពធនធានហិរញ្ញវត្ថុ ធនធានមនុស្ស និងបច្ចេកវិទ្យាទំនើបៗ ផលិតផលមានការប្រកួតប្រជែងទាំងគុណភាព និងថ្លៃ។ ការវិនិយោគផ្ទាល់ពីបរទេសនេះផងដែរ ក៏បានផ្តល់នូវការងារជាច្រើនសម្រាប់ប្រជាជននៅក្នុងប្រទេសកម្ពុជា ដូចជាការងារប្រភេទជាកម្មករកម្មការនីកាត់ដេរ និងសំណង់ បុគ្គលិកបម្រើការងារតាមសណ្ឋាគារ ភោជនីយដ្ឋាននៅតាមរមណីយដ្ឋាននានា ការបកប្រែ ដឹកអ្នកដំណើរ កសិកម្មកែច្នៃ រួមទាំងវិស័យមួយចំនួនផ្សេងៗទៀត ដែលអាចផ្តល់នូវការងារដល់ប្រជាជនមកពីជនបទក្រីក្រ មិនមានការងារធ្វើ ឬធ្វើតែកសិកម្មលក្ខណៈប្រពៃណី ដែលមានចំណូលទាប និងសិស្សនិស្សិតដែលកំពុងតែខ្វះការងារធ្វើបន្ទាប់ពីបញ្ចប់ការសិក្សា។ ពិសេសជាងនេះទៅទៀតប្រភពការងារទាំងអស់នេះបានចូលរួមចំណែក ក្នុងការកាត់បន្ថយវិសមភាពនៃប្រាក់ចំណូលរបស់ប្រជាជនក្នុងប្រទេសកម្ពុជា ដែលទទួលបានការទូទាត់សងក្នុងកម្រិតល្អប្រសើរ ការកាត់បន្ថយអត្រាអតិផរណាបង្កភាពងាយស្រួលដល់សហគ្រិនជាមួយស្ថានភាពហិរញ្ញវត្ថុល្អប្រសើរ និងអត្រាការប្រាក់ទាបក្នុងការបង្កើនការវិនិយោគឲ្យកាន់តែច្រើនឡើងជាលំដាប់ ។ លើសពីនេះទៅទៀត កំណើននៃការវិនិយោគផ្ទាល់ពីបរទេស បាននាំមកនូវការប្រកួតប្រជែងគុណភាពផលិតផលកសិកម្ម ហើយក៏ជួយជំរុញផលិតភាពកសិផលដល់ប្រជាកសិករផងដែរ ដោយការនាំចូលមកនូវបច្ចេកវិទ្យាថ្មីៗក្នុងការជំរុញផលិតភាពធ្វើឲ្យទិន្នផលមានការកើនឡើង និងប្រើប្រាស់នូវបច្ចេកវិទ្យាដើម្បីធ្វើឲ្យគុណភាពប្រសើរឡើង ដើម្បីយកទៅប្រកួតប្រជែងក្នុងទីផ្សារក្រៅប្រទេស ជាពិសេសបានធ្វើឲ្យផលិតផលកសិកម្មលក់បានថ្លៃប្រសើរជាងមុន ដែលជាលទ្ធផលប្រជាកសិករនៅក្នុងប្រទេសកម្ពុជាអាចរកប្រាក់ចំណូលបន្ថែមពីវិស័យកសិកម្ម និងជំរុញឲ្យវិស័យកសិកម្មកាន់តែរឹងមាំមួយកម្រិតទៀត។

ពិសេសជាងនេះទៅទៀត ការវិនិយោគផ្ទាល់ពីបរទេសបានផ្ទេរគុណប្រយោជន៍ដល់ប្រទេសកម្ពុជាជាច្រើន តាមរយៈការធ្វើឲ្យមានប្រសិទ្ធិភាពនៃកម្លាំងពលកម្ម។ ការវិនិយោគផ្ទាល់ពីបរទេស បានផ្តល់មកនូវសមត្ថភាពពលកម្មក្នុងស្រុកតាមរយៈការបើកទូលាយនូវការផ្លាស់ប្តូរពលកម្មក្នុងស្រុក និងបរទេស ដោយការផ្ទេរផលប្រយោជន៍ទៅកាន់បុគ្គលិកតាមរយៈការបណ្តុះបណ្តាលពីអ្នកជំនាញបរទេស ដូចជាការបង្រៀនឲ្យចេះធ្វើការងារ និងការផ្តល់ការងារជាបទពិសោធន៍ផ្សេងៗ។ ដូច្នេះហើយ ការវិនិយោគផ្ទាល់ពីបរទេសបាននាំមកនូវជាមួយនឹងចំណេះដឹង ចំណេះធ្វើ ដែលជាកត្តាជំរុញឲ្យពលកម្មអនុវត្តន៍ និងធ្វើការផ្លាស់ប្តូរទៅរកការងារប្រើប្រាស់

ជំនាញ និងធ្វើឲ្យដំណើរការការងារទទួលបានជោគជ័យ។ ជាងនេះទៅទៀត ការលើកទឹកចិត្តតាមរយៈការផ្ទេរបុគ្គលិកឲ្យទៅធ្វើការសិក្សានៅក្នុងក្រុមហ៊ុនក្រៅស្រុក និងការផ្ទេរបុគ្គលិកពីបរទេសមកធ្វើការនៅក្នុងស្រុកវិញ ដើម្បីអាចឲ្យបុគ្គលិកក្នុងស្រុកទទួលបានបទពិសោធន៍ទាំងជំនាញ និងចំណេះដឹងថ្មីៗថែមទៀតផង។

### ៣.៥.២ គុណវិបត្តិ

ការវិនិយោគផ្ទាល់ពីបរទេសបានផ្តល់ផលប្រយោជន៍ជាច្រើនដល់ប្រទេសកម្ពុជា ប៉ុន្តែទោះបីជាយ៉ាងណាក្តី ការវិនិយោគនេះក៏បានផ្តល់ផលលំបាកមួយចំនួនផងដែរ ដូចជាការធ្វើឲ្យមានផលប៉ះពាល់ទៅដល់បរិស្ថាន កង្វក់ទឹក និងបរិយាកាសជាដើម តាមរយៈកាកសំណល់ផ្សេងៗ ដូចជាសម្ភារៈបរិក្ខាផ្សេងៗ ការប្រើប្រាស់ទឹក និងផ្សែងពុលចេញពីរោងចក្រឧស្សាហកម្មនានា។ ជាងនេះទៅទៀត ការវិនិយោគបានទាញយកធនធានធម្មជាតិ ដែលជាធនធានកម្រជាច្រើន ដូចជាការរុករករ៉ែ ប្រេងកាតក្នុងដី និងសមុទ្រ គម្រោងមួយចំនួនធ្វើលើដីភ្នំ និងព្រៃឈើដែលធ្វើការកាប់ឈូសឆាយ ដោយបានបំផ្លាញព្រៃឈើនៅស្រទាប់ខាងលើ។ នៅថ្ងៃខាងមុខទៅប្រសិនបើមិនមានការគ្រប់គ្រងធនធានទាំងនេះច្បាស់លាស់ទេ នោះនឹងធ្វើឲ្យធនធានធម្មជាតិអាចនឹងបាត់បង់ទាំងស្រុង។

ម្យ៉ាងវិញទៀត ការវិនិយោគផ្ទាល់ពីបរទេសបានធ្វើឲ្យមានការជះឥទ្ធិពលអាក្រក់ ដល់អ្នកវិនិយោគក្នុងស្រុក ប្រសិនបើរដ្ឋាភិបាលមិនយកចិត្តទុកដាក់ទេនោះ។ នៅពេលដែលមានការហូរចូលនូវវិនិយោគិនបរទេសកាន់តែខ្លាំង វានឹងធ្វើឲ្យអ្នកវិនិយោគក្នុងស្រុកបរាជ័យ និងក្ស័យធនជាដើម ដោយសាគ្មានសមត្ថភាពអាចប្រកួតប្រជែងជាមួយអ្នកនិយោគបរទេសបាន ក្រោមហេតុផលមួយចំនួនដូចជា ការខ្វះខាតនូវមូលធន សមត្ថភាព ជំនាញ និងបច្ចេកទេស ដើម្បីធ្វើឲ្យទំនិញមានគុណភាព និងតម្លៃសមរម្យ ដែលជាហេតុមិនអាចប្រកួតប្រជែងជាមួយក្រុមហ៊ុនបរទេសបានទេ។

## ៣.៦ បញ្ហាប្រឈម

បើទោះបីប្រទេសកម្ពុជា មានចំណុចជាច្រើនក្នុងការទាក់ទាញវិនិយោគផ្ទាល់ពីបរទេសយ៉ាងណាក្តី ក៏ប្រទេសកម្ពុជានៅតែមានបញ្ហាប្រឈមមួយចំនួនផងដែរ ដែលធ្វើឲ្យរាំងស្ទះដល់ការវិនិយោគផ្ទាល់ពីបរទេស ដូចជា៖

### ៣.៦.១ កង្វះខាតហេដ្ឋារចនាសម្ព័ន្ធ

ប្រទេសកម្ពុជាមានហេដ្ឋារចនាសម្ព័ន្ធ ដែលមិនទាន់គ្រប់គ្រាន់សម្រាប់ទ្រទ្រង់ដល់ការវិនិយោគ និងទាក់ទាញការវិនិយោគទេ។ នៅពេលប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធមានភាពខ្វះខាត ឬមិនសូវអំណោយផលធ្វើឲ្យមានការចំណាយច្រើន និងខាតពេលវេលា។ ដោយសារហេដ្ឋារចនាសម្ព័ន្ធនៅមានភាពខ្វះខាត ដែលបណ្តាលឲ្យខ្ជះខ្ជាយពេលវេលា និងថវិការ ហើយខាតបង់ទាំងប្រាក់ចំណេញ។ ជាងនេះទៅទៀត នៅពេលប្រទេសកម្ពុជា

មិនទាន់មានគ្រប់គ្រាន់ក្នុងការផ្គត់ផ្គង់អគ្គិសនី ដែលធ្វើឲ្យតម្លៃអគ្គិសនីនៅក្នុងប្រទេសកម្ពុជានៅតែមានតម្លៃថ្លៃនៅឡើយ។ អគ្គិសនីមានសារៈសំខាន់ណាស់ទៅដល់អ្នកវិនិយោគផ្នែកវិស័យឧស្សាហកម្មធនធូន់ ជាពិសេសក្នុងវិស័យផលិតកម្ម ដែលត្រូវការប្រើប្រាស់កម្លាំងអគ្គិសនីជាច្រើនក្នុងដំណើរការផលិត។ ថ្វីត្បិតតែរាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងសាងសង់វារីអគ្គិសនី និងធ្វើការទិញពីប្រទេសជិតខាងយ៉ាងណាក៏ដោយ ក៏ការផ្គត់ផ្គង់នៅតែមានកង្វះខាត ពោលគឺនៅមិនទាន់គ្រប់គ្រាន់សម្រាប់តម្រូវការប្រើប្រាស់ និងមានតម្លៃខ្ពស់នៅឡើយបើធៀបធៀបទៅនឹងប្រទេសជិតខាងរបស់យើង។ មូលហេតុទាំងអស់នេះហើយ បានជាធ្វើឲ្យមានការរាំងស្ទះទៅដល់វិស័យវិនិយោគ ដែលប្រើប្រាស់គ្រឿងម៉ាស៊ីនអគ្គិសនីសម្រាប់ដំណើរការផលិតខ្ពស់។

### ៣.៦.២ កង្វះសមត្ថភាពធនធានមនុស្ស

ទោះបីជាធនធានមនុស្សនៅក្នុងប្រទេសកម្ពុជាមានចំនួនច្រើន រហូតដល់ជាងពាក់កណ្តាលនៃចំនួនប្រជាជនសរុប ហើយថ្លៃឈ្នួលពលកម្មមានតម្លៃថោកយ៉ាងណាក៏ដោយ ប៉ុន្តែសមត្ថភាពសម្រាប់បម្រើការងារ ក៏ជាចំណុចសំខាន់ណាស់ដែរសម្រាប់អ្នកវិនិយោគក្នុងការគិតពិចារណា។ យ៉ាងណាមិញសមត្ថភាព និងជំនាញរបស់កម្មករ និងបុគ្គលិកក្នុងប្រទេសនៅមានកម្រិតនៅឡើយ ដោយសារតែប្រព័ន្ធអប់រំនៅកំពុងធ្វើកំណែទម្រង់ និងការពង្រីក។ ដូច្នេះហើយ ទើបប្រជាជននៅជនបទពិបាកក្នុងការទទួលយកនូវការបង្ហាត់បង្រៀន និងជំនាញថ្មីៗ។ តែផ្ទុយទៅវិញ ការវិនិយោគផ្ទាល់ពីបរទេសតែងតែប្រើប្រាស់ និងនាំមកនូវបច្ចេកទេសថ្មីៗ និងបច្ចេកវិទ្យាទំនើបៗ ដើម្បីជំរុញកំណើនការផលិត។ នេះហើយ ជាកង្វះសមត្ថភាពបុគ្គលិកមានជំនាញ និងចំណេះដឹងធ្វើឲ្យអ្នកវិនិយោគមានការស្ទាក់ស្ទើរក្នុងការដាក់ទុនវិនិយោគនៅក្នុងប្រទេសកម្ពុជា។

### ៣.៦.៣ ប្រព័ន្ធហិរញ្ញវត្ថុ

បើទោះបីជាប្រព័ន្ធហិរញ្ញវត្ថុ មានការរីកដុះដាល និងពង្រីកពាសពេញផ្ទៃប្រទេស ជាពិសេសនៅតាមតំបន់ជនបទ ដោយចំនួនធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងធានារ៉ាប់រង ដែលកំពុងតែមានការកើនឡើងយ៉ាងណាក្តី ក៏ការយល់ដឹងរបស់ប្រជាជនពីការប្រើប្រាស់ប្រព័ន្ធធនាគារនៅមានកម្រិតនៅឡើយ ដូចជាទំនុកចិត្តលើសេវាកម្មរបស់ធនាគារក្នុងការដាក់ប្រាក់បញ្ញើដើម្បីយកការប្រាក់ជាដើម។

ហេតុដូច្នេះហើយ បានជាធ្វើអោយធនធានបម្រុងទុកនៅក្នុងធនាគារមានតិច ដែលធ្វើឲ្យមានភាពខ្វះខាតធនធានសម្រាប់ផ្តល់កម្ចី មិនអាចផ្គត់ផ្គង់ដល់ការវិនិយោគ ដែលមានតម្រូវការមូលធនច្រើន និងអត្រាការប្រាក់ខ្ពស់បានក្លាយជាភាពរាំងស្ទះដល់ការវិនិយោគ និងអ្នកមានបំណងវិនិយោគ ដោយសារការប្រាក់ថ្លៃ ដែលធ្វើឲ្យក្លាយជាបន្ទុកបន្ថែមលើថ្លៃដើមផលិតកម្ម។

### ៣.៦.៤ ជម្លោះដីសម្បទាន

ការផ្តល់ដីសម្បទានដល់អ្នកវិនិយោគ ក្នុងរយៈពេលកំណត់មួយពិតជាបានចូលរួមដល់ការទាក់ទាញវិនិយោគិនក៏ពិតមែន ក៏ប៉ុន្តែនៅពេលដែលការផ្តល់ដីសម្បទានពីសំណាក់រដ្ឋាភិបាលទៅដល់វិនិយោគិនមួយចំនួន បានបង្កឲ្យមានវិបត្តិជម្លោះដីធ្លីជាមួយប្រជាជនមូលដ្ឋាន ដោយភាពមិនច្បាស់លាស់នៃការគ្រប់គ្រងដីធ្លី និងភាពអនាធិតេយ្យនៃការសាងសង់លំនៅដ្ឋាន ដោយគ្មានការត្រួតពិនិត្យឲ្យបានច្បាស់លាស់ពីរដ្ឋអំណាច។ វាបានក្លាយជាកត្តារាំងស្ទះដល់ការអនុវត្តន៍គម្រោងវិនិយោគក្នុងរយៈពេលមិនពិតប្រាកដមួយ ដោយសារតែដំណោះស្រាយជម្លោះដីធ្លីភាគច្រើនត្រូវចំណាយពេលវេលាក្នុងការចរចា ដើម្បីរកដំណោះស្រាយជាមួយបណ្តាភាគីពាក់ព័ន្ធ។ ជាងនេះទៅទៀត ក្នុងករណីមួយចំនួន ការដោះស្រាយជម្លោះដីធ្លីបានក្លាយទៅជាបញ្ហាប្រឈមសម្រាប់អ្នកវិនិយោគក្នុងការទូទាត់សំណងសមស្របមួយ ដែលបានផ្តល់ជាបន្ទុកបន្ថែមដល់ការវិនិយោគ។

### ៣.៦.៥ បញ្ហារបន្ទាប់បន្សំ

#### ៣.៦.៥.១ អំពើពុករលួយ

អំពើពុករលួយជាបញ្ហាដ៏ស្មុគស្មាញមួយ និងប៉ះពាល់ដល់សង្គមជាតិទាំងមូល ពីព្រោះថាបញ្ហានេះអាចធ្វើឲ្យបាត់បង់ប្រាក់ចំណូលពលរដ្ឋនៅក្នុងប្រទេសកម្ពុជា និងការរាំងស្ទះដល់ឱកាសសម្រាប់ការវិនិយោគ។ បើទោះបីជាប្រទេសកម្ពុជាមានការកើនឡើងនៃអ្នកវិនិយោគពីបរទេសយ៉ាងណាក្តី ក៏ប៉ុន្តែប្រទេសកម្ពុជានៅតែមានលំដាប់ថ្នាក់ខ្សោយទៅលើភាពប្រកួតប្រជែងនឹងបញ្ហាពុករលួយផងដែរ ដែលតាមធនាគារពិភពលោកបានដាក់លំដាប់ថ្នាក់ប្រទេសកម្ពុជានៅមានភាពខ្សោយទៅលើបរិយាកាសវិនិយោគនៅលេខរៀងទី 145 ក្នុងចំណោមចំណាត់ថ្នាក់ 183 នៅក្នុងឆ្នាំ2009។

អំពើពុករលួយត្រូវបានគេចាត់ទុកថាជាឧបសគ្គដល់អ្នកវិនិយោគទាំងក្នុងស្រុក និងអ្នកវិនិយោគបរទេស ដែលមានការខ្លាចញញើតក្នុងការដាក់ទុនវិនិយោគ ដោយសារវាជាឧបសគ្គ ដែលមានដូចជា ការចំណាយក្រៅផ្លូវការ ចំណាយខាតខាងពេលវេលា និងបញ្ហាធំបំផុតគឺហានិភ័យ ដែលអាចធ្វើឲ្យភាពបរាជ័យនៃការវិនិយោគទាំងស្រុង ដោយសារតែភាពមិននឹងនរនៃស្ថានភាពវិនិយោគ។ ជាងនេះទៅទៀត អត្ថប្រយោជន៍ដែលបានមកពីការវិនិយោគត្រូវបានបញ្ចៀសពីអត្ថប្រយោជន៍សាធារណៈ ទៅជាអត្ថប្រយោជន៍របស់បុគ្គលមួយចំនួនតែប៉ុណ្ណោះ នាំមកនូវភាពរាំងស្ទះដល់ការអភិវឌ្ឍប្រទេសទាំងមូល។

#### ៣.៦.៥.២ ការិយាល័យធិបតេយ្យ

បើទោះបីប្រទេសកម្ពុជា មានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាជាអ្នកផ្តល់សេវាកម្មច្រកចេញចូលតែមួយសម្រាប់ជំរុញដល់ដំណើរការផ្តល់សិទ្ធិវិនិយោគយ៉ាងណាក្តី ក៏ប៉ុន្តែក៏នៅមានក្រសួងជាច្រើនចូលរួម និងទាក់ទងគ្នា ហើយក្រសួងទាំងនោះមានតួនាទីសំខាន់ៗ និងមានសិទ្ធិអំណាចក្នុងការអនុម័តទៅលើលិខិតវិនិយោគដែរ

ក្នុងរយៈពេល 28 ថ្ងៃ ហើយពាក្យទាំងនោះត្រូវឆ្លងកាត់ក្រសួងផ្សេងៗគ្នាដើម្បី ពន្យល់បញ្ជាក់ និងផ្តល់ព័ត៌មានបន្ថែម ហើយតម្លាភាពនៅក្នុងដំណើរការនីមួយៗនៅតែមានភាពខ្សោយនៅឡើយ។ ហេតុដូចនេះហើយទើបការិយាល័យធិបតេយ្យ ក៏ជាបញ្ហាមួយស្មុគស្មាញដល់ការវិនិយោគ ពីព្រោះមានការចំណាយច្រើនគ្រប់លំដាប់ថ្នាក់ និងខាតទាំងពេលវេលាថែមទៀតផង។

### ៣.៦.៥.៣ របាំងក្នុងការនាំចេញ

សកម្មភាពធ្វើពាណិជ្ជកម្មមានភាពរាំងស្ទះ ដោយសារតែត្រូវឆ្លងកាត់ដំណាក់កាលភ្នាក់ងាររដ្ឋជាច្រើនក្នុងការត្រួតពិនិត្យ និងអនុម័តលើឯកសារនាំចេញនាំចូល ដែលជាហេតុធ្វើឲ្យត្រូវចំណាយរយៈពេលយូ និងថវិការក្នុងសកម្មភាពពាណិជ្ជកម្ម ពីព្រោះនៅពេលមន្ត្រីអវត្តមាន ដោយសារមូលហេតុផ្ទាល់ខ្លួន (ការចូលរួមអាពាពិពាហ៍សាច់ញាតិបងប្អូនជាដើម) ឬមូលហេតុការិយាល័យដូចជា ការប្រជុំជាដើមធ្វើឲ្យដំណើរការ ការអនុម័តលើឯកសារផ្សេងៗត្រូវពន្យាពេល។

## ៣.៧ ដំណោះស្រាយ

### ៣.៧.១ កំណែទម្រង់រដ្ឋបាល និងស្ថាប័ន

ដើម្បីឲ្យសកម្មភាពជំនួញមានភាពល្អប្រសើ រដ្ឋាភិបាលកម្ពុជាត្រូវយកចិត្តទុកដាក់ទៅលើការធ្វើកំណែទម្រង់រដ្ឋបាល និងស្ថាប័ននូវចំណុចសំខាន់ៗមួយចំនួនដូចជា ការធ្វើឲ្យប្រសើរឡើងនូវសេវាកម្មបែងចែកគឺផ្តោតលើក្រសួងនានា និងដៃគូអភិវឌ្ឍន៍ធ្វើការស្វែងរកវិធីសាស្ត្រ ដើម្បីធ្វើឲ្យការបែងចែកសេវាកម្មមានភាពកាន់តែប្រសើរឡើង ការធ្វើឲ្យប្រសើរឡើងនូវតម្លាភាព និងការកាត់បន្ថយការិយាល័យធិបតេយ្យជាដើម។ ការធ្វើឲ្យប្រសើរឡើងនូវចំណាយ និងភាពមានការងារតាមរយៈការពង្រឹងភាពខ្លាំងក្នុងការគ្រប់គ្រង និងត្រួតពិនិត្យធនធានមនុស្ស ការប្រើប្រាស់កញ្ចប់ថវិការឲ្យមានប្រសិទ្ធភាព និងចំគោលដៅ។ ម្យ៉ាងវិញទៀត ការអភិវឌ្ឍទៅលើសមត្ថភាព គឺធ្វើការជំរុញការអភិវឌ្ឍនូវមុខតំណែង និងជំនាញដែលជាស្នូល ដូចជាផ្នែករៀបចំផែនការប្រតិបត្តិការ និងយុទ្ធសាស្ត្រហិរញ្ញវត្ថុ ការគ្រប់គ្រងបុគ្គលិក ក៏ដូចជាការគ្រប់គ្រងគម្រោងសម្រាប់ប្រទេសកម្ពុជាដើម្បីកាត់បន្ថយការពឹងផ្អែកលើជំនួយបច្ចេកទេសអន្តរជាតិ។

លើសពីនេះទៅទៀត ការបង្កើនការផ្សព្វផ្សាយព័ត៌មាន និងបច្ចេកវិទ្យាទំនាក់ទំនងឲ្យមានភាពកាន់តែទូលំទូលាយដល់ប្រជាជន ហើយបង្កើតការអនុវត្តកម្មវិធីក្រុមបេសកម្មអាទិភាព គឺសំដៅលើក្រសួង និងភ្នាក់ងារដទៃទៀតធ្វើការអនុវត្តគោលនយោបាយរៀបចំកម្មវិធីអាទិភាពមួយចំនួន ដូចជាការធ្វើឲ្យប្រសើរនូវការបែងចែកសេវាកម្មសាធារណៈ។ ជាងនេះទៅទៀត ការកាត់បន្ថយពេលវេលាសម្រាប់អនុម័តលើគម្រោងវិនិយោគនៅក្នុងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ពីព្រោះថា បើយើងក្រឡេកទៅមើលប្រទេសជិតខាង គេអនុម័តលឿនជាងហើយជាពិសេសលើសេចក្តីស្នើសុំ។

### ៣.៧.២ កាត់បន្ថយអំពើពុករលួយ

ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ នៅតែជារបៀបវារៈអាទិភាពមួយដ៏សំខាន់សម្រាប់គម្រោងអភិវឌ្ឍន៍ជាតិរបស់រដ្ឋាភិបាលនីតិកាលទី៤ តាមរយៈវិធានការប្រទាក់ក្រឡាគ្នា។ តាមរយៈការលើកកម្ពស់ការយល់ដឹងរាល់ទិដ្ឋភាពស្តីអំពីអំពើពុករលួយរួមមានមូលហេតុឥទ្ធិពល និងផលលំបាកដ៏គ្រោះថ្នាក់ ដោយមានការលើកកម្ពស់ការចូលរួមពីសាធារណៈជន និងការពង្រឹងសមត្ថភាពរបស់មន្ត្រីរាជការ និងបញ្ឈប់រាល់ទំនាស់ផ្សេងៗ។ ការប្រឆាំងអំពើពុករលួយ ក៏តម្រូវឲ្យមានការពង្រឹងគណនេយ្យភាព និងពង្រឹងសមត្ថភាពស្ថាប័ន ដោយផ្តល់នូវសេរីភាព បញ្ចេញមតិជាសាធារណៈ ក៏ដូចជាតម្លាភាពព័ត៌មានរបស់ស្ថាប័នរដ្ឋ ការគោរពច្បាប់ និងអនុវត្តន៍ប្រកបដោយប្រសិទ្ធភាពខ្ពស់របស់មន្ត្រីអនុវត្តន៍ ដោយចាត់វិធានការច្បាប់យ៉ាងម៉ឺងម៉ាត់ និងតឹងរឹងចំពោះជនល្មើស ការលុបបំបាត់នូវការប្រើប្រាស់តួនាទី សិទ្ធិអំណាច និងភាពលំអៀងក្នុងការសម្រេចចិត្តផ្សេងៗ រួមជាមួយការចូលរួមពីវិស័យឯកជនក្នុងការកាត់បន្ថយការឃុបឃិតគ្នា និងមានការប្រកួតប្រជែងគ្នាដោយសេរី យុត្តិធម៌ និងស្មើភាព។

### ៣.៧.៣ ការកសាង និងអភិវឌ្ឍន៍ធនធានមនុស្ស

កំណែទម្រង់ប្រព័ន្ធអប់រំនៅក្នុងប្រទេសកម្ពុជា ពិតជាមានសារៈសំខាន់ណាស់សម្រាប់អភិវឌ្ឍន៍ជំនាញ តាមរយៈការធ្វើឲ្យប្រសើរឡើងនូវគុណភាពអប់រំដូចជា ជំនាញបង្រៀន និងជំនាញភាសា ដែលជាសម្ថភាពរបស់លោកគ្រូអ្នកគ្រូ ជាពិសេសផ្តល់ជំនាញភាសាដល់សិស្ស និងនិស្សិត។ ការប្រើប្រាស់នូវប្រព័ន្ធព័ត៌មានវិទ្យា ក៏ដូចជាការរៀនពីឧបករណ៍បច្ចេកវិទ្យាផ្សេងៗជាដើម ជាពិសេសការពង្រឹងសមត្ថភាពបណ្តុះបណ្តាលផ្សេងៗ និងគ្រូបង្រៀន។ ជាងនេះទៅទៀតមានការលើកទឹកចិត្តដល់ក្រុមហ៊ុន ឬស្ថាប័នឯកជនឲ្យចូលរួមជួយពង្រឹងធនធានមនុស្សក្នុងក្រុមហ៊ុនរបស់ខ្លួនតាមរយៈជំនាញថ្មីៗ ការពង្រឹងសមត្ថភាពនៅថ្នាក់បន្តការសិក្សា និងការផ្លាស់ប្តូរបុគ្គលិករបស់ខ្លួនឲ្យសិក្សាបន្ថែមនៅឯក្រៅប្រទេស។

### ៣.៧.៤ ការពង្រីក និងពង្រីកវិសាលភាពវិស័យហិរញ្ញវត្ថុ

គម្រោងអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុដែលដាក់ចេញ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ក្នុងឆ្នាំ2011 ដល់ 2020 ផ្តោតទៅលើការអភិវឌ្ឍប្រព័ន្ធទូទាត់ជាតិឲ្យមានប្រសិទ្ធភាព ផលិតភាព និងសុវត្ថិភាពតាមការបង្កើន និងអនុវត្តន៍ប្រព័ន្ធគ្រប់គ្រងបច្ចេកទេសព័ត៌មានវិទ្យា ដើម្បីទ្រទ្រង់សេវាកម្មធនាគារចម្រុះ ដោយមានការប្រើប្រាស់ឧបករណ៍អេឡិចត្រូនិចក្នុងការចំណាយនៅគ្រប់ទីកន្លែង។[28] រាជរដ្ឋាភិបាលកម្ពុជា បានស្វែងយល់ពីសារៈសំខាន់

---

[28] *ដកស្រង់ពី៖ អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពី យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ2011 ដល់ 2020 (Financial Sector Development Strategy 2011-2020)។ បានទាញយកនៅថ្ងៃទី04 ខែមិថុនា ឆ្នាំ2022 ម៉ោង 11:00 ព្រឹក។* https://gdfi.mef.gov.kh/kh/financial-sector

របស់ទីផ្សារមូលបត្រ ដែលជាកន្លែងស្តុកមូលធនច្រើនសម្រាប់អ្នកវិនិយោគ និងផ្តល់ភាពងាយស្រួលក្នុងការខ្ចីបុលតាមរយៈការបោះលក់ ជាអាជ្ញាបណ្ណភាគហ៊ុនជាដើម។ រដ្ឋាភិបាលនៅតែបន្តកិច្ចខំប្រឹងប្រែងធ្វើឲ្យទីផ្សារនេះដំណើរការល្អ ដោយធ្វើការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឲ្យយល់ដឹងអំពីការអភិវឌ្ឍ និងបណ្តុះបណ្តាលធនធានមនុស្ស និងសមត្ថភាពរបស់ស្ថាប័នក្នុងការគ្រប់គ្រង និងប្រតិបត្តិការផ្សេងៗ រួមជាមួយច្បាប់ជាច្រើន ដែលបានបង្កើតឡើងទាក់ទងនឹងទីផ្សារមូលបត្រនេះ ដើម្បីសម្រួលដល់ដំណើរការក្នុងទីផ្សារនេះ និងទាក់ទាញជំនឿទុកចិត្តពីអ្នកវិនិយោគ។

### ៣.៧.៥ ការបន្តស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ មានតួនាទីសំខាន់ណាស់សម្រាប់ជួយជំរុញដល់ដំណើរការវិនិយោគ និងចរាចរណ៍ទំនិញចេញចូល។ ហេតុដូច្នេះហើយ រដ្ឋាភិបាលគួរតែបន្ថែមការយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍវិស័យនេះ។ យោងតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ2019 ដល់ 2023 រដ្ឋាភិបាលកម្ពុជាបានបន្តស្តារ និងអភិវឌ្ឍន៍ទៅលើការកសាងហេដ្ឋារចនាសម្ព័ន្ធ ដូចជាប្រព័ន្ធផ្លូវជាតិ ផ្លូវរថភ្លើងកំពង់ផែ និងព្រលានយន្តហោះ ដែលជាប្រព័ន្ធដឹកជញ្ជូនដ៏សំខាន់ ដែលផ្សារភ្ជាប់ទំនាក់ទំនងក្នុងប្រទេស និងខាងក្រៅប្រទេស ដែលរដ្ឋាភិបាលធ្វើការថែរក្សា និងផ្តល់អាទិភាពដល់វិស័យឯកជនចូលរួម ដើម្បីចូលរួមចំណែកកាត់បន្ថយចំណាយលើថ្លៃដឹកជញ្ជូន។[29]

ដោយសារការខ្វះខាតការផ្គត់ផ្គង់អគ្គិសនី រដ្ឋាភិបាលបានពង្រីក និងបង្កើនប្រព័ន្ធអគ្គសនីតាមរយៈគម្រោងអភិវឌ្ឍន៍អគ្គិសនី ដូចជាផែនការអភិវឌ្ឍន៍វិស័យអគ្គិសនីឆ្នាំ2006 ដល់ 2024 ដើម្បីផ្គត់ផ្គង់អគ្គិសនីនៅតាមបណ្តាខេត្តតាមរយៈការផ្ទេរថាមពលអគ្គិសនីពីប្រទេសជិតខាង ដើម្បីផ្គត់ផ្គង់ជិតខ្សែរបន្ទាត់ព្រំដែន និងការសាងសង់វារីអគ្គសនីក្នុងស្រុក ដើម្បីផ្គត់ផ្គង់ដល់តំបន់ដែលមានសក្តានុពលនៃប្រភពទឹក។ ជាងនេះទៅទៀត ការអនុវត្តន៍គោលនយោបាយអគ្គិសនីជនបទ រដ្ឋាភិបាលបានផ្តល់ជាមូលនិធិសម្រាប់ការផ្គត់ផ្គង់អគ្គិសនី និងលើកទឹកចិត្តទៅដល់អ្នកវិនិយោគឲ្យធ្វើការផ្តល់អគ្គិសនីនៅតាមតំបន់ជនបទ តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ ដែលអាចឲ្យការប្រើប្រាស់ថាមពលអគ្គិសនីប្រកបដោយចីរភាព។

### ៣.៧.៦ ការលើកស្ទួយវិស័យកសិកម្ម

សព្វថ្ងៃនេះការវិនិយោគភាគច្រើន ជាប្រភេទវិស័យឧស្សាហកម្ម ទេសចរណ៍ ហិរញ្ញវត្ថុ និងសំណង់ ចំណែកឯវិស័យកសិកម្មវិញនៅមានសន្ទុះយឺតនៅឡើយ ពីព្រោះវិនិយោគិនមិនសូវចាប់អារម្មណ៍ ដោយវិស័យនេះនៅមានភាពទន់ខ្សោយ និងមិនមានស្តង់ដារសម្រាប់ការនាំចេញ។ តាមពិតប្រទេសកម្ពុជា ជាប្រទេសដែល

---

[29] *ដកស្រង់ពី៖ ក្រសួងអប់រំ យុវជន និងកីឡា ស្តីពី ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ 2019 ដល់ 2023។ បានទាញយកនៅថ្ងៃទី04 ខែមិថុនា ឆ្នាំ2022 ម៉ោង 11:30 ព្រឹក។*
http://www.moeys.gov.kh/index.php/kh/policies-and-strategies/3179.html#.YpqrgXZBw2x

មានសក្ដានុពលយ៉ាងខ្លាំងចំពោះវិស័យនេះ ដែលប្រជាជនភាគច្រើនប្រកបរបរកសិកម្ម ពីព្រោះវាសមស្របទៅនឹងកម្លាំងពលកម្ម ហើយសម្បូរធនធានធម្មជាតិ ដែលទ្រទ្រង់លើវិស័យនេះ ដូចជាធនធានទឹកដីសម្រាប់ប្រកបរបរកសិកម្មនៅសល់ច្រើន និងដីមានជីវជាតិមិនទាន់បានអភិវឌ្ឍន៍។ ម្យ៉ាងវិញទៀត ការកើនឡើងការវិនិយោគលើវិស័យនេះអាចជួយកម្ពុជាឲ្យមានការរីកចម្រើន និងមាននិរន្តភាពរយៈពេលវែងជាជាងវិស័យផ្សេងៗទៀត។

# ជំពូកទី៤
# ការសិក្សាអំពីវិសមភាពនៃប្រាក់ចំណូល

## ៤.១ សេចក្តីផ្តើម

ការអភិវឌ្ឍបានជម្រុញឲ្យមានសន្ទុះយ៉ាងខ្លាំងនូវកំណើនសេដ្ឋកិច្ច ជាពិសេសមានការកើនឡើងនៃប្រាក់ចំណូលរបស់ប្រជាជន។ ថ្វីដ្បិតមានការកើនឡើងនូវប្រាក់ចំណូលរបស់ប្រជាជនក៏ពិតមែន ក៏ប៉ុន្តែយើងសង្កេតឃើញថាវិសមភាពនៃប្រាក់ចំណូលនៅតែកើតមានឡើងជារឿយៗ ជាពិសេសនៅក្នុងប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍។ វិសមភាពនៃប្រាក់ចំណូលរបស់ប្រជាជននៅតែកើតមានឡើង ពោលមិនមានប្រទេសណាមួយអាចចៀសផុតឡើយ គ្រាន់តែមានចំនួនតិច និងច្រើនប៉ុណ្ណោះ ដោយវិសមភាពនៃប្រាក់ចំណូលនេះកើតឡើងរវាងប្រជាជននៅតាមតំបន់ជនបទ និងប្រជាជននៅតាមទីក្រុង (គម្លាតរវាងអ្នកមាន និងអ្នកក្រ) ជាពិសេសនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍តែម្តង។ ក្នុងរយៈពេល 30 ឆ្នាំចុងក្រោយនេះ ស្ថានភាពវិសមភាពនៃប្រាក់ចំណូលនៅតែកើតមានឡើងជាបន្តបន្ទាប់ឥតឈប់ឈរ បើទោះបីជាមានការកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសមានចំនួនច្រើនយ៉ាងណាក៏ដោយ។

វិសមភាព[30] ជាទូទៅស្ថិតនៅដំណាក់កាលកណ្តាលនៃការជជែកពិភាក្សាអំពីគោលនយោបាយសេដ្ឋកិច្ចនៅទូទាំងពិភពលោក ដោយការចែកចាយប្រាក់ចំណូលអោយស្មើភាព និងសមធម៌ ដែលមានជាតុផ្សំជាមូលដ្ឋាននៃកិច្ចសន្យាសង្គម។ គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច (រួមទាំងគោលនយោបាយពន្ធដារ និងការចំណាយរបស់រដ្ឋាភិបាល) មានឥទ្ធិពលយ៉ាងសំខាន់លើការបែងចែកប្រាក់ចំណូល ហើយវិសមភាពអាចមានផលវិបាកផ្នែកនយោបាយ សេដ្ឋកិច្ច និងសង្គម ជាមួយនឹងសក្តានុពលក្នុងការបំផ្លាញស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងកំណើនប្រកបដោយចីរភាព។

## ៤.២ និយមន័យវិសមភាពនៃប្រាក់ចំណូល

វិសមភាពនៃប្រាក់ចំណូល[31] គឺជាលំហូរចែកចាយនៃការទទួលបានប្រាក់ចំណូលរបស់ប្រជាជនមិនស្មើគ្នានៅទូទាំងប្រទេស ដោយការចែកចាយកាន់តែតិច វិសមភាពប្រាក់ចំណូលកាន់តែខ្ពស់។ ចំនួនប្រជាជន

[30] *International Monetary Fund: The IMF and income inequality introduction to inequality. Downloaded on 10 June 2022 at 4:00PM.* https://www.imf.org/en/Topics/Inequality/introduction-to-inequality

[31] *What Is Income Inequality? By* CAROL M. KOPP *Updated November 02, 2021, Reviewed by* ROBERT C. KELLY, *Fact checked by* ARIEL COURAGE. *Downloaded on 10 June 2022 at 6:00PM.* https://www.investopedia.com/terms/i/income-inequality.asp

អាចត្រូវបានបែងចែកតាមវិធីផ្សេងៗគ្នា ដើម្បីបង្ហាញពីកម្រិត និងទម្រង់នៃវិសមភាពប្រាក់ចំណូលរបស់ប្រជាជនក្នុងប្រទេសនោះ ដូចជាវិសមភាពប្រាក់ចំណូលតាមប្រភេទ និងវិសមភាពប្រាក់ចំណូលតាមតំបន់។

## ៤.៣ មេគុណ GINI និងវិធានការសរុបនៃវិសមភាព

ក្រាហ្វិកទី១៖ ការប៉ាន់ស្មានតាមរយៈមេគុណ GINI




ប្រភព៖ មេរៀនទី៥ ភាពក្រីក្រ វិសមភាព និងការអភិវឌ្ឍ ដោយលោក (P. Todaro & C. smith)

មេគុណ Gini[32] និងវិធានការសរុបនៃវិសមភាព គឺជារង្វាស់សង្ខេបខ្លីៗងាយស្រួលនៃការបែងចែកកម្រិតចំណូលដែលទាក់ទងទៅនឹងវិសមភាពនៅក្នុងប្រទេសមួយអាចទទួលបាន ដោយការគណនាសមាមាត្រនៃតំបន់រវាងអង្កត់ទ្រូង និងខ្សែកោង Lorenz បែងចែកដោយផ្ទៃដីសរុបនៃពាក់កណ្តាលការ៉េដែលខ្សែកោងស្ថិតនៅក្នុងក្រាហ្វិកទី១ ដែលបង្ហាញអំពីសមាមាត្រនៃផ្ទៃដែលមានស្រមោល A ទៅផ្ទៃដីសរុបនៃត្រីកោណ BCD ។ សមាមាត្រនេះត្រូវបានគេស្គាល់ថាជាសមាមាត្រ Gini ឬមេគុណ Gini ដែលដាក់ឈ្មោះតាមអ្នកស្ថិតិអ៊ីតាលីដំបូងគេ គឺលោក Corrado Gini ដែលបានបង្កើតវានៅឆ្នាំ1912 ។ម្យ៉ាងវិញទៀត មេគុណ Gini គឺជាវិធានការ

[32] *Economic Development: chapter 5 Poverty, Inequality, and Development. By* Michael P. Todaro *(New York University) &* Stephen C. Smith *(The George Washington University)*

វិសមភាពសរុប ហើយអាចប្រែប្រួលចាប់ពី 0 (សមភាពល្អឥតខ្ចោះ) ដល់ 1 (វិសមភាពល្អឥតខ្ចោះ)។ មេគុណ Gini សម្រាប់ប្រទេសដែលមានការបែងចែកប្រាក់ចំណូលខ្ពស់មិនស្មើគ្នាជាធម្មតាស្ថិតនៅចន្លោះ 0.50 និង 0.75 ខណៈពេលដែលប្រទេស ដែលមានទំនាក់ទំនងការបែងចែកប្រាក់ចំណូលស្មើៗគ្នាវិញ គឺស្ថិតនៅលើលំដាប់ពី 0.25 ទៅ 0.35 មានបញ្ជាក់នៅក្នុងក្រាហ្វិកទី២ បន្ទាប់។ ម្យ៉ាងវិញទៀត មេគុណ Gini គឺជារង្វាស់ធម្មតានៃវិសមភាពប្រាក់ចំណូល ដែលការវិភាគភាគច្រើនផ្តោតសំខាន់ទៅលើគំនិតនៃវិសមភាពប្រាក់ចំណូល ដែលចាប់យកដោយមេគុណ Gini ដែលអាចរកបានសម្រាប់ប្រទេសមួយចំនួនធំ និងមានរយៈពេលវែង លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។ វិសមភាពនៃប្រាក់ចំណូល Gini សំដៅលើប្រាក់ចំណូល ឬការប្រើប្រាស់ ដែលអាចប្រើប្រាស់បាន ហើយដូច្នេះវាឆ្លុះបញ្ចាំងពីការចែកចាយឡើងវិញតាមរយៈពន្ធ និងការផ្ទេរ។

### ៤.៣.១ សម្មតិកម្ម KUZNETS (១៩៥៥)

Kuznets (1955) បានបង្កើតសម្មតិកម្មមួយ ហៅថាវិសមភាពនៃប្រាក់ចំណូល ដែលវាកើតឡើងនៅដំណាក់កាលដំបូងនៃការអភិវឌ្ឍ ហើយវិសមភាពនៃប្រាក់ចំណូលវានឹងធ្លាក់ចុះទៅវិញនៅពេលសេដ្ឋកិច្ចឈានទៅដល់ចំណុចខ្ពស់បំផុតនៃការអភិវឌ្ឍ មានបង្ហាញនៅក្នុងក្រាហ្វិកទី២។ ការអភិវឌ្ឍលើកដំបូងចាប់ផ្តើមពីវិស័យកសិកម្ម ឧស្សាហកម្ម និងសេវាកម្ម ដោយមានបញ្ចូលនូវបច្ចេកវិទ្យាថ្មីៗ ហើយមានតែមនុស្សមួយចំនួនតូចប៉ុណ្ណោះ ដែលទទួលបាននូវអត្ថប្រយោជន៍នេះ។

ក្រាហ្វិកទី២៖ ខ្សែកោង Kuznets (Inverted-U)




ប្រភព៖ មេរៀនទី៥ ភាពក្រីក្រ វិសមភាព និងការអភិវឌ្ឍ ដោយលោក (P. Todaro & C. smith)

យើងអាចនិយាយបានម្យ៉ាងទៀតថា វិសមភាពនៃប្រាក់ចំណូលតែងតែកើតមានឡើងនៅក្នុងដំណាក់កាលនៃការអភិវឌ្ឍប្រទេសលើកដំបូង ពោលការចាប់ផ្តើមនៃការអភិវឌ្ឍដំបូងមិនសុទ្ធតែទទួលបាននូវការអភិវឌ្ឍគ្រប់ជ្រុងជ្រោយ និងគ្រប់វិស័យនៅក្នុងតំបន់នោះទេ។ ជាទូទៅ ការអភិវឌ្ឍភាគច្រើន គឺមានការចាប់ផ្តើមពីទីប្រជុំជនធំៗ និងវិស័យចម្បងសំខាន់ៗតែប៉ុណ្ណោះ ដែលជាហេតុធ្វើឲ្យប្រជាជនមួយចំនួនតូច ទទួលបាននូវផលប្រយោជន៍ពីការអភិវឌ្ឍនោះ នៅពេលដែលសេដ្ឋកិច្ចមានកំណើនកើនឡើង ពោលអ្នករស់នៅតាមទីប្រជុំជន ឬទីក្រុងមានឱកាសទទួលបាននូវចំណូលខ្ពស់។ ចំណែកឯ ប្រជាជនដែលរស់នៅតាមតំបន់ជនបទភាគច្រើន មិនសូវទទួលបានផលប្រយោជន៍ពីការអភិវឌ្ឍដំបូងនោះទេ ឬស្ទើរតែមិនទទួលបានទាល់តែសោះ។ កត្តាទាំងអស់នេះហើយ ដែលបណ្តាលឲ្យមាននិសមភាពរវាងប្រជាជននៅក្នុងតំបន់ទាំងពីរកើតមានឡើង ដែលជាហេតុធ្វើឲ្យមានការរាំងស្ទះទៅដល់ការអភិវឌ្ឍនៅក្នុងប្រទេសទាំងមូល។

### ៤.៣.១.១ ឥស្សុតាខមួយចំនួន ដែលបង្ហាញដោយ KUZNETS (១៩៥៥)

តារាងទី៨៖ ប៉ាន់ស្មានការចែកចាយប្រាក់ចំណូលតាមបណ្តាប្រទេសនីមួយៗ ត្រូវបានជ្រើសរើស

| Country | Lowest 10% | Quintile 1st | 2nd | 3rd | 4th | 5th | Highest 10% | Year |
|---|---|---|---|---|---|---|---|---|
| Bangladesh | 4.3 | 9.4 | 12.6 | 16.1 | 21.1 | 40.8 | 26.6 | 2005 |
| Brazil | 1.1 | 3.0 | 6.9 | 11.8 | 19.6 | 58.7 | 43.0 | 2007 |
| China | 2.4 | 5.7 | 9.8 | 14.7 | 22.0 | 47.8 | 31.4 | 2005 |
| Colombia | 0.8 | 2.3 | 6.0 | 11.0 | 19.1 | 61.6 | 45.9 | 2006 |
| Costa Rica | 1.6 | 4.4 | 8.5 | 12.7 | 19.7 | 54.6 | 38.6 | 2007 |
| Guatemala | 1.3 | 3.4 | 7.2 | 12.0 | 19.5 | 57.8 | 42.4 | 2006 |
| Honduras | 0.7 | 2.5 | 6.7 | 12.1 | 20.4 | 58.4 | 42.2 | 2006 |
| India | 3.6 | 8.1 | 11.3 | 14.9 | 20.4 | 45.3 | 31.1 | 2005 |
| Jamaica | 2.1 | 5.2 | 9.0 | 13.8 | 20.9 | 51.2 | 35.6 | 2004 |
| Namibia | 0.6 | 1.5 | 2.8 | 5.5 | 12.0 | 78.3 | 65.0 | 1993 |
| Pakistan | 3.9 | 9.1 | 12.8 | 16.3 | 21.3 | 40.5 | 26.5 | 2005 |
| Peru | 1.3 | 3.6 | 7.8 | 13.0 | 20.8 | 54.8 | 38.4 | 2007 |
| Philippines | 2.4 | 5.6 | 9.1 | 13.7 | 21.2 | 50.4 | 33.9 | 2006 |
| South Africa | 1.3 | 3.1 | 5.6 | 9.9 | 18.8 | 62.7 | 44.9 | 2000 |
| Tanzania | 3.1 | 7.3 | 11.8 | 16.3 | 22.3 | 42.3 | 27.0 | 2001 |
| Zambia | 1.3 | 3.6 | 7.8 | 12.8 | 20.6 | 55.2 | 38.9 | 2005 |
| Japan | 4.8 | 10.6 | 14.2 | 17.6 | 22.0 | 35.7 | 21.7 | 1993 |
| United States | 1.9 | 5.4 | 10.7 | 15.7 | 22.4 | 45.8 | 29.9 | 2000 |

*Source:* World Bank, *World Development Indicators*, 2010. (Washington, D.C.: World Bank, 2010), tab. 2.9.

ប្រភព៖ ធនាគារពិភពលោក (សូចនាករអភិវឌ្ឍន៍ពិភពលោកឆ្នាំ២០១០)

ចូរយើងពិនិត្យមើលទិន្នន័យដែលប្រមូលបានពីប្រទេសចំនួន ១៦ ទៅលើចំណែកភាគរយនៃប្រាក់ចំណូលជាតិសរុប (សូមមើលតារាងទី៨) ។ បើទោះបីជាវិធីសាស្ត្រនៃការប្រមូល កម្រិតនៃការធានា និង និយមន័យជាក់លាក់នៃប្រាក់ចំណូលផ្ទាល់ខ្លួនអាចប្រែប្រួលទៅតាមប្រទេសនីមួយៗ ចំពោះប្រទេសដែលមានតួលេខកត់ត្រាក្នុងតារាងទី៨ ដែលផ្ដល់នូវការប៉ាន់ស្មានដំបូងនៃវិសមភាពនៃប្រាក់ចំណូលនៅក្នុងប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍។ ឧទាហរណ៍យើងឃើញថានៅក្នុងប្រទេសហ្សំប៊ីមានប្រជាជនក្រីក្រច្រើនបំផុត 20% (ត្រីមាសដំបូង) ទទួលបានត្រឹមតែ 3.6% ប៉ុណ្ណោះនៃប្រាក់ចំណូលខណៈដែលខ្ពស់បំផុត 10% និង 20% (ត្រីមាសទីប្រាំ) ទទួលបាន 38.9% និង 55.2% រៀងគ្នា។ ផ្ទុយទៅវិញនៅក្នុងការអភិវឌ្ឍដែលមានកម្រិតស្មើគ្នា ដូចជាប្រទេសជប៉ុន ប្រជាជនក្រីក្របំផុត 20% ទទួលបានច្រើនជាង 10.6% នៃប្រាក់ចំណូល ខណៈពេលដែលអ្នកមានបំផុត 10% និង 20% ទទួលបានតែ 21.7% និង 35.7% រៀងគ្នា។

តារាងទី៩៖ ប្រាក់ចំណូល និងវិសមភាពនៅក្នុងបណ្ដាប្រទេសនីមួយៗ ត្រូវបានជ្រើសរើស

| Country | Income Per Capita (U.S. $, 2008) | Gini Coefficient | Survey Year for Gini Calculation |
|---|---|---|---|
| **Low Income** | | | |
| Ethiopia | 280 | 29.8 | 2005 |
| Mozambique | 380 | 47.1 | 2003 |
| Nepal | 400 | 47.3 | 2004 |
| Cambodia | 640 | 40.7 | 2007 |
| Zambia | 950 | 50.7 | 2005 |
| **Lower Middle Income** | | | |
| India | 1,040 | 36.8 | 2005 |
| Cameroon | 1,150 | 44.6 | 2001 |
| Bolivia | 1,460 | 57.2 | 2007 |
| Egypt | 1,800 | 32.1 | 2005 |
| Indonesia | 1,880 | 37.6 | 2007 |
| **Upper Middle Income** | | | |
| Namibia | 4,210 | 74.3 | 1993 |
| Bulgaria | 5,490 | 29.2 | 2003 |
| South Africa | 5,820 | 57.8 | 2000 |
| Argentina | 7,190 | 48.8 | 2006 |
| Brazil | 7,300 | 55.0 | 2007 |
| Mexico | 9,990 | 51.6 | 2008 |
| **Upper Income** | | | |
| Hungary | 12,810 | 30.0 | 2004 |
| Spain | 31,930 | 34.7 | 2000 |
| Germany | 42,710 | 28.3 | 2000 |
| United States | 47,930 | 40.8 | 2000 |
| Norway | 87,340 | 25.8 | 2000 |

*Source:* World Bank, *World Development Indicators, 2010* (Washington, D.C.: World Bank, 2010), tabs. 1.1 and 2.9.

ប្រភព៖ ធនាគារពិភពលោក (សូចនាករអភិវឌ្ឍន៍ពិភពលោកឆ្នាំ២០១០)

ក្រឡេកមកមើលតារាងទី៩ បានផ្តល់ទិន្នន័យនៅលើការចែកចាយប្រាក់ចំណូលទាក់ទងនឹង GNI របស់មនុស្សម្នាក់ៗសម្រាប់គំរូនៃប្រទេស ដែលរៀបចំពីទាបទៅខ្ពស់ក្នុងលក្ខខណ្ឌនៃចំណូលរបស់មនុស្សម្នាក់ៗ។ ប្រទេស អេត្យូពី ម៉ូសំប៊ិក នេប៉ាល់ កម្ពុជា និងហ្សាំប៊ីមានវិសមភាពខ្ពស់ខ្លាំងដោយយោងទៅតាមស្តង់ដារអន្តរជាតិ បើទោះបីជាប្រទេសជាច្រើននៅអាមេរិកឡាទីន ដែលមានវិសមភាពខ្ពស់ក៏ដោយ ក៏ត្រូវបានគេរកឃើញនៅក្នុងជួរប្រទេសមានចំណូលមធ្យម ដូចជាប្រទេសអេហ្ស៊ីប និងឥណ្ឌូណេស៊ី ក៏ដូចជាបណ្តាប្រទេសនៅអឺរ៉ុបខាងកើត ដែលមានវិសមភាពទាប ចំណែកប្រទេសដែលមានចំណូលខ្ពស់មានទំនោរទៅរកភាពស្មើគ្នាជាជាងប្រទេស ដែលមានប្រាក់ចំណូលមធ្យម។ ប៉ុន្តែជាថ្មីម្តងទៀត គឺមានការប្រែប្រួលយ៉ាងខ្លាំងនៅក្នុងកម្រិតវិសមភាពនៃប្រាក់ចំណូល។

### ៤.៣.១.២ កំណើន និងវិសមភាព

ក្រាហ្វិកទី៣៖ កំណើនសេដ្ឋកិច្ចរយៈពេលវែង និងវិសមភាពនៃប្រាក់ចំណូល




Sources: World Bank, *World Development Indicators, 1998* (Washington, D.C.: World Bank, 1998), tab. 1.4; *Economist*, October 19, 1996, p. 82.

ប្រភព៖ ធនាគារពិភពលោក (សូចនាករអភិវឌ្ឍន៍ពិភពលោកឆ្នាំ១៩៩៨)

ដោយបានពិនិត្យមើលទំនាក់ទំនងរវាងវិសមភាព និងកម្រិតនៃប្រាក់ចំណូលរបស់មនុស្សម្នាក់ៗ បានអនុញ្ញាតឲ្យយើងមើលឃើញអំពីទំនាក់ទំនងរវាងកំណើនសេដ្ឋកិច្ច និងវិសមភាព។ នៅក្នុងក្រាហ្វិកទី៣ ជាទិន្នន័យរយៈពេលវែងពាក់កណ្ដាលទសវត្សរ៍ឆ្នាំ1960 និងពាក់កណ្ដាលទសវត្សរ៍ឆ្នាំ1990 ។ តារាងនេះផងដែរបានឆ្លុះបញ្ចាំងពីការពិតដែលគេស្គាល់ ថាវិសមភាពទាបអាស៊ីបូព៌ាបានកើនឡើងយ៉ាងឆាប់រហ័ស និងវិសមភាពខ្ពស់នៅអាមេរិកឡាទីន ហើយអាហ្វ្រិកមានការរីកចម្រើនយឺតណាស់។ វាក៏បង្ហាញផងដែរថាការផ្លាស់ប្ដូរនូវវិសមភាព ដូចដែលបានវាស់វែងដោយមេគុណ Gini មានទំហំតូចនៅក្នុងតំបន់នីមួយៗរវាងឆ្នាំ1960 និងឆ្នាំ 1990 ។ ក្នុងអំឡុងពេលទាំងនោះ កំណើនចំណូលមនុស្សម្នាក់ៗនៅអាស៊ីបូព៌ាមានជាមធ្យម 5.5% ខណៈពេលដែលទ្វីបអាហ្វ្រិកធ្លាក់ចុះ 0.2% ។

## ៤.៤ បញ្ហា និងដំណោះស្រាយជុំវិញវិសមភាពនៃប្រាក់ចំណូល

### ៤.៤.១ បញ្ហាប្រឈម

នៅក្នុងប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងប្រទេសអភិវឌ្ឍន៍ភាគច្រើនប្រាក់ចំណូលទីផ្សារភាគច្រើនបានមកពីប្រាក់ឈ្នួល និងប្រាក់ខែ ប៉ុន្តែក៏មានពីប្រាក់ចំណេញលើដើមទុន ដូចជាភាគហ៊ុន និងថ្លៃជួលផងដែរ។ ប្រាក់ចំណូលទីផ្សាររបស់ប្រជាជនត្រូវបានកាត់បន្ថយដោយការយកពន្ធ និងឬបានកើនឡើងដោយការផ្ទេររបស់រដ្ឋាភិបាលដូចជាប្រាក់សោធននិវត្តន៍។ វិសមភាពនៅក្នុងសង្គមមួយត្រូវបានវាស់ជាសមាមាត្រនៃប្រាក់ចំណូលពីខ្ពស់ទៅទាប ឧទាហរណ៍៖ សមាមាត្រនៃប្រាក់ចំណូលខ្ពស់បំផុត 20% នៃចំណូលគ្រួសារស្មើនឹងទាបបំផុត 20% ។ វាចាំបាច់ក្នុងការបែងចែករវាងវិសមភាព ទ្រព្យសម្បត្តិ និងភាពក្រីក្រ ដែលប្រទេសអ្នកមាន អាចមានភាពមិនស្មើគ្នា ហើយប្រទេសក្រីក្រអាចមានចំនួនស្មើគ្នា។

#### ៤.៤.១.១ ចល័តភាពនៃសង្គម

ដោយសារវិសមភាពសង្គម ឬភាពមិនស្មើគ្នានៃប្រាក់ចំណូល និងទ្រព្យសម្បត្តិ (Income and wealth inequality) បាននឹងកំពុងបន្តកើនឡើងចាប់តាំងពីទសវត្សរ៍ឆ្នាំ1990 បានលេចចេញនូវបញ្ហាចល័តភាពនៃសង្គម (social mobility) ស្ថានភាពនេះសំដៅទៅដល់បញ្ហាមួយ ដែលក្រុមពលរដ្ឋពីគ្រួសារក្រីក្រនោះមានប្រាក់ចំណូលទាប ដែលអាចកែប្រែជោគវាសនារបស់ខ្លួនមករស់នៅក្នុងជីវភាពល្អប្រសើរឡើងវិញកាន់តែមានចំនួនតិចតួចទៅៗ ខណៈក្រុមពលរដ្ឋអ្នកមានបំផុតក្នុងសង្គមចេះតែបន្តកើនឡើង ដោយបង្កើនប្រាក់ចំណូល និងទ្រព្យសម្បត្តិរបស់ខ្លួនកាន់តែច្រើនឡើងៗ។ និន្នាការបែបនេះត្រូវព្រមានដោយអ្នកជំនាញ ថាអាចនឹងបង្កផលវិបាកដល់សង្គម និងសេដ្ឋកិច្ចទាំងក្នុងពេលអតីតកាល បច្ចុប្បន្ន និងនៅថ្ងៃអនាគតផងដែរនេះបើយោងតាមការចេញផ្សាយជារបាយការណ៍របស់ OECD ។ របាយការណ៍នេះ បានបង្ហាញថាបើផ្អែកតាមកម្រិតនៃវិសមភាពសង្គមបច្ចុប្បន្ន និងចល័តភាពនៃប្រាក់ចំណូល ពីមនុស្សមួយជំនាន់ទៅមួយជំនាន់គេត្រូវការពេលយ៉ាងហោច

ណាស់មនុស្សប្រាំជំនាន់ ឬស្មើប្រហែល 150 ឆ្នាំសម្រាប់កុមារពីគ្រួសារក្រីក្រ ដែលអាចកែប្រែជោគវាសនារបស់ខ្លួនដើម្បីទទួលបានប្រាក់ចំណូលជាមធ្យមនៅបណ្តាប្រទេសសមាជិកអង្គការសម្រាប់សហប្រតិបត្តិការ និងការអភិវឌ្ឍសេដ្ឋកិច្ច(Organization for Economic Cooperation and Development -OECD)។ នៅក្នុងន័យនេះ មួយជំនាន់មនុស្សអាចប្រហែលស្មើនឹងរយៈពេល 30 ឆ្នាំ គឺគេគិតពីពេលមនុស្សកើតហើយអាចបង្កើតជំនាន់មនុស្សថ្មីឧទាហរណ៍៖ នៅក្នុងប្រទេសអឺរ៉ុបខាងជើង តួយ៉ាងប្រទេសដាណឺម៉ាក ហ្វាំងឡង់ ន័រវែស ឬក៏ប្រទេសស៊ុយអែតគេសង្កេតឃើញថាក្មេងពីគ្រួសារក្រីក្រប្រើរយៈពេលត្រឹមតែពីរ ឬបីជំនាន់មនុស្សប៉ុណ្ណោះនេះបើប្រៀបធៀបទៅនឹងបណ្តាប្រទេស ដែលមានសេដ្ឋកិច្ចកំពុងលូតលាស់ផ្សេងៗទៀត ពីព្រោះប្រទេសទាំងនោះត្រូវការពេលវេលាអាចរហូតដល់ជាងមនុស្ស ៩ ជំនាន់។

ពីមួយជំនាន់ទៅមួយជំនាន់ ចល័តភាពសង្គមមានទំនោរធ្លាក់ចុះនៅក្នុងបណ្តាប្រទេស ដែលមានវិសមភាពនៃប្រាក់ចំណូលកាន់តែកើនឡើងខ្ពស់ហើយអត្រាកាន់តែកើនឡើងខ្លាំងនៅក្នុងបណ្តាប្រទេស ដែលមានវិសមភាពសង្គមទាប។ នៅបណ្តាប្រទេសអឺរ៉ុបខាងជើង ដែលមានវិសមភាពសង្គមទាប ជាប្រទេសដែលមានចល័តភាពសង្គមខ្ពស់ខណៈបណ្តាប្រទេសអាមេរិកឡាទីន និងប្រទេសកំពុងអភិវឌ្ឍមួយចំនួន ដែលមានវិសមភាពសង្គមខ្ពស់ច្រើនតែជាប្រទេស ដែលមានចល័តភាពសង្គមទាបទៅវិញ។ ហេតុអ្វីបានជាប្រទេសអឺរ៉ុបខាងជើងធ្វើបានល្អយ៉ាងនេះ? យោងតាមអ្នកជំនាញប្រទេសទាំងនោះជាដែនដីនៃឱកាសស្មើគ្នា (Land of Equal Opportunity) ព្រោះមនុស្សរាល់គ្នាក្នុងសង្គមអាចទទួលបានសេវាកម្មអប់រំ សេវាសុខាភិបាល ឱកាសការងារ ឬឱកាសការអភិវឌ្ឍខ្លួនជាដើមយ៉ាងសម្បូរបែប ហើយអ្វីដែលពួកគេខ្វះខាត គឺការខិតខំប្រឹងប្រែងតែប៉ុណ្ណោះ។

### ៤.៤.១.២ សុខភាព និងការអប់រំ

អ្នកស្រាវជ្រាវជនជាតិអង់គ្លេស Richard G. Wilkinson និង Kate Pickett[33] បានរកឃើញអត្រាខ្ពស់នៃបញ្ហាសុខភាព ការអប់រំ និងសង្គម (ជំងឺផ្លូវចិត្ត មនុស្សឃាត កំណើតក្នុងវ័យជំទង់ ការជាប់ឃុំឃាំងជម្លោះកុមារ ឬគ្រួសារ ការប្រើប្រាស់គ្រឿងញៀន អត្រាទាបនៃផលិតផលទំនិញ និងសេវាកម្ម អាយុសង្ឃឹមរស់តាមប្រទេស)។ ដំណើរការអប់រំ ការជឿទុកចិត្ត ដែលស្ថានភាពរបស់ស្ត្រីភាពចល័តក្នុងសង្គម សូម្បីតែចំនួនប៉ាតង់ដែលបានចេញនៅក្នុងប្រទេស និងរដ្ឋដែលមានវិសមភាពខ្ពស់ជាង ដោយប្រើស្ថិតិពីប្រទេសអភិវឌ្ឍន៍ចំនួន ២១ ប្រទេស (សូមមើលក្រាហ្វិកទី៤) បានរកឃើញបញ្ហាសង្គម សុខភាពទាបជាងប្រទេសជប៉ុន និងហ្វាំងឡង់

[33] *Pickett, KE; Wilkinson, RG (March 2015). "Income inequality and health: a causal review". Social Science & Medicine. 128: 316–26. Downloaded on 19 June 2022 at 10:30AM.* https://doi.org/10.1016%2Fj.socscimed.2014.12.031

ដែលមានកម្រិតសមភាពខ្ពស់ជាងប្រទេស (សហរដ្ឋអាមេរិក និងចក្រភពអង់គ្លេស) ជាមួយនឹងភាពខុសគ្នាដ៏ធំនៃប្រាក់ចំណូលគ្រួសារ។

ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ លក្ខណៈដែលមានទំនាក់ទំនងយ៉ាងខ្លាំងជាមួយនឹងសុខភាពនៅក្នុងប្រទេសអភិវឌ្ឍន៍គឺវិសមភាពប្រាក់ចំណូល។ បញ្ហាសុខភាព និងសង្គម អ្នកនិពន្ធ Richard Wilkinson និង Kate Pickett បានរកឃើញបញ្ហាសុខភាព និងសង្គម ជាទូទៅនៅក្នុងប្រទេសដែលមានវិសមភាពប្រាក់ចំណូលធំជាង។ ជាមួយនឹងវិសមភាពប្រាក់ចំណូលធំជាង ការសិក្សាផ្សេងទៀតបានបញ្ជាក់ពីទំនាក់ទំនងនេះ សន្ទស្សន៍របស់អង្គការយូនីសេហ្វ (ស្តីអំពី៖ សុខុមាលភាពកុមារនៅក្នុងប្រទេសអភិវឌ្ឍន៍) ដោយសិក្សាពីសូចនាករចំនួន ៤០ នៅក្នុងប្រទេសចំនួន ២១ ទាក់ទងនឹងសមភាពកាន់តែច្រើនប៉ុន្តែមិនមែនប្រាក់ចំណូលសម្រាប់មនុស្សម្នាក់នោះទេ។ Pickett និង Wilkinson ប្រកែកថា វិសមភាព និងការបែងចែកសង្គមនាំទៅរកកម្រិតខ្ពស់នៃភាពតានតឹងផ្លូវចិត្ត និងការថប់អារម្មណ៍ក្នុងស្ថានភាពដែលអាចនាំឱ្យមានជំងឺធ្លាក់ទឹកចិត្តការពឹងផ្អែកលើសារធាតុគីមី ជីវិតសហគមន៍តិច បញ្ហាឪពុកម្តាយ និងជំងឺដែលទាក់ទងនឹងភាពតានតឹង។

ក្រាហ្វិកទី៤៖ បញ្ហាសុខភាព និងសង្គមកាន់តែអាក្រក់ទៅៗនៅក្នុងប្រទេស ដែលមិនស្មើគ្នា




ប្រភព៖ Wilkinson & Pickett, The Spirit Level (២០០៩)

**ក. បញ្ហាប្រឈមនឹងសុខភាព**

ប្រសិនបើមនុស្សមិនមានសុខភាពល្អ ពួកគេនឹងមិនអាចធ្វើការដើម្បីផលិតភាពពេញលេញរបស់ពួកគេទេ។ ការដឹងថា តើវិសមភាពគឺជាបុព្វហេតុផ្ទាល់នៃសុខភាពមិនល្អ (ផ្ទុយពីការដែលគ្រាន់តែការទាក់ទងនឹងវាក៏ដោយ) គឺពិបាក។ នៅលើតុល្យភាពនៃការស្រាវស្រាវ ហាក់ដូចជាបង្ហាញថាវិសមភាពបណ្តាលឲ្យមានសុខភាពមិនល្អ។ យន្តការដែលអាចកើតមានមួយសម្រាប់បញ្ហានេះគឺតាមរយៈការកើនឡើងនៃភាពតានតឹងដែលជាកត្តាហានិភ័យដែលត្រូវបានគេស្គាល់ចំពោះជំងឺជាច្រើន។ ជាពិសេសការស្រាវជ្រាវរបស់អង្គការសុខភាពពិភពលោក (WHO) បង្ហាញថានៅអឺរ៉ុបមានប្រទេសមិនស្មើភាពគ្នាជាច្រើនមានលទ្ធផលសុខភាពផ្លូវចិត្តខ្សោយ។

និយាយងាយយល់ជាងនេះទៅទៀត គឺនៅក្នុងប្រទេសអ្នកមានភាគច្រើនមានការថយចុះនូវការចំណាយតិចតួចទៅលើការចំណាយរបស់បុគ្គលម្នាក់ៗចំពោះសុខភាព ដូច្នេះការផ្ទេរថវិកាពីការព្យាបាលអ្នកមានទៅព្យាបាលអ្នកក្រ អាចកាត់បន្ថយទាំងវិសមភាព និងធ្វើអោយប្រសើរឡើងនូវសុខភាពប្រជាជនសរុប។

**ខ. បញ្ហាប្រឈមក្នុងការអប់រំ**

ប្រសិនបើកុមារមិនសូវជោគជ័យនៅក្នុងសាលារបស់ពួកគេទេ នោះពួកគេទំនងនឹងក្លាយជាកម្មករដែលមានជំនាញទាបលើសមត្ថភាពផលិតភាពរបស់ពួកគេ ហើយដូច្នេះសមត្ថភាពផលិតភាពនៃសេដ្ឋកិច្ចត្រូវបានថយចុះ។ ការស្រាវជ្រាវរបស់ OECD សន្និដ្ឋានថាគោលនយោបាយដើម្បីកែលម្អអត្រាបញ្ចប់ការសិក្សានៅវិទ្យាល័យ និងឧត្តមសិក្សាក៏ធ្វើឲ្យប្រសើរឡើងនូវផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់ៗផងដែរ។ ដោយវិសមភាពបានកាត់បន្ថយការអនុវត្តន៍ ដោយសារតែផលប៉ះពាល់ដាច់ដោយឡែករបស់វា។ មានភស្តុតាងជាច្រើនដែលបង្ហាញថាជោគជ័យរបស់កូនៗយ៉ាងហោចណាស់ផ្នែកខ្លះអាស្រ័យទៅលើផលប្រយោជន៍ និងសេចក្តីប្រាថ្នារបស់មិត្តភក្តិ។ ឥទ្ធិពលរបស់មិត្តភក្តិគឺធំជាងឥទ្ធិពលនៃសាលារៀនរួមទាំងគុណភាពគ្រូបង្រៀនផងដែរ។ ប្រសិនបើសាលារៀនត្រូវបានបែងចែកជាក្រុមកុមារពីគ្រួសារ ដែលមានវិបត្តិសេដ្ឋកិច្ចសង្គមនឹងលាយបញ្ចូលគ្នាជាមួយកុមារ ដែលជួបការលំបាកដទៃទៀតហើយដូច្នេះជាមួយកុមារដែលមិនសូវធ្វើបានល្អនៅសាលា។ ការបែងចែកគឺទំនងជានៅក្នុងសង្គមមិនស្មើគ្នា។ ផលប៉ះពាល់អវិជ្ជមានរបស់កុមារក្រីក្រដែលសេពគប់ជាមួយកុមារដែលមានទេពកោសល្យច្រើនជាង។ ដូច្នេះវិសមភាពអាចបណ្តាលឲ្យមានការថយចុះក្នុងការសម្រេចបានការអប់រំផងដែរ។

**៤.៤.១.៣ បញ្ហាកំណើនសេដ្ឋកិច្ច**

មានសេដ្ឋកិច្ចវិទូមួយចំនួនដូចជា Simon Kuznets និង Arthur Okun បានគាំទ្រថាវិសមជាភាពល្អសំរាប់កំណើនសេដ្ឋកិច្ច តែទោះជាយ៉ាងណាក៏ដោយ មានភស្តុតាងថ្មីពី OECD IMF និង ផ្សេងៗទៀតបានលើកឡើងថា វិសមភាពហួសហេតុគឺមិនល្អសម្រាប់កំណើនទេ។ ការស្រាវជ្រាវថ្មីៗរបស់ OECD បង្ហាញឲ្យ

ឃើញថាផលប៉ះពាល់នេះអាចមានច្រើន នៅក្នុងបណ្តាប្រទេស OECD ការកើនឡើងជាមធ្យមនៅក្នុងវិសមភាព នៃGini ៣ ពិន្ទុប្រហែលពីរបីទសវត្សរ៍កន្លងមកនេះត្រូវបានគេប៉ាន់ស្មាន ថាបានកាត់បន្ថយផលិតផលក្នុងស្រុកសរុបប្រហែល 8.5%។ ( មេគុណGini ត្រូវបានវាស់នៅលើមាត្រដ្ឋានសូន្យទៅមួយ) ។ Giniនៃសូន្យ បង្ហាញថាអ្នករាល់គ្នានៅក្នុងក្រុមដែលបានកំណត់មានប្រាក់ចំណូលស្មើៗគ្នា។ ទោះយ៉ាងណាលទ្ធផលនេះមិនចាំបាច់ល្អនោះទេ ព្រោះថាមនុស្សគ្រប់គ្នានៅក្នុងក្រុមអាចក្រ ឬក្រីក្រដូចៗគ្នា។ Gini នៃមនុស្សម្នាក់ៗ មានន័យថា កម្មករម្នាក់រកប្រាក់ចំណូលទាំងអស់ហើយគ្រប់គ្នាផ្សេងទៀតសូន្យ។ លទ្ធផលនេះមិនចាំបាច់អាក្រក់នោះទេ ព្រោះគ្រួសារជាច្រើនពឹងផ្អែកលើប្រាក់ចំណូលរបស់បុគ្គលតែមួយ ដែលសន្មតថា ក្រុមនេះគឺជាគ្រួសារ។ សន្ទស្សន៍ Gini តាមដានសង្គមណាដែលមិនស្មើគ្នាបំផុត)។

### ៤.៤.១.៤ អស្ថេរភាពសេដ្ឋកិច្ច

សេដ្ឋវិទូមួយចំនួនបានអះអាងថាវិសមភាពនាំឲ្យមានអស្ថិរភាពសេដ្ឋកិច្ច។ យន្តការមួយ ដែលរឿងនេះកើតឡើងគឺថាអ្នកមានប្រើប្រាស់បរិមាណប្រាក់ចំណូលតិចជាងអ្នកក្រ។ ពួកគសន្សំប្រាក់ ដែលមនុស្សដែលមានប្រាក់ចំណូលទាបនឹងត្រូវចំណាយ។ នេះនាំឲ្យមានការកាត់បន្ថយតម្រូវការសរុបដែលជាលទ្ធផលនាំឲ្យមានភាពអត់ការងារធ្វើ។ ជាការឆ្លើយតបរដ្ឋាភិបាល ចាត់វិធានការបន្ទាន់ដើម្បីជំរុញតម្រូវការដូចជាការបញ្ចុះនូវអត្រាការប្រាក់។ ទន្ទឹមនឹងនេះនៅពេលវិសមភាពកើនឡើងបុគ្គលដែលប្រឈមនឹងប្រាក់ចំណូលទាប ឬថយចុះរក្សាចំណូលរបស់ពួកគេតាមរយៈការខ្ចីប្រាក់ (ផ្តល់ហិរញ្ញប្បទានដោយការសន្សំរបស់អ្នកមាន) ។ ការកើនឡើងតិចតួចបំផុតនៃអត្រាគ្មានការងារធ្វើ ឬអត្រាការប្រាក់អាចបណ្តាលឲ្យមានលំនាំដើមលើប្រាក់កម្ចីអតិថិជនហើយអាចមានលទ្ធផលមហន្តរាយ ដែលមានការឯកភាពគ្នាមួយចំនួនដែលវិសមភាពនៅក្នុងប្រទេសជឿនលឿនបានជួយបណ្តាលអោយមានវិបត្តិហិរញ្ញវត្ថុពិភពលោក។

## ៤.៤.២ ដំណោះស្រាយ

### ៤.៤.២.១ ការពង្រឹងនូវចល័តភាពនៃសង្គម

ជាទូទៅចល័តភាពនៃសង្គមបានប្រែក្លាយឱកាសដល់ប្រជាជនក្រីក្រ ដោយទទួលបាននូវការងើបចេញពីភាពក្រីក្រ ក្លាយជាអ្នកដែលមានចំណូលមធ្យម និងខ្ពស់ ពោលចល័តភាពសង្គមបានជម្រុញទៅដល់ដំណើរការមួយ ដែលក្រុមពលរដ្ឋពីគ្រួសារក្រីក្រអាចកែប្រែនូវជោគវាសនារបស់ខ្លួនឲ្យមានជីវភាពល្អប្រសើរឡើងវិញ។ ប៉ុន្តែលក្ខខណ្ឌទាំងអស់នេះ វាពុំសមស្របទៅហ្នឹងប្រទេសដែលមានវិសមភាពនៃប្រាក់ចំណូលខ្ពស់ទេ ជាពិសេសប្រទេសកំពុងអភិវឌ្ឍន៍ ដែលធ្វើឲ្យការប្រែក្លាយនូវជីវភាពរបស់ពួកគេជួបប្រទះនូវបញ្ហា។ ដើម្បីជម្រុញទៅដល់ចល័តភាពនៃសង្គមឲ្យកាន់តែប្រសើរហើយមានរយៈពេលខ្លី និងលឿនឆាប់រហ័ស យើងត្រូវយកចិត្តទុកដាក់ទៅលើការបង្កើតឱកាសការងារទៅដល់អ្នកមានចំណូលទាប ដោយផ្សារភ្ជាប់ជាមួយគោលនយោបាយ

បាញ់ឆ្ពោះទៅរកការកែតម្រូវនូវថ្លៃកត្តាផលិតកម្ម ការបែងចែកឡើងវិញនូវម្ចាស់ទ្រាប់សម្បត្តិសម្រាប់ប្រទេសដែលមានវិសមភាពចំណូលខ្លាំង រួមជាមួយការបង្កើនពន្ធលើអ្នកមានចំណូលខ្ពស់ និងផ្ទេលុយទៅឲ្យអ្នកមានចំណូលទាបតាមសេវាសាធារណៈ។ ជាពិសេសជាងនេះទៅទៀត គឺការបង្កើននូវការវិនិយោគផ្ទាល់បរទេសចូលទៅក្នុងប្រទេសនោះ ព្រោះការវិនិយោគផ្ទាល់ពីបរទេសជាមូលធនដ៏សំខាន់ ជាពិសេសគឺបង្កើនការងារទៅដល់ប្រជាជននៅក្នុងប្រទេសនោះតាមរៈវិស័យផ្សេងៗក្នុងគោលបំណង គឺដើម្បីបង្កើនចំណូល ការកាត់បន្ថយវិសមភាពនៃប្រាក់ចំណូល និងចល័តភាពនៃសង្គមមានការកើនឡើងយ៉ាងឆាប់រហ័ស។

**៤.៤.២.២ លើកកម្ពស់ផ្នែកសុខភាព និងការអប់រំ**

សុខភាព និងការអប់រំ គឺជាកម្មវត្ថុដ៏សំខាន់មួយនៃការអភិវឌ្ឍ និងការកាត់បន្ថយនូវវិសមភាពនៃប្រាក់ចំណូលរបស់ប្រជាជននៅក្នុងប្រទេស។ ទោះបីជាយ៉ាងនេះក្ដី វិសមភាពនៃប្រាក់ចំណូលបានធ្វើឲ្យមានការរាំងស្ទះទៅដល់សុខភាព និងការអប់រំផងដែរ ពីព្រោះកាលណាប្រជាជនមានគម្លាតចំណូលខ្លាំងវាបានធ្វើឲ្យការទទួលបាននូវសេវាសុខភាព និងការអប់រំពុំស្មើគ្នាជាហេតុធ្វើឲ្យមានការរាំងស្ទះដល់ការអភិវឌ្ឍ។ ដើម្បីជម្រុញទៅដល់ការលើកកម្ពស់នូវសុខភាព និងការអប់រំ យើងត្រូវបង្កើននូវការធ្វើឲ្យប្រសើរឡើងវិញ ដូចជាការបង្កើនការកសាងនូវមន្ទីពេទ្យ និងសាលារៀនគ្រប់តំបន់ទូទាំងប្រទេស ពីព្រោះសុខភាពបានបំពេញលក្ខខណ្ឌសំខាន់សម្រាប់កំណើនផលិតភាព ពោលមនុស្សដែលមានសុខភាពល្អគឺមានផលិតភាពខ្ពស់(Output/labor)។ ការដាក់ចេញនូវយុទ្ធសាស្ត្រស្តីអំពី សុខភាព និងការអប់រំ ដែលគឺជាការវិនិយោគរួមសម្រាប់ការអភិវឌ្ឍ និងកាត់បន្ថយនូវវិសមភាពនៃប្រាក់ចំណូល ពោលសុខភាពជាកត្តាមួយដែលធ្វើឲ្យមានការរៀនសូត្រពេញលេញ ដោយកូនសិស្សដែលមានសុខភាពល្អច្រើនទទួលបាននូវប្រសិទ្ធភាពជាជាងអ្នក ដែលមិនមានសុខភាពល្អផងដែរ។ ម្យ៉ាងវិញទៀត អ្នកដែលមានសុខភាពល្អ ជាទូទៅគឺអាចប្រើប្រាស់នូវចំណេះដឹងផ្សេងៗ ដែលខ្លួនទទួលបានពីសាលាយកមកប្រកបការងារមានប្រសិទ្ធភាពខ្ពស់ និងមានការងារល្អ ដែលជាហេតុធ្វើឲ្យពួកគេមានឱកាសទទួលបាននូវប្រាក់ចំណូលខ្ពស់ដូចៗគ្នា។

# ជំពូកទី ៥
# ទំនាក់ទំនងរវាង (FDI) និងការកាត់បន្ថយវិសមភាពនៃប្រាក់ចំណូល៖ ករណីសិក្សាប្រទេសកម្ពុជា

## ៥.១ សេចក្តីផ្តើម

ប្រទេសកម្ពុជាបានរៀបចំរចនាសម្ព័ន្ធសេដ្ឋកិច្ចរបស់ខ្លួនឡើងវិញ បន្ទាប់ពីបានឆ្លងកាត់នូវសង្គ្រាមអូសបន្លាយ និងអស្ថិរភាពជាច្រើនឆ្នាំ។ សេដ្ឋកិច្ចកម្ពុជា[34] បានកើនឡើងយ៉ាងខ្លាំងក្លាបន្ទាប់ពីមានការផ្លាស់ប្តូររបបប្រទេសទៅជាសេដ្ឋកិច្ចទីផ្សារសេរី ដែលក្នុងនោះប្រទេសកម្ពុជាបានបើកចំហឲ្យមានពាណិជ្ជកម្ម និងលំហូរមូលធន។ កំណើនសេដ្ឋកិច្ចនេះ ត្រូវបានគាំទ្រដោយលំហូរនៃជំនួយអភិវឌ្ឍន៍ផ្លូវការបានចូលទៅកាន់ទីផ្សាររបស់សហគមន៍អឺរ៉ុប និងសហរដ្ឋអាមេរិក ក៏ដូចជាលំហូរនៃការវិនិយោគផ្ទាល់ពីបរទេសយ៉ាងច្រើនសន្ធឹកសន្ធាប់។

ជាទូទៅ ការវិនិយោគផ្ទាល់ពីបរទេស (FDI) ត្រូវបានគេមើលឃើញថាជាកម្លាំងជំរុញនូវកំណើនសេដ្ឋកិច្ច និងលើកកម្ពស់ការអភិវឌ្ឍសង្គមក្នុងការកាត់បន្ថយនូវវិសមភាពនៃប្រាក់ចំណូលរបស់ប្រជាជនសម្រាប់ប្រទេសអភិវឌ្ឍន៍ និងកំពុងអភិវឌ្ឍន៍ដូចគ្នា។ ជាក់ស្តែង ប្រទេសកម្ពុជាបានទទួលអត្ថប្រយោជន៍ផងដែរពី FDI[35] ក្នុងការកាត់បន្ថយនូវគម្លាតចំណូលរបស់ប្រជាជាជន ជាពិសេសប្រជាជននៅតាមទីជនបទ និងទីក្រុង ដែលមានឱកាសទទួលបាននូវប្រាក់ចំណូលប្រហាក់ប្រហែលគ្នា ឬលើសគ្នាតិចតួច។ លំហូរវិនិយោគផ្ទាល់ពីបរទេសមកក្នុងប្រទេសកម្ពុជាបានកើនឡើងយ៉ាងខ្លាំងចាប់ពីដើមឆ្នាំ2000 ដោយសារតែគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចប្រកបដោយការប្រុងប្រយ័ត្នខ្ពស់ ស្ថិរភាពនយោបាយ និងការបើកចំហទីផ្សារ ក៏ដូចជាឥទ្ធិពលនៃកំណើនសេដ្ឋកិច្ចក្នុងតំបន់។

## ៥.២ FDI បានជម្រុញដល់ការកាត់បន្ថយវិសមភាពនៃប្រាក់ចំណូលក្នុងប្រទេសកម្ពុជា

យោងតាមការអង្កេតវិនិយោគផ្ទាល់ពីបរទេសឆ្នាំ2014 មាននិយោជិតចំនួន 131,428 នាក់ ដែលបានបម្រើការងារនៅក្នុងសហគ្រាសចំនួន 117 ដែលក្នុងចំណោមនិយោជិតទាំងអស់នោះ 96% ជាពលរដ្ឋកម្ពុជា។ វិស័យកម្មន្តសាលស្រូបយកនិយោជិតប្រមាណ 75% (ឬ 98,362 នាក់) នៃនិយោជិតសរុបបន្ទាប់មក គឺវិស័យ

[34] *ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) (យុទ្ធសាស្ត្រនៃភាពជាដៃគូប្រទេសកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ីឆ្នាំ២០១៩-២០២៣) ខែតុលា ឆ្នាំ២០១៩។ បានទាញយកនៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ2022 ម៉ោង 6:00 ល្ងាច។*
https://www.adb.org/sites/default/files/institutional-document/534691/cps-cam-2019-2023.pdf

[35] *សន្និសីទអង្គការសហប្រជាជាតិស្តីពីពាណិជ្ជកម្ម និងការអភិវឌ្ឍ (UNCTAD) (មគ្គុទេសក៍ការវិនិយោគនៃប្រទេសកម្ពុជា ៖ ឱកាសនិងលក្ខខណ្ឌនានា) ខែកញ្ញា ឆ្នាំ២០០៣។ បានទាញយកនៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ2022 ម៉ោង 7:00 ល្ងាច។*
https://unctad.org/system/files/official-document/iteiia20036_en.pdf

សិល្បៈការកម្សាន្ត និងការសម្តែចំនួន 9% (ឬ 11,667 នាក់) កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (ផលិតកម្មដំណាំ និងសត្វ ការប្រមាញ់ និងសកម្មភាពសេវាកម្មពាក់ព័ន្ធ) ចំនួន 8% (ឬ 10,066 នាក់) និងព័ត៌មានវិទ្យា និងទូរគមនាគមន៍ចំនួន 3% (ឬ 4,530 នាក់) អាជីវកម្មលក់ដុំ និងលក់រាយ ជួសជុលយានយន្ត និងទោចក្រក្រយានយន្តគ្រប់ប្រភេទចំនួន 2% (ឬ 1,984 នាក់) ការដឹកជញ្ជូន និងការស្តុកទុកចំនួន 2% (ឬ 1,916 នាក់) និងសកម្មភាពរដ្ឋបាល និងសេវាកម្មគាំទ្រចំនួន 1% (ឬ 1,599 នាក់) ហើយវិស័យដែលនៅសេសសល់ផ្សេងៗទៀតមានចំនួន 1% ។ និយោជិតបរទេសត្រូវបានផ្តល់ការងារក្រោមលក្ខខណ្ឌដូចគ្នានឹងនិយោជិតខ្មែរដែរ ដែលមានបង្ហាញនៅក្នុងតារាងទី១០ ។ *បញ្ជាក់៖ ទិន្នន័យខាងក្រោមនេះគឺគ្រាន់តែជារបាយការណ៍អំពីលទ្ធផលអង្កេត ដែលស្រង់ទិន្នន័យចេញពីសហគ្រាសមួយចំនួនដែលកំពុងមានសកម្មភាពក្នុងអំឡុងពេលនោះប៉ុណ្ណោះ ( ឆ្នាំ២០១៤ ) ។*

តារាងទី១០៖ របាយការណ៍ចំនួននិយោជិតធ្វើការក្នុងវិស័យនីមួយៗនៅចុងឆ្នាំ២០១៤

| វិស័យ | ខ្មែរ | | បរទេស | |
|---|---|---|---|---|
| | ប្រុស | ស្រី | ប្រុស | ស្រី |
| កម្មន្តសាល | 15,543 | 81,372 | 846 | 601 |
| សិល្បៈ ការកម្សាន្ត និងការលម្ហែ | 4,430 | 6,423 | 476 | 338 |
| កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | 5,280 | 1,723 | 2,240 | 823 |
| ព័ត៌មានវិទ្យា និងទូរគមនាគមន៍ | 3,139 | 1,179 | 201 | 11 |
| អាជីវកម្មលក់ដុំលក់រាយ ជួសជុលរថយន្ត និងទោចក្រយាន | 1,235 | 699 | 43 | 7 |
| ការដឹកជញ្ជូន និងការស្តុកទុក | 1,428 | 448 | 34 | 6 |
| សកម្មភាពរដ្ឋបាល និងសេវាកម្មគាំទ្រ | 1,363 | 195 | 1 | 0 |
| សកម្មភាពសេវាកម្មស្នាក់នៅ និងអាហារ | 540 | 316 | 10 | 11 |
| សកម្មភាពអចលនទ្រព្យ | 99 | 31 | 29 | 1 |
| ការអប់រំ | 39 | 45 | 25 | 39 |
| ការផ្គត់ផ្គង់អគ្គសនី ឧស្ម័ន ចំហាយទឹក និងប្រព័ន្ធខ្យល់ត្រជាក់ | 76 | 10 | 8 | 0 |
| ប្រតិបត្តិការ និងអាជីវកម្មធនធានរ៉ែ | 46 | 5 | 11 | 0 |
| សំណង់ | 2 | 1 | 0 | 0 |
| **សរុប** | **33,220** | **92,447** | **3,924** | **1,837** |

ប្រភព៖ របាយការណ៍អំពីលទ្ធផលអង្កេតវិនិយោគផ្ទាល់ពីបរទេសឆ្នាំ២០១៤

តម្លៃពលកម្មទាប គឺជាគុណសម្បត្តិសំខាន់បំផុតមួយសម្រាប់ការវិនិយោគនៅក្នុងប្រទេសកម្ពុជា ដែលជាប្រទេសសម្បូរដោយនិយោជិតមានសក្តានុពល។ លើសពីនេះទៅទៀត ការវិនិយោគផ្ទាល់ពីបរទេសក្នុងវិស័យខាងលើនេះ បានជម្រុញឲ្យនិយោជិតខ្មែរទាំងអស់ទទួលបាននូវប្រាក់ចំណូលពីការប្រកបការងារនៅតាមបណ្តាក្រុមហ៊ុនក្នុងវិស័យនីមួយៗ ដែលធ្វើឲ្យជីវភាពរបស់ពួកគេមានភាពល្អប្រសើរក្នុងឱកាសទទួលបាននូវប្រាក់ចំណូលសម្រាប់ផ្គត់ផ្គង់តម្រូវការផ្ទាល់ខ្លួន និងគ្រួសាររបស់ពួកគេទៀតផង។

### ៥.២.១ វិស័យកាត់ដេរសម្លៀកបំពាក់

វិស័យកាត់ដេរសម្លៀកបំពាក់[36] គ្របដណ្តប់ការផលិតសម្លៀកបំពាក់ ស្បែកជើង វាយនភ័ណ្ឌ និងផលិតផលវាយនភ័ណ្ឌផ្សេងៗទៀត ដូចជាកាបូប ស្រោមដៃ។ បន្ថែមទៅនឹងទិន្នន័យស្ថិតិជញ្ជីងទូទាត់ និងស្ថានភាពវិនិយោគអន្តរជាតិ ដែលពាក់ព័ន្ធទៅនឹងវិនិយោគផ្ទាល់ពីបរទេស ប្រទេសជាច្រើន (រួមមានប្រទេសមួយចំនួនរបស់ប្រទេស ដែលជាសមាជិកអាស៊ាន) បានចាប់ផ្តើមប្រមូលទិន្នន័យពីក្រុមហ៊ុនបុត្រសម្ព័ន្ធបរទេស ដែលពាក់ព័ន្ធទៅនឹងប្រតិបត្តិការរបស់ខ្លួន ផ្អែកតាមអនុសាសន៍នៃ UNCTAD OECD និង IMF ។ ទិន្នន័យទាំងនេះ ត្រូវបានគេហៅថា ក្រុមហ៊ុនបុត្រសម្ព័ន្ធបរទេស (FATS) ។ ក្រុមហ៊ុនបុត្រសម្ព័ន្ធបរទេស ត្រូវបានកំណត់ន័យសម្រាប់គោលបំណងនេះ ដោយសារសហគ្រាសវិនិយោគផ្ទាល់ពីបរទេសទាំងនោះ ត្រូវបានត្រួតត្រាដោយវិនិយោគិនបរទេសផ្ទាល់។ ដើម្បីមានសិទ្ធិត្រួតត្រា វិនិយោគិនបរទេសត្រូវកាន់កាប់ដើមទុនច្រើនជាង 50% នៃសហគ្រាសផ្ទាល់ពីបរទេស។ ដូច្នេះ ក្រុមហ៊ុនបុត្រសម្ព័ន្ធបរទេស គឺជាចំណែកមួយយ៉ាងសំខាន់នៃក្រុមហ៊ុនវិនិយោគផ្ទាល់ពីបរទេស។ ទិន្នន័យប្រតិបត្តិការ ដែលត្រូវប្រមូលពីក្រុមហ៊ុនបុត្រសម្ព័ន្ធបរទេសរួមមាន ការនាំចេញ ការនាំចូល ភាពមានការងារធ្វើ ប្រាក់បៀវត្សរ៍ តម្លៃបន្ថែម ទ្រព្យសកម្ម។ ក្នុងករណីប្រទេសកម្ពុជា ទិន្នន័យនេះអាចទទួលបានពីវិស័យកាត់ដេរសម្លៀកបំពាក់ តាមរយៈការធ្វើអង្កេត និងសមាគមរោងចក្រកាត់ដេរនៅក្នុងប្រទេសកម្ពុជា។

យោងតាមលទ្ធផលអង្កេតនៃសហគ្រាសកាត់ដេរសម្លៀកបំពាក់ចំនួន 50 វិនិយោគផ្ទាល់ពីបរទេសមានចំនួន 454 លានដុល្លារអាមេរិក គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2014 ។ សហគ្រាសទាំងនេះបានផ្តល់ការងារចំនួនប្រមាណ 80,000 នាក់ ឬស្មើនឹង 14% នៃចំនួននិយោជិតសរុបនៅក្នុងវិស័យនេះ។ ការវិនិយោគរបស់ប្រទេសចិនមានទំហំដល់ទៅ 383 លានដុល្លារអាមេរិក បន្ទាប់មកប្រទេសកូរ៉េខាងត្បូង 33 លានដុល្លារអាមេរិក ប្រទេសសិង្ហបុរី 10 លានដុល្លារអាមេរិក ប្រទេសម៉ាឡេស៊ី 10 លានដុល្លារអាមេរិក ចំណែកឯប្រទេសថៃ 8 លានដុល្លារអាមេរិក ចក្រភពអង់គ្លេស 8 លានដុល្លារអាមេរិក និងសហរដ្ឋអាមេរិក 2 លានដុល្លារអាមេរិក។ វិស័យកាត់ដេរសម្លៀកបំពាក់ គឺជាឧស្សាហកម្មចម្បងក្នុងវិស័យកម្មន្តសាល និងជាឧស្សាហកម្មដ៏សំខាន់បំផុតនៃវិនិយោគ

[36] *របាយការណ៍អំពីលទ្ធផលអង្កេតវិនិយោគផ្ទាល់ពីបរទេសឆ្នាំ២០១៤*

ផ្ទាល់ពីបរទេសផងដែរ។ វិនិយោគផ្ទាល់ពីបរទេសក្នុងវិស័យនេះមានចំនួន 3,950 លានដុល្លារអាមេរិក នៅចុងឆ្នាំ2014 ដែលមានសមាមាត្រ 86% នៃកម្មន្តសាលសរុបស្មើនឹង 21% នៃវិនិយោគផ្ទាល់ពីបរទេសសរុប នៅក្នុងប្រទេសកម្ពុជា។

សមាគមរោងចក្រកាត់ដេរនៅកម្ពុជា ដែលជាស្ថាប័នឧស្សាហកម្មទំនងជាប្រភពដ៏ប្រសើរបំផុតក្នុងការផ្តល់នូវចំនួនរោងចក្រ ដែលកំពុងមានសកម្មភាព និងចំនួននិយោជិត ដែលកំពុងបម្រើការងារ។ រោងចក្រមួយចំនួនបិទទ្វារជារៀងរាល់ឆ្នាំ មូលហេតុចម្បងនោះ គឺប្រហែលជាមានជាប់ពាក់ព័ន្ធនឹងការលើកទឹកចិត្តទៅលើការវិនិយោគ។ មានន័យថា នៅពេលដែលរយៈពេលលើកទឹកចិត្តលើការវិនិយោគត្រូវបានបញ្ចប់ រោងចក្រនឹងបិទទ្វា ហើយបើកឡើងវិញ ដើម្បីទទួលការលើកទឹកចិត្តលើការវិនិយោគជាថ្មីម្តងទៀត (រយៈពេលអនុគ្រោះពន្ធ) ។ ការបាត់បង់ការបញ្ជាទិញផលិតផលសម្រេចពីអតិថិជនសំខាន់ៗ ក៏ទំនងជាកត្តាតូចមួយក្នុងការបិទរោងចក្រទាំងនេះផងដែរ ប៉ុន្តែបញ្ហានេះមិនបានកើតឡើងជាញឹកញាប់នោះទេ។ ក្នុងអំឡុងពេលតែមួយនេះរោងចក្រថ្មីៗមួយចំនួនក៏បានចូលមកក្នុងទីផ្សារនេះផងដែរ។ ការប្តូរទីតាំងនៃរោងចក្ររបស់ប្រទេសចិនមួយចំនួននៅក្នុងប្រទេសកម្ពុជា គឺជាហេតុផលដ៏ចម្បងក្នុងការធ្វើឲ្យមានកំណើនសុទ្ធនៃរោងចក្រថ្មីៗ។ ដូច្នេះ អ្វីដែលសំខាន់នៃការកើនឡើងនៃកម្រិតវិនិយោគផ្ទាល់ពីបរទេសក្នុងវិស័យនេះ គឺពុំមែនជាការបើករោងចក្រថ្មីនោះទេ ប៉ុន្តែជាការកើនឡើងសុទ្ធនៃរោងចក្រ និងទំហំនៃការវិនិយោគថ្មីទៅវិញ។

តារាងទី១១៖ ចំនួនរោងចក្រ និងនិយោជិតក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ឆ្នាំ២០១៤

| | ចំនួនរោងចក្រ | ចំនួនកម្មករ |
|---|---|---|
| • កាត់ដេរសម្លៀកបំពាក់ | 558 | 458,728 |
| • កាត់ដេរស្បែកជើង | 58 | 84,365 |
| • ក្រុមហ៊ុនម៉ៅការបន្ត (Sub-contractor) | 40 | 11,476 |
| សរុប | 656 | 554,569 |

ប្រភព៖ សមាគមរោងចក្រកាត់ដេរនៅកម្ពុជា

សារៈសំខាន់នៃឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ និងស្បែកជើងអាចត្រូវបានវាស់ដោយទិន្នន័យលើចំនួនរោងចក្រ ភាពមានការងារធ្វើ និងការនាំចេញនាំចូលទំនិញ។ ក្នុងអំឡុងឆ្នាំ2014 វិស័យនេះមានរោងចក្រចំនួន 656 និងមាននិយោជិតសរុប 554,569 នាក់ (សូមមើលតារាងទី១១) ។ ការនាំចេញទំនិញក្នុងវិស័យនេះមានទំហំទឹកប្រាក់ចំនួន 5,783.6 លានដុល្លារអាមេរិក បើធៀបនឹងការនាំចេញសរុបចំនួន 7,407.4 លានដុល្លារអាមេរិក ក្នុងអំឡុងឆ្នាំ2014 ឬស្មើនឹង 78%។ ការនាំចូលក្នុងវិស័យនេះមានទឹកប្រាក់ចំនួន 2,747.5 លានដុល្លារអាមេរិក ធៀបនឹងការនាំចូលសរុបចំនួន 10,615.6 លានដុល្លារអាមេរិក ឬស្មើនឹង 26% ។ ការនាំចេញសុទ្ធក្នុងវិស័យនេះមានចំនួន 3,036 លានដុល្លារអាមេរិក (សូមមើលតារាងទី១២) ។

តារាងទី១២៖ ការនាំចេញ និងការនាំចូលសម្លៀកបំពាក់ឆ្នាំ២០១០ ដល់ ២០១៤

(គិតជាលានដុល្លារអាមេរិក)

| | 2010 | 2011 | 2012 | 2013 | 2014 | សមាមាត្រ | បម្រែបម្រួល 2014/2013 |
|---|---|---|---|---|---|---|---|
| **ការនាំចេញតាមមុខទំនិញ** | | | | | | | |
| វិស័យកាត់ដេរសម្លៀកបំពាក់ | 3,015.4 | 3,936.9 | 4,244.9 | 4,911.3 | 5,334.4 | 72.0% | 9.0% |
| វិស័យកាត់ដេរស្បែកជើង | 166.8 | 247.1 | 268.4 | 318.9 | 418.0 | 6.0% | 31.0% |
| វិស័យវាយនភណ្ឌ | 5.7 | 11.2 | 16.1 | 25.1 | 31.2 | 0.0% | 24.0% |
| សរុបរង | 3,187.9 | 4,195.2 | 4,529.4 | 5,255.3 | 5,783.6 | 78.0% | 10.0% |
| ការនាំចេញផ្សេងៗ | 718.0 | 839.5 | 1,103.5 | 1,274.6 | 1,623.8 | 22.0% | 27.0% |
| **ការនាំចេញសរុប** | 3,905.9 | 5,034.7 | 5,632.9 | 6,529.9 | 7,407.4 | | |
| **ការនាំចូលតាមមុខទំនិញ** | | | | | | | |
| វត្ថុធាតុដើមសម្រាប់វិស័យកាត់ដេរសម្លៀកបំពាក់ | 1,448.7 | 1,771.8 | 2,175.7 | 2,598.4 | 2,747.5 | 26.0% | 6.0% |
| ការនាំចូលផ្សេងៗ | 4,306.9 | 5,408.1 | 5,963.2 | 7,150.6 | 7,868.1 | 74.0% | 10.0% |
| **ការនាំចូលសរុប** | 5,755.6 | 7,179.9 | 8,138.9 | 9,749.0 | 10,615.6 | | |
| **ការនាំចេញសុទ្ធ វិស័យកាត់ដេរសម្លៀកបំពាក់** | | | | | | | |
| កាត់ដេរស្បែកជើង និងវាយនភ័ណ្ឌ | 1,739.2 | 2,423.4 | 2,353.6 | 2,657.0 | 3,036.0 | | 14.0% |

ប្រភព៖ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ៥.២.២ FDI ជម្រុញដល់កំណើន GDP និងការកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសកម្ពុជា

### ៥.២.២.១ និន្នាការទូទៅនៃ FDI និងកំណើនសេដ្ឋកិច្ចនៅកម្ពុជា

ការវិនិយោគផ្ទាល់ពីបរទេស FDI ពិតជាដើរតួនាទីយ៉ាងសំខាន់ក្នុងការជម្រុញដល់ការរីកចម្រើនក្នុងប្រទេសកម្ពុជា ពីព្រោះប្រទេសនេះបានឆ្លងកាត់សោកនាដកម្មជាច្រើនជំនាន់ ជាពិសេសរបប ប៉ុល ពត ដែលបានបំផ្លិចបំផ្លាញស្ទើរតែទាំងស្រុងនូវហេដ្ឋារចនាសម្ព័ន្ធគ្រប់ប្រភេទរួមទាំងធនធានមនុស្ស និងជីវិតស្លូតត្រង់ប្រមាណជាងពីរលាននាក់។ ដោយសារកង្វះទុនក្នុងស្រុកសម្រាប់ពង្រឹងកំណើន និងការអភិវឌ្ឍន៍ មូលធនបរទេស ពិតជាមានសារៈប្រយោជន៍ចំពោះគោលដៅនេះ។

ក្រាហ្វិកទី៥៖ សមាមាត្រនៃភាគហ៊ុន FDI ទៅជា GDP (ក្នុងលោការីត)




ប្រភព៖ សន្និសីទអង្គការសហប្រជាជាតិស្តីពីពាណិជ្ជកម្ម និងការអភិវឌ្ឍ

ម្យ៉ាងវិញទៀត ដើម្បីទាក់ទាញ FDI ពីខាងក្រៅ កម្ពុជាត្រូវធ្វើកំណែទម្រង់សេដ្ឋកិច្ចដ៏ធំមួយ ដោយផ្លាស់ប្តូរពីសេដ្ឋកិច្ចផែនការទៅជាសេដ្ឋកិច្ចទីផ្សារនៅចុងឆ្នាំ1980 ប្រទេសនេះក៏កែលម្អបរិយាកាសវិនិយោគ និងធុរកិច្ចសម្រាប់អ្នកវិនិយោគបរទេសផងដែរ តាមរយៈការបង្កើតច្បាប់វិនិយោគក្នុងឆ្នាំ1994 ។ មុនទសវត្សរ៍ឆ្នាំ1990 ភាគហ៊ុន FDI ជាភាគរយនៃ GDP មានតិចតួចណាស់។ ឧទាហរណ៍៖ សម្រាប់រយៈពេលពីឆ្នាំ1980 ដល់ឆ្នាំ1989 ភាគហ៊ុន FDI ជាភាគរយនៃ GDP មានត្រឹមតែ 3.58% ជាមធ្យម។ ជាអកុសលចំនួនទឹកប្រាក់នៅតូចនៅឡើយពីឆ្នាំ1990 ដល់ឆ្នាំ1993 ហើយវាចាប់ផ្តើមកើនឡើងបន្តិចម្តងៗ។ ដើម្បីទាក់ទាញ FDI រដ្ឋាភិបាលកម្ពុជាបានអនុម័តច្បាប់វិនិយោគក្នុងឆ្នាំ1994 ។ ហើយជាលទ្ធផលភាគហ៊ុន FDI ទំនងជាកើនឡើងក្នុងអត្រាគួរ

ឲ្យកត់សម្គាល់។ ចាប់ពីឆ្នាំ1994 ដល់ឆ្នាំ1998 ភាគហ៊ុន FDI ជាភាគរយនៃ GDP គឺ 18.8% ចំនួនទឹកប្រាក់បន្តកើនឡើងដល់ 43.09% សម្រាប់រយៈពេលពីឆ្នាំ1999 ដល់ឆ្នាំ2014 (សូមមើលក្រាហ្វិកទី៥ )។ កំណើននេះកើតឡើងដោយសារស្ថិរភាពនយោបាយ សមាហរណកម្មសេដ្ឋកិច្ចពិភពលោក និងតំបន់ ការអនុវត្តទៅលើច្បាប់វិនិយោគ និងគោលនយោបាយសេដ្ឋកិច្ចអនុគ្រោះពន្ធ ដែលបង្កើតឱកាសល្អសម្រាប់អ្នកវិនិយោគបរទេស។

ក្រាហ្វិកទី៦៖ GDP ពិតប្រាកដនៅក្នុងមនុស្សម្នាក់ៗ




ប្រភព៖ សន្និសីទអង្គការសហប្រជាជាតិស្តីពីពាណិជ្ជកម្ម និងការអភិវឌ្ឍន៍

ក្រឡេកមើលនិន្នាការកំណើន GDP វាទំនងជាប្រែប្រួលតាមពេលវេលា។ ជាឧទាហរណ៍៖ ក្នុងអំឡុងឆ្នាំ1980 ដល់ 1989 អត្រាកំណើនប្រចាំឆ្នាំជាមធ្យមនៃផលិតផលក្នុងស្រុកសរុបពិតប្រាកដមានត្រឹមតែ 4.69 និង 4.94% ពីឆ្នាំ1990 ដល់ឆ្នាំ1993 កំណើននេះបានកើនឡើងបន្តិច 5.76% សម្រាប់រយៈពេល ពីឆ្នាំ 1994 ដល់ឆ្នាំ1998។ កំណើនយឺតនេះកើតឡើងដោយសារអស្ថិរភាពនយោបាយ ពីព្រោះសន្តិភាពពេញលេញក្នុងប្រទេសមិនទាន់បានស្តារឡើងវិញនៅឡើយទេ។ ក្នុងរយៈពេលនោះសង្គ្រាមស៊ីវិលនៅតែកើតមាននៅក្នុងតំបន់ជាច្រើននៃប្រទេសកម្ពុជា ជាពិសេសនៅតាមព្រំដែនជាមួយប្រទេសថៃ ដែលបង្កការលំបាកដល់គម្រោងអភិវឌ្ឍន៍របស់រដ្ឋាភិបាលក្នុងការចូលទៅក្នុងតំបន់នោះ។ ដូច្នេះផ្នែកខ្លះនៃប្រទេសកម្ពុជានៅតែស្ថិតក្នុងភាពក្រីក្រ ប៉ុន្តែជាសំណាងល្អ គឺនៅចាប់ពីឆ្នាំ1999 ដល់ឆ្នាំ2014 អត្រាកំណើន GDP គឺ 8.1% គិតជាមធ្យម (សូមមើលក្រាហ្វិកទី ៦) ។

ក្រាហ្វិកទី៧៖ កំណើន GDP ពិតប្រាកដ (អត្រាប្រចាំឆ្នាំគិតជាភាគរយ)




ប្រភព៖ សន្និសីទអង្គការសហប្រជាជាតិស្ដីពីពាណិជ្ជកម្ម និងការអភិវឌ្ឍន៍

លើសពីនេះទៅទៀត វាតំណាងឲ្យភាពជោគជ័យសេដ្ឋកិច្ចគួរឲ្យកត់សម្គាល់ដែលកម្ពុជាទទួលបានដោយកំណើនដ៏ខ្ពស់នេះគឺដោយសារតែស្ថិរភាពនយោបាយពេញលេញ និងការពង្រីកសសរស្តម្ភទាំងបួននៃកំណើន រួមមាន សំណង់ វាយនភណ្ឌ និងកាត់ដេរ ទេសចរណ៍ និងកសិកម្ម។ ទោះបីជាយ៉ាងណាក៏ដោយសម្រាប់រយៈពេល កំណើន GDP ពិតប្រាកដប្រចាំឆ្នាំគឺជាង 6.52% (សូមមើលតារាងទី១៣ )[37] ទាបជាងទសវត្សរ៍ចុងក្រោយ 8.1%។ ទោះបីជាអត្រាកំណើនមានកម្រិតខ្ពស់ក្នុងអំឡុងទស្សវត្សរ៍ចុងក្រោយក៏ដោយ ក៏វាត្រូវបានជះឥទ្ធិពលដោយការប៉ះទង្គិចពីខាងក្រៅផងដែរ។ ឧទាហរណ៍ក្នុងឆ្នាំ2009 កំណើន GDP ពិតប្រាកដមានត្រឹមតែ 0.1% (សូមមើលក្រាហ្វិកទី៧ )។ ការធ្លាក់ចុះនៃសេដ្ឋកិច្ចនេះ គឺជាបញ្ហាចម្បងដោយសារតែវិបត្តិហិរញ្ញវត្ថុ ដែលបានកើតឡើងនៅក្នុងសហរដ្ឋអាមេរិកក្នុងឆ្នាំ2008 និងបានរីករាលដាលទៅផ្នែកផ្សេងទៀតនៃពិភពលោក។ កម្ពុជាក៏ជាប្រទេសដែលមានទំនាក់ទំនងពាណិជ្ជកម្មជាមួយអាមេរិករងផលប៉ះពាល់អវិជ្ជមាន។ នេះបង្ហាញថា សេដ្ឋកិច្ចកម្ពុជាហាក់ងាយនឹងមានការរង្គោះរង្គើពីខាងក្រៅ ដែលនាំឲ្យមានការថយចុះសសរស្តម្ភសំខាន់ៗចំនួនបីនៃកំណើនគឺ វាយនភ័ណ្ឌ និងកាត់ដេរ សំណង់ និងឧស្សាហកម្មទេសចរណ៍។ ការរួញតូចនៅក្នុងសសរស្តម្ភទាំងបីបានជះឥទ្ធិពលយ៉ាងខ្លាំងទៅដល់កំណើនក្នុងប្រទេស។ ជាសំណាងល្អដោយសារតែការ

---

[37] Sothan, *Cogent Economics & Finance (2017), descriptive data on each variable, 1980–2014. Downloaded on 30 June 2022 at 10:00PM.* http://dx.doi.org/10.1080/23322039.2016.1277860

ងើបឡើងវិញនៃសេដ្ឋកិច្ចពិភពលោកនាពេលថ្មីៗនេះ ដែលសេដ្ឋកិច្ចកម្ពុជាក៏ចាប់ផ្តើមងើបឡើងវិញនូវភាពរឹងមាំនៃសេដ្ឋកិច្ចរបស់ខ្លួនផងដែរ។ ការសម្រេចបាននូវអត្រាកំណើនពិតប្រាកដនៃ 7.3 ទៅ 7.4 និង 7% ក្នុងឆ្នាំ2012 2013 និង 2014 រៀងគ្នា (សូមមើលក្រាហ្វិកទី៧ )។

តារាងទី១៣៖ ទិន្នន័យពិពណ៌នាអំពីអថេរនីមួយៗនៅចន្លោះឆ្នាំ១៩៨០ ដល់ ២០១៤

| | Real GDP | Manufacturing | Gross fixed capital formation | FDI stock |
|---|---|---|---|---|
| Mean | 6.527942 | 12.58303 | 13.93110 | 25.96484 |
| Median | 6.691602 | 12.13447 | 13.41960 | 26.85757 |
| Maximum | 21.53152 | 19.91324 | 20.94545 | 79.30991 |
| Minimum | -5.668406 | 7.187175 | 7.873631 | 1.678952 |
| Std. dev. | 4.959216 | 4.606079 | 4.285651 | 23.02470 |
| Skewness | 0.436314 | 0.194515 | 0.108344 | 0.547979 |
| Kurtosis | 4.684572 | 1.382571 | 1.445659 | 2.283215 |
| Jarque-Bera | 5.248925 | 4.035824 | 3.591773 | 2.500902 |
| Probability | 0.072479 | 0.132933 | 0.165980 | 0.286376 |
| Sum | 228.4780 | 440.4061 | 487.5885 | 908.7693 |
| Sum sq. dev. | 836.1900 | 721.3426 | 624.4713 | 18024.65 |
| Observations | 35 | 35 | 35 | 35 |

ប្រភព៖ Sothan, Cogent Economics & Finance (២០១៧)

### ៥.២.២.២ ការកាត់បន្ថយភាពក្រីក្រ

ការវិនិយោគផ្ទាល់ពីបរទេស មិនត្រឹមតែបានផ្តល់ការងារសម្រាប់ប្រជាជននៅក្នុងប្រទេសកម្ពុជានោះទេ ការវិនិយោគនេះ ក៏អាចជួយកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសបានផងដែរ ឧទាហរណ៍៖ ឧស្សាហកម្មកាត់ដេរ មានឥទ្ធិពលច្រើនគួរឲ្យកត់សំគាល់ ដែលវិស័យនេះមានតួនាទីសំខាន់យ៉ាងខ្លាំងលើការកាត់បន្ថយភាពក្រីក្រ។ កម្មករទើបចូលថ្មីមិនត្រឹមតែទទួលបានប្រាក់បៀវត្សស្មើ ឬលើសពី 192 ដុល្លារក្នុងមួយខែ ហើយពួកគេក៏អាចទទួលបានប្រាក់បន្ថែមផ្សេងៗទៀតដូចជា ប្រាក់បៀវត្សដំណាច់ឆ្នាំ និងប្រាក់លើទឹកចិត្តធ្វើការបន្ថែមម៉ោងដែលខ្ពស់ ឬច្រើនជាងខ្សែបន្ទាត់ក្រីក្រ។ ដូច្នេះ ប្រាក់បៀវត្សដែលកម្មករកាត់ដេរអាចរកបាននៅក្នុងមួយខែអាចប្រើប្រាស់សម្រាប់ការរស់នៅប្រចាំថ្ងៃ និងអាចមានសល់ខ្លះយកទៅផ្គត់ផ្គង់ដល់គ្រួសារនៅឯជនបទសម្រាប់ធ្វើកសិកម្ម និងសងបំណុលគ្រួសារបានមួយចំនួនថែមទៀតផង ។ ទាំងនេះហើយធ្វើឲ្យជីវភាព គ្រួសាររបស់គេមានភាពធូរធារជាងមុន។

តារាងទី១៨៖ ប្រាក់ឈ្នួលពលកម្មផ្នែកវាយនភ័ណ្ឌកាត់ដេរសម្លៀកបំពាក់... និងសំណង់

ទិន្នន័យប្រាក់ឈ្នួល ក្នុងវិស័យ កាត់ដេរសម្លៀកបំពាក់ និងស្បែកជើង ឆ្នាំ២០២២

| | | ក្នុងមួយខែគិតជាដុល្លា(អប្បបរមា) | ក្នុងមួយខែគិតជារៀល(អប្បបរមា) |
|---|---|---|---|
| កាត់ដេរសម្លៀកបំពាក់ និងស្បែកជើង | *សាកល្បង* | $192.00 | 781,824.00៛ |
| | *ពេញសិទ្ធិ* | $194.00 | 789,968.00៛ |
| សំណង់ | | ក្នុងមួយថ្ងៃគិតជាដុល្លា(អប្បបរមា) | ក្នុងមួយថ្ងៃគិតជារៀល(អប្បបរមា) |
| | *N/A* | $5.00 | 20,000.00៛ |

ទិន្នន័យប្រាក់ឈ្នួល ក្នុងវិស័យ សំណង់ ឆ្នាំ២០១៩

ប្រភព៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ក្នុងការងារសំណង់វិញ ក៏អាចជួយដល់ប្រជាជននូវប្រាក់ចំណូលប្រចាំថ្ងៃអប្បបរមាស្មើ ឬលើសពី ២ ម៉ឺនរៀលក្នុងមួយថ្ងៃ ដែលអាចឲ្យប្រជាជនក្រីក្រ និងអ្នកគ្មានជំនាញស្វែងរកប្រាក់បន្ថែមសម្រាប់ផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ ក្រៅពីធ្វើកសិកម្ម។ ចំណែកឯកសិកម្មកែច្នៃវិញ បានជួយសម្រួលដល់ការកាត់បន្ថយភាពក្រីក្រផងដែរ និងធ្វើឲ្យជីវភាពប្រជាជនមានកំណើនជាងមុន ព្រោះប្រជាជនភាគច្រើនប្រកបរបរកសិកម្ម ហើយពួកគេអាចធ្វើការដាំបន្លែក្នុងឧស្សាហកម្មកែច្នៃនៅពេលទំនេរពីការងារបង្កបង្កើនផលរបស់ពួកគេ ។

ការកើនឡើងនៃការវិនិយោគផ្ទាល់ពីបរទេស (FDI) បាននាំមកនូវការប្រកួតប្រជែងគុណភាពផលិតផលកសិកម្ម ហើយក៏ជួយជំរុញទៅដល់ផលិតភាពកសិផលដល់ប្រជាកសិករផងដែរ ដោយការនាំចូលមកនូវបច្ចេកវិទ្យាថ្មីៗ ក្នុងការជំរុញផលិតភាពធ្វើឲ្យទិន្នផលកើនឡើង និងប្រើប្រាស់នូវបច្ចេកទេសដើម្បីធ្វើឲ្យគុណភាពប្រសើរជាង ដើម្បីយកទៅប្រកួតប្រជែងក្នុងទីផ្សារខាងក្រៅ ដោយបានធ្វើឲ្យផលិផលកសិកម្មលក់បានថ្លៃប្រសើរជាងមុន។ ជាលទ្ធផល កសិករកម្ពុជាអាចរកប្រាក់ចំណូលបន្ថែមពីវិស័យកសិកម្ម និងជំរុញឲ្យវិស័យកសិកម្មកាន់តែរឹងមាំថែមទៀត។

# ជំពូកទី ៦
# ការពិភាក្សា សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៦.១ ការពិភាក្សា

បើទោះបីជាមានកត្តាមួយចំនួន ដែលរាំងស្ទះទៅដល់ការវិនិយោគផ្ទាល់ពីបរទេស (FDI) នៅក្នុងប្រទេសកម្ពុជាយ៉ាងណាក្តីដូចជា កង្វះខាតហេដ្ឋារចនាសម្ព័ន្ធ កង្វះសមត្ថភាពធនធានមនុស្ស ប្រព័ន្ធហិរញ្ញវត្ថុ ជម្លោះដីសម្បទាន និងកត្តាផ្សេងៗទៀតយ៉ាងណាក៏ដោយ ក៏ប្រទេសកម្ពុជានៅតែជាគោលដៅ ដ៏សមស្របមួយសម្រាប់វិនិយោគិនពីបរទេសក្នុងការវិនិយោគផ្ទាល់មកក្នុងប្រទេសកម្ពុជា។ នេះដោយសារតែប្រទេសកម្ពុជាជាប្រទេសដែលមានការអនុគ្រោះនូវពន្ធនាំចេញ ឬយកពន្ធតិចតួចបំផុតទៅកាន់ទីផ្សារនៅលើពិភពលោក ជាពិសេសគឺថ្លៃឈ្នួលកម្លាំងពលកម្មទាប និងអត្រាមនុស្សវ័យក្មេងមានចំនួនច្រើន (មនុស្សដែលអាចបំពេញការងារកម្លាំងពលកម្ម 100%) ដែលជាផ្នែកមួយនៃការទាក់ចិត្តវិនិយោគិននៅលើបណ្តាប្រទេសក្នុងពិភពលោក ជាពិសេសគឺស្ថានភាពនយោបាយនៅក្នុងប្រទេសកម្ពុជា មានសុខសន្តិភាព។ យ៉ាងណាមិញ រដ្ឋាភិបាលក៏បាននឹងកំពុងព្យាយាមបង្កើតនូវសាលាបណ្តុះបណ្តាលជំនាញផ្សេងៗជាច្រើន ដែលទីផ្សារបច្ចុប្បន្នកំពុងត្រូវការទៅដល់ប្រជាជនក្នុងប្រទេស ដើម្បីធ្វើយ៉ាងណាឲ្យពួកគេមានជំនាញច្បាស់លាស់ ហើយអាចមានសមត្ថភាពបំពេញនូវការងារក្នុងក្រុមហ៊ុន និងរោងចក្រសហគ្រាស ដែលជាក្រុមហ៊ុនវិនិយោគផ្ទាល់ពីបរទេស ជាពិសេសក្នុងវិស័យឧស្សាហកម្ម មិនមែនវិស័យកាត់ដេរសម្លៀកបំពាក់ ដែលប្រើប្រាស់នូវបច្ចេកវិទ្យាទំនើបៗជាច្រើន។ លើសពីនេះទៅទៀត រដ្ឋាភិបាលបានកសាងហេដ្ឋារចនាសម្ព័ន្ធជាច្រើន ជាពិសេសបណ្តាញផ្លូវនៅតាមតំបន់ជនបទ ដើម្បីធ្វើយ៉ាងណាឲ្យមធ្យោបាយដឹកជញ្ជូនកាន់តែមានភាពងាយស្រួល ជាពិសេសគឺការផ្គត់ផ្គង់នូវថាមពលអគ្គិសនីឲ្យបានគ្រប់គ្រាន់ និងតាមតម្រូវការក្នុងចង្វាក់ផលិតកម្មតាមសហគ្រាសនីមួយៗ។

ការវិនិយោគផ្ទាល់ពីបរទេសបានបណ្តាក់ទុនលើគ្រប់វិស័យចម្បងៗ នៅក្នុងប្រទេសកម្ពុជាក្នុងនោះរួមមាន វិស័យកសិកម្មដែលបានធ្វើការវិនិយោគលើគម្រោង កសិកម្មកែច្នៃ កសិដ្ឋានចិញ្ចឹមសត្វ និងចំការកៅស៊ូជាដើម។ ចំណែកឯវិស័យឧស្សាហកម្មមានការវិនិយោគលើគម្រោងដូចជាផលិតផល អាហារទឹកបរិសុទ្ធ រោងចក្រថាមពលអគ្គិសនី រោងចក្រផលិតសំលៀកបំពាក់ ឧស្សាហកម្មរ៉ែ ប្លាស្ទិច ស្បែកជើង ស្រោមជើង រោងចក្រអារឈើ និងឧស្សាហកម្មផ្សេងៗទៀត។ វិស័យពាណិជ្ជកម្ម សេវាកម្ម រួមមាន សេវាកម្មការដឹកជញ្ជូន ហិរញ្ញវត្ថុ រដ្ឋបាលសាធារណៈ អចលនទ្រព្យ ជំនួញ សណ្ឋាគា និង ភោជនីយដ្ឋាន គមនាគមន៍ និង សេវាកម្មផ្សេងៗមួយចំនួនទៀត។ វិស័យទាំងអស់នេះបានរួមចំណែកចំណែកយ៉ាងសំខាន់ទៅដល់សេដ្ឋកិច្ចកម្ពុជា ដើម្បីមានឱកាសក្នុងការនាំចេញផលិតផលទៅកាន់ទីផ្សារអន្តរជាតិ ជាពិសេសគឺបង្កើនការងារនៅក្នុងប្រទេសផងដែរ។

## ៦.២ សេចក្តីសន្និដ្ឋាន

ឆ្លងតាមការបកស្រាយប្រធានបទខាងលើនេះ ការវិនិយោគផ្ទាល់ពីបរទេសបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការកាត់បន្ថយវិសមភាពនៃប្រាក់ចំណូលនៅក្នុងប្រទេសកម្ពុជាពិតប្រាកដមែន។ ការខិតខំប្រឹងប្រែងពីសំណាក់រាជរដ្ឋាភិបាល ដោយសហការជាមួយវិស័យឯកជនក្នុងការកសាងនូវហេដ្ឋារចនាសម្ព័ន្ធ និងកិច្ចសម្របសម្រួលផ្សេងៗ ដើម្បីពង្រីកវិសាលភាពវិនិយោគទៅក្នុងតំបន់ជនបទ ដែលជាផ្នែកមួយនៃការអភិវឌ្ឍដល់ប្រទេសកម្ពុជាទាំងមូល ដូចជាបង្កើនការងារដល់ប្រជាជនគ្រប់ខេត្តក្រុងនៅទូទាំងប្រទេស ការផ្ទេរបច្ចេកវិទ្យា និងជំនាញដល់កម្មករ ការលើកកម្ពស់ផលិតកម្ម និងពាណិជ្ជកម្មអន្តរជាតិ ការកាត់បន្ថយនូវភាពក្រីក្រ និងបង្កើនល្បឿនអភិវឌ្ឍន៍ជាតិយ៉ាងឆាប់រហ័ស។ ត្បិតការវិនិយោគផ្ទាល់ពីបរទេស (FDI) បានផ្តល់ផលប៉ះពាល់ដល់ប្រយោជន៍ប្រទេសកម្ពុជាខ្លះដែរ។ តែទោះបីជាយ៉ាងនោះក្តី បើយើងធ្វើការវិភាគ និងប្រៀបធៀបផលប្រយោជន៍ជាមួយនឹងផលប៉ះពាល់ យើងអាចទាញសេចក្តីសន្និដ្ឋានបានថា វិនិយោគផ្ទាល់ពីបរទេសពិតជាបានផ្តល់នូវគុណសម្បត្តិច្រើនជាងគុណវិបត្តិ ដោយសារការវិនិយោគទាំងអស់នោះអាចជួយឲ្យប្រទេសកម្ពុជាមានការអភិវឌ្ឍរីកចម្រើន និងធ្វើឲ្យសេដ្ឋកិច្ចមានកំណើនយ៉ាងឆាប់រហ័ស។

ម្យ៉ាងវិញទៀត ការវិនិយោគផ្ទាល់ពីបរទេសបានផ្ទេរគុណប្រយោជន៍ដល់ប្រទេសកម្ពុជាជាច្រើនតាមរយៈការធ្វើឲមានប្រសិទ្ធិភាពនៃកម្លាំងពលកម្មរបស់ប្រជាជនក្នុងប្រទេសកម្ពុជា។ ការវិនិយោគផ្ទាល់ពីបរទេស បានផ្តល់មកនូវសមត្ថភាពពលកម្មក្នុងស្រុកតាមរយៈការបើកទូលាយនូវការផ្លាស់ប្តូរកម្លាំងពលកម្មក្នុងស្រុក និងបរទេស ដោយការផ្ទេរផលប្រយោជន៍ទៅកាន់បុគ្គលិក ឬកម្មករតាមរយៈការបណ្តុះបណ្តាលពីអ្នកមានជំនាញបរទេស (អ្នកមានឯកទេសខ្ពស់) នូវការបង្រៀនឲ្យចេះធ្វើការងារ និងការផ្តល់ការងារជាបទពិសោធន៍ផ្សេងៗ។ ដូច្នេះហើយ ការវិនិយោគផ្ទាល់ពីបរទេសបាននាំមកនូវជាមួយនឹងចំណេះដឹង ចំណេះធ្វើ ដែលជាកត្តាជំរុញឲ្យពលកម្មអនុវត្តន៍ និងធ្វើការផ្លាស់ប្តូរទៅរកការងារប្រើប្រាស់ជំនាញ និងធ្វើឲ្យដំណើរការការងារអាចទទួលបានជោគជ័យ។

សរុបសេចក្តីមក ការវិនិយោគផ្ទាល់ពីបរទេស គឺជាចលករមួយក្នុងការផ្ទេរ និងផ្តល់ផលប្រយោជន៍ជាច្រើនដល់ប្រជាជននៅក្នុងប្រទេសកម្ពុជា តាមរយៈការបង្កើតការងារនៅតាមវិស័យផ្សេងៗ ដែលជាប្រភពចំណូលដ៏សំខាន់ក្នុងការផ្គត់ផ្គង់ទៅដល់ជីវភាពផ្ទាល់ខ្លួន និងគ្រួសាររបស់ពួកគេ។ ទាំងអស់នេះហើយ ដែលជាកត្តាជម្រុញទៅដល់ការកាត់បន្ថយនូវវិសមភាពនៃប្រាក់ចំណូល ពីព្រោះទាំងអ្នកនៅទីក្រុង និងអ្នកនៅតាមតំបន់ជនបទ មានឱកាសទទួលបានប្រាក់ចំណូលតាមរយៈការប្រកបការងារនៅក្នុងវិស័យទាំងអស់នោះផងដែរ។

## ៦.៣ ការផ្តល់អនុសាសន៍

តាមរយៈការវិភាគ និងបង្ហាញពីទំនាក់ទំនងរវាងការវិនិយោគផ្ទាល់ពីបរទេស (FDI) និងការកាត់បន្ថយវិសមភាពនៃប្រាក់ចំណូលៈ ករណីសិក្សាប្រទេសកម្ពុជា យើងឃើញថារាជរដ្ឋាភិបាលគួរតែយកចិត្តទុកដាក់បន្ថែមទៅលើៈ

❖ បង្កើនការទាក់ទាញវិនិយោគផ្ទាល់ពីបរទេសបន្ថែម

បង្កើនការផ្សព្វផ្សាយជាសាធារណៈ ឲ្យបានទូលំទូលាយដល់គ្រប់ស្រទាប់ប្រជាជននូវផែនការអភិវឌ្ឍន៍របស់រដ្ឋាភិបាល ជាពិសេសលើព័ត៌មានទាក់ទងនឹងស្ថានភាពសេដ្ឋកិច្ច នយោបាយ និងសង្គមរបស់ប្រទេសកម្ពុជា តាមរយៈការបោះពុម្ពផ្សាយជាសៀវភៅណែនាំផ្សេងៗ និងការផ្សព្វផ្សាយតាមប្រព័ន្ធអេឡិចត្រូនិចអំពីសក្តានុភាពនៃវិស័យវិនិយោគនៅក្នុងប្រទេសកម្ពុជា។ ការលើទឹកចិត្តវិនិយោគិន ក្នុងការបន្ថែមប្រសិទ្ធិភាពការផ្សព្វផ្សាយ អំពីកាលានុវត្តន៍ភាពនៃវិស័យវិនិយោគរបស់កម្ពុជា ជាពិសេសការទាក់ទាញនៃវិស័យទេសចរណ៍គួរតែធ្វើឡើងនៅតាមប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិផ្សេងៗ ដែលទើបនឹងបង្កើតឡើងក្នុងកិច្ចជំរុញដល់ការទាក់ទាញវិនិយោគផ្ទាល់ពីបរទេសឲ្យមកវិនិយោគនៅក្នុងប្រទេសកម្ពុជា។

❖ កាត់បន្ថយរបាំងរាំងស្ទះដល់ការបង្កើតមូលដ្ឋានវិនិយោគ

រដ្ឋាភិបាលគួរតែបន្តកិច្ចខិតខំប្រឹងប្រែងកែលម្អស្ថាប័ននានា ហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធច្បាប់របស់ខ្លួន តាមរយៈការលុបបំបាត់របាំងផ្នែករដ្ឋបាលផ្សេងៗ ដែលអាចជះឥទ្ធិពលអវិជ្ជមានលើលំហូរវិនិយោគផ្ទាល់ពីបរទេស និងដំណើរការប្រព្រឹត្តទៅនៃវិនិយោគ ដែលបានបង្កើតមូលដ្ឋានរួចហើយ។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាគួរតែព្យាយាម និងធ្វើការផ្គូរផ្គង់អ្នកវិនិយោគក្នុងស្រុក ដែលបានចុះបញ្ជី និងចង្អុលបង្ហាញដៃគូវិនិយោគពីបរទេស ដោយការបង្កើតជាជំនួបជួបជុំរវាងវិនិយោគិនទាំងក្នុងស្រុក និងបរទេស។ ទីមួយៈ គឺដើម្បីជំរុញដល់ការបង្កើតមូលដ្ឋានវិនិយោគផ្ទាល់ពីបរទេសឲ្យកាន់តែប្រសើរ និងឆាប់រហ័សឡើង។ ទីពីរៈ គឺដើម្បីផ្តល់ឱកាសដល់វិនិយោគិនក្នុងស្រុកក្នុងការពង្រឹង និងពង្រីកពាណិជ្ជកម្មរបស់ខ្លួន ដោយការទាញយកផលប្រយោជន៍ពីគ្នាទៅវិញទៅមកនូវបទពិសោធន៍គ្រប់គ្រងធនធាន ការប្រើប្រាស់បច្ចេកវិទ្យាទំនើបៗ ដើម្បីឲ្យដំណើរការផលិតកម្មប្រព្រឹត្តទៅកាន់តែមានប្រសិទ្ធភាពឡើង។

❖ កង្វះខាតវត្ថុធាតុដើម

ការលើកទឹកចិត្តដល់ឧស្សាហកម្មកែច្នៃវត្ថុធាតុដើម គួរតែត្រូវបានយកចិត្តទុកដាក់ ដើម្បីលើកទឹកចិត្តដល់ការប្រើប្រាស់វត្ថុធាតុដើមបានមកពីវិស័យកសិកម្មក្នុងស្រុក ដែលទីមួយ គឺជួយបង្កើនការងារដល់ប្រជាជននៅតាមជនបទ និងទីពីរ គឺដើម្បីកាត់បន្ថយថ្លៃដើមផលិតកម្មលើចំណាយក្នុងការដឹកជញ្ជូន។

❖ ចំពោះបញ្ហាដីសម្បទាន

បញ្ហាដំលោះដីសម្បទាន គឺជាបញ្ហាដែលកំពុងតែជួបប្រទះនាពេលបច្ចុប្បន្ន។ រដ្ឋាភិបាលគួរតែបង្កើតយន្តការដោះស្រាយវិវាទដីធ្លី ដើម្បីសម្រួលទាំងភាគីទាំងសងខាង (ប្រជាជន និងអ្នកវិនិយោគ) ឲ្យស្វែងរកនូវដំណោះស្រាយជាសន្តិវិធី ដែលផ្តល់នូវផលចំណេញដល់ភាគីទាំងសងខាង ដោយត្រូវមានតម្លាភាពចំពោះការផ្តល់សំណងសាកសមជាមួយប្រជាជន និងអ្នកវិនិយោគ។ ហើយដើម្បីកាត់បន្ថយបញ្ហាមុននឹងធ្វើការផ្តល់ជាដីសម្បទានដល់ដៃគូអភិវឌ្ឍន៍ ដែលរដ្ឋាភិបាលគួរតែធ្វើការសិក្សាលំអិតដល់ភាគីពាក់ព័ន្ធ ដោយសិក្សាឲ្យបានស៊ីជម្រៅនូវអត្ថប្រយោជន៍ និងផលប៉ះពាល់នៃការផ្តល់ដីសម្បទាននីមួយៗ និងការផ្តល់ជាដំណោះស្រាយសមស្របមួយ ក្នុងការចេញជាសំណងដល់ភាគីរងគ្រោះ ដែលសំណងនេះជាទូទៅរាជរដ្ឋាភិបាលអាចធ្វើការចចារជាមួយនឹងក្រុមហ៊ុនវិនិយោគលើគម្រោងអភិវឌ្ឍន៍បាន។

❖ កាត់បន្ថយកង្វះខាតធនធានមនុស្ស

ដើម្បីជៀសវាងការពឹងផ្អែកលើធនធានពីបរទេស (ធនធានពីខាងក្រៅ) ការពង្រឹងធនធានមនុស្សតាមរយៈការបណ្តុះបណ្តាលធនធានក្នុងស្រុកឲ្យទទួលបាន យ៉ាងហោចណាស់នូវជំនាញមូលដ្ឋានមួយចំនួនដែលអាចឲ្យពួកគេធ្វើការជាមួយនឹងអ្នកវិនិយោគបរទេសបាន ឬក៏បង្កើតពាណិជ្ជកម្មធុនតូច និងមធ្យមដោយខ្លួនឯងដើម្បីជាកិច្ចសម្របសម្រួលដល់ការវិនិយោគផ្ទាល់ពីបរទេស។

សរុបសេចក្តីមក លំហូរនៃការវិនិយោគផ្ទាល់ពីបរទេសមកក្នុងប្រទេសកម្ពុជាពិតជានាំមកនូវការអភិវឌ្ឍដល់ប្រទេសកម្ពុជា និងប្រជាជនកម្ពុជា ជាពិសេសប្រជាជនក្រីក្រ ឬកាត់បន្ថយនូវគម្លាតនៃប្រាក់ចំណូល និង គោលដៅអភិវឌ្ឍន៍ផ្សេងៗទៀត។ ដូច្នេះ រដ្ឋាភិបាលជាតួអង្គសំខាន់ក្នុងការសម្របសម្រួលដំណើរការវិនិយោគរួមជាមួយការអភិវឌ្ឍផ្នែកផ្សេងៗ ដែលជាកត្តាសម្រួលដល់អ្នកវិនិយោគ និងទាក់ទាញវិនិយោគផ្ទាល់ពីបរទេស។

# ឯកសារយោង


1) *Introduction the Global Economy, FDI, and the Regime for Investment.* By Helen V. Milner, *downloaded on 30 April 2022 at 5:00PM.* https://scholar.princeton.edu/sites/default/files/hvmilner/files/hvm_wp_2014.pdf

2) *ដកស្រង់អត្ថបទពី៖* Seng Sothan (2017) *បុព្វហេតុរវាងការវិនិយោគផ្ទាល់ពីបរទេស និងកំណើនសេដ្ឋកិច្ចសម្រាប់ប្រទេសកម្ពុជា Cogent Economics & Finance អត្ថបទ PDF ជាភាសាអង់គ្លេសដែលមានចំណងជើងថា Causality between foreign direct investment and economic growth for Cambodia ។ បានទាញយកនៅថ្ងៃទី30 ខែមេសា ឆ្នាំ2022 ម៉ោង 6:00 ល្ងាច។* https://www.tandfonline.com/doi/pdf/10.1080/23322039.2016.1277860

3) *ដកស្រង់អត្ថបទពី៖ អង្គការទិន្នន័យអំពីការអភិវឌ្ឍ ដែលប្រធានបទនិយាយអំពី គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពក្នុងប្រទេសកម្ពុជា។ បានទាញយកនៅថ្ងៃទី05 ខែឧសភា ឆ្នាំ2022 ម៉ោង 7:00 ល្ងាច។* https://opendevelopmentcambodia.net/km/topics/sustainable-development-goals/#ref-115279-12

4) *Understanding Foreign Direct Investment (FDI)* Jeffrey P. Graham *and* R. Barry Spaulding. *Downloaded on 15 May 2022 at 6:00PM.* http://www.orintonlawfirm.com/data/artikel/01-Understand%20FDI.pdf

5) *Difference Between Home and Host Country (2016, November 28). Compare the Difference Between Similar Terms. Downloaded on 15 May 2022 at 6:00PM.* https://www.differencebetween.com/difference-between-home-and-vs-host-country/

6) *International Business, Foreign Direct Investment, Introduction (Page: 238)*

7) *សម្រាយបន្តពីសារណារបស់និស្សិតឈ្មោះ* នាង នីតា (2021) *ដែលបានដកស្រង់ ប្រភពដើមពី៖* Wild, John J., & Wild, Kenneth L. *(2016). International Business: The Challenges of Globalization (8th ed.).* Harlow: Pearson *(p. 208).*

8) *ដកស្រង់ពី៖ របាយការណ៍អំពីលទ្ធផលអង្កេតវិនិយោគផ្ទាល់ពីបរទេសឆ្នាំ2014 ។ វិធីសាស្ត្រចងក្រងស្ថិតិជញ្ជីងទូទាត់ និងស្ថានភាពវិនិយោគអន្តរជាតិរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ និងបានបោះពុម្ពលើកទី៦ (BPM6) ។ បានទាញយកនៅថ្ងៃទី19 ខែឧសភា ឆ្នាំ2022 ម៉ោង 10:00 ព្រឹក។* https://www.nbc.org.kh/download_files/other_reports/khmer/Report-on-FDI-Survey-Result-2014_NBC_KH.pdf

9) *Suggested Citation:* Chhair, Sokty; Ung, Luyna *(2013): Economic history of industrialization in Cambodia, WIDER Working Paper, No. 2013/134, The United Nations University World Institute for Development Economics Research (UNU-WIDER), Helsinki. Downloaded on 19 May 2022 at 3:00PM.*
https://www.econstor.eu/bitstream/10419/93708/1/773878327.pdf

10) *International Business, Foreign Direct Investment, The Form of FDI (Page: 244 – 245)*

11) *Understanding the Workings of Foreign Direct Investment, Types of FDI. Downloaded on 20 May 2022 at 6:00PM.*
https://tradesmartonline.in/knowledge-hub/stock-market/types-of-fdi/

12) *Understanding the Workings of Foreign Direct Investment, Types of FDI. Downloaded on 20 May 2022 at 9:00PM.*
https://tradesmartonline.in/knowledge-hub/stock-market/types-of-fdi/

13) *សម្រាយបន្តពីសារណារបស់និស្សិតឈ្មោះ* នាង នីតា*(2021) ដែលបានដកស្រង់ ប្រភពដើមពី៖* Rugman, Alan M., & Collinson, Simon. (2012). *International Business: (6th ed.).* Harlow: *Pearson (p. 366)*

14) *What are the types of Foreign Direct Investment?* – Enterslice, *Downloaded on 21 May 2022 at 9:00AM.*
https://www.google.com/amp/s/enterslice.com/learning/types-of-foreign-direct-investment/

15) *Understanding the Workings of Foreign Direct Investment, Types of FDI. Downloaded on 20 May 2022 at 10:00AM.*
https://tradesmartonline.in/knowledge-hub/stock-market/types-of-fdi/

16) *Market-seeking Investment (Foreign Direct Investment in the Transition Economies (mht).*

17) *អង្គការទិន្នន័យអំពីការអភិវឌ្ឍស្តីអំពី៖ គោលនយោបាយ និងបទប្បញ្ញត្តិស្តីពីការវិនិយោគ។ បានទាញយកនៅថ្ងៃទី22 ខែឧសភា ឆ្នាំ2022  ម៉ោង 8:00 ព្រឹក។*
https://opendevelopmentcambodia.net/km/topics/investment-policy-and-regulation/

18) *ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាស្តីអំពី៖ គម្រោង វិនិយោគ ៖ នីតិវិធីនៃការដាក់ពាក្យស្នើសុំវិនិយោគ ឆ្នាំ2020 ។ បានទាញយកនៅថ្ងៃទី22 ខែឧសភា ឆ្នាំ2022 ម៉ោង 8:30 ព្រឹក។*

http://www.cambodiainvestment.gov.kh/investment-scheme/investment-application-procedures.html

19) *ក្រុមប្រឹក្សាសម្រាប់ការអភិវឌ្ឍកម្ពុជា ច្បាប់ស្តីអំពី៖ ការវិនិយោគឆ្នាំ1994 ថ្ងៃទី05 ខែសីហា ឆ្នាំ១៩៩៤ ។ បានទាញយកនៅថ្ងៃទី22 ខែឧសភា ឆ្នាំ2022 ម៉ោង 9:00 ព្រឹក។*
https://data.opendevelopmentcambodia.net/en/dataset/law-on-investment-in-the-kingdom-of-cambodia

20) *សន្និសិទអង្គការសហប្រជាជាតិស្តីអំពី៖ ពាណិជ្ជកម្មអន្តរជាតិ និងការអភិវឌ្ឍ (UNCTAD) មគ្គុទេសក៍ការវិនិយោគសំរាប់ប្រទេសកម្ពុជា៖ ឱកាស និងលក្ខខណ្ឌ (ខែកញ្ញា ឆ្នាំ2003) ។ បានទាញយកនៅថ្ងៃទី22 ខែឧសភា ឆ្នាំ2022 ម៉ោង 9:30 ព្រឹក។*
https://unctad.org/en/docs/iteiia20036_en.pdf

21) *ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា៖ អនុក្រឹត្យលេខ ១១១ ស្តីពីច្បាប់វិសោធនកម្មច្បាប់វិនិយោគ (ថ្ងៃទី26 ខែតុលា ឆ្នាំ2011 ។ បានទាញយកនៅថ្ងៃទី22 ខែឧសភា ឆ្នាំ2022 ម៉ោង 10:00 ព្រឹក។*
https://data.opendevelopmentmekong.net/laws_record/sub-decree-on-the-implementation-of-the-law-on-the-amendment-of-the-law-on-investment

22) *ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាច្បាប់ស្តីអំពី៖ វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ចុះនៅថ្ងៃទី15 ខែតុលា ឆ្នាំ2021 (ទំព័រទី១)។ បានទាញយកនៅថ្ងៃទី22 ខែឧសភា ឆ្នាំ2022 ម៉ោង 11:00 ព្រឹក។*
https://data.opendevelopmentcambodia.net/en/laws_record/law-on-the-investment-of-the-kingdom-of-cambodia

23) Siphana Sok *និង* Soromnear Sin *(កម្ពុជាអនុម័តច្បាប់ថ្មីស្តីពីការវិនិយោគ)* SokSiphana *&* associates *ចុះនៅថ្ងៃទី8 ខែធ្នូ ឆ្នាំ2021 ។ ឯកសារនេះជាភាសាអង់គ្លេស ដោយពុំមានការបកប្រែជាភាសាខ្មែរ។ បានទាញយកនៅថ្ងៃទី22 ខែឧសភា ឆ្នាំ2022 ម៉ោង 11:30 ព្រឹក។*
https://www.soksiphana.com/resources/alerts/cambodia-adopts-newlawoninvestment/#:~:text=On%2015%20October%202021%2C%20Cambodia,efficiency%20of%20investments%20in%20Cambodia

24) *Under the LoI (Chapter 6), 19 investment sectors (listed in Article 24 of the LoI). Downloaded on 23 May 2022 at 6:00PM.*
https://cdc.gov.kh/incentives-and-schemes/

25) *ដកស្រង់ពី៖ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ (Ministry of Foreign Affairsand International Cooperation)។ ស្តីពី ការវិនិយោគផ្ទាល់ពីបរទេសរបស់បណ្តាប្រទេសផ្សេងៗ។ បានទាញយកនៅថ្ងៃទី28 ខែឧសភា ឆ្នាំ2022 ម៉ោង 9:00 ព្រឹក។*

https://data.opendevelopmentcambodia.net/km/dataset/dashboard-series-about-cambodia/resource/ac3ffd22-e65c-4e5b-b474-dfc840016318/view/de5b84e2-2c01-4604-8a24-d11e64e47ecd

26) *ដកស្រង់ពី៖ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ (Ministry of Foreign Affairsand International Cooperation)។ បានទាញយកនៅថ្ងៃទី28 ខែឧសភា ឆ្នាំ2022 ម៉ោង 11:00 ព្រឹក។*

https://data.opendevelopmentcambodia.net/km/dataset/dashboard-series-about-cambodia/resource/ac3ffd22-e65c-4e5b-b474-dfc840016318/view/de5b84e2-2c01-4604-8a24-d11e64e47ecd

27) *ដកស្រង់ពី៖ អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពី យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ2011 ដល់ 2020 (Financial Sector Development Strategy 2011 - 2020)។ បានទាញយកនៅថ្ងៃទី04 ខែមិថុនា ឆ្នាំ2022 ម៉ោង 11:00 ព្រឹក។*

https://gdfi.mef.gov.kh/kh/financial-sector

28) *ដកស្រង់ពី៖ ក្រសួងអប់រំ យុវជន និងកីឡា ស្តីពី ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ 2019 ដល់ 2023 ។ បានទាញយកនៅថ្ងៃទី04 ខែមិថុនា ឆ្នាំ2022 ម៉ោង 11:30 ព្រឹក។*

http://www.moeys.gov.kh/index.php/kh/policies-and-strategies/3179.html#.YpqrgXZBw2x

29) *International Monetary Fund: The IMF and income inequality introduction to inequality. Downloaded on 10 June 2022 at 4:00PM.*

https://www.imf.org/en/Topics/Inequality/introduction-to-inequality

30) *What Is Income Inequality? By* CAROL M. KOPP *Updated November 02, 2021, Reviewed by* ROBERT C. KELLY, *Fact checked by* ARIEL COURAGE. *Downloaded on 10 June 2022 at 6:00PM.*

https://www.investopedia.com/terms/i/income-inequality.asp

31) *Economic Development: chapter 5 Poverty, Inequality, and Development. By* Michael P. Todaro *(New York University)* & Stephen C. Smith *(The George Washington University)*

32) *Pickett, KE; Wilkinson, RG (March 2015). "Income inequality and health: a causal review". Social Science & Medicine. 128: 316–26. Downloaded on 19 June 2022 at 10:30AM.* [*https://doi.org/10.1016%2Fj.socscimed.2014.12.031*](https://doi.org/10.1016%2Fj.socscimed.2014.12.031)

33) *ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) (យុទ្ធសាស្ត្រនៃភាពជាដៃគូប្រទេសកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ីឆ្នាំ ២០១៩ ដល់ ២០២៣) ខែតុលា ឆ្នាំ២០១៩។ បានទាញយកនៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ2022 ម៉ោង 6:00 ល្ងាច។*
https://www.adb.org/sites/default/files/institutional-document/534691/cps-cam-2019-2023.pdf

34) *សន្និសីទអង្គការសហប្រជាជាតិស្តីពីពាណិជ្ជកម្ម និងការអភិវឌ្ឍ (UNCTAD) (មគ្គុទេសក៍ការវិនិយោគនៃប្រទេសកម្ពុជា៖ ឱកាស និងលក្ខខណ្ឌនានា) ខែកញ្ញា ឆ្នាំ២០០៣។ បានទាញយកនៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ2022 ម៉ោង 7:00 ល្ងាច។*
https://unctad.org/system/files/official-document/iteiia20036_en.pdf

35) *របាយការណ៍អំពីលទ្ធផលអង្កេតវិនិយោគផ្ទាល់ពីបរទេសឆ្នាំ២០១៤*

36) Sothan, *Cogent Economics & Finance (2017), descriptive data on each variable, 1980–2014. Downloaded on 30 June 2022 at 10:00PM.*
http://dx.doi.org/10.1080/23322039.2016.1277860

## បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១៖ ប្រភេទនៃការវិនិយោគផ្ទាល់ពីបរទេស (Types of FDI)

ឧបសម្ព័ន្ធទី២៖  គោលដៅទាំង១០ កាត់បន្ថយវិសមភាព

ឧបសម្ព័ន្ធទី៣៖ បញ្ហាសុខភាព និងសង្គមកាន់តែអាក្រក់ទៅៗនៅក្នុងប្រទេស ដែលមិនស្មើគ្នា

ឧបសម្ព័ន្ធទី៤៖ កំណើនសេដ្ឋកិច្ចរយៈពេលវែង និងវិសមភាពនៃប្រាក់ចំណូល

ឧបសម្ព័ន្ធទី៥៖ ការប៉ាន់ស្មានតាមរយៈមេគុណ GINI

## ឧបសម្ព័ន្ធទី១៖ ប្រភេទនៃការវិនិយោគផ្ទាល់ពីបរទេស ( Types of FDI )




(ទាញយកនៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២)

https://tradesmartonline.in/knowledge-hub/stock-market/types-of-fdi/

## ឧបសម្ព័ន្ធទី២៖ គោលដៅទី១០ កាត់បន្ថយវិសមភាព




(ទាញយកនៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២២)

https://opendevelopmentcambodia.net/km/topics/sdg10-reduced-inequalities/

## ឧបសម្ព័ន្ធទី៣៖ បញ្ហាសុខភាព និងសង្គមកាន់តែអាក្រក់ទៅៗនៅក្នុងប្រទេសដែលមិនស្មើគ្នា




(ទាញយកនៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២២)

Wilkinson & Pickett, The Spirit Level (២០០៩)

## ឧបសម្ព័ន្ធទី៤៖ កំណើនសេដ្ឋកិច្ចរយៈពេលវែង និងវិសមភាពនៃប្រាក់ចំណូល




*Sources:* World Bank, *World Development Indicators, 1998* (Washington, D.C.: World Bank, 1998), tab. 1.4; *Economist*, October 19, 1996, p. 82.

(ទាញយកនៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២២)

ធនាគារពិភពលោក (សូចនាករអភិវឌ្ឍន៍ពិភពលោកឆ្នាំ១៩៩៨)

## ឧបសម្ព័ន្ធទី៥៖ ការប៉ាន់ស្មានតាមរយៈមេគុណ GINI




(ទាញយកនៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២)

មេរៀនទី៥៖ ភាពក្រីក្រ វិសមភាព និងការអភិវឌ្ឍ ដោយលោក (P. Todaro & C. smith)